មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា
# ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍

## ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤



ខែតុលា ឆ្នាំ២០២៥

ស្កេនដើម្បីអាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ("របាយការណ៍") ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ("គម្រោង") នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលប្រជាពលរដ្ឋទាំងអស់អាចទទួលបានសិទ្ធិមនុស្សមូលដ្ឋាន ទទួលបាននីតិរដ្ឋដែលគ្មាននិទណ្ឌភាព ទទួលបានការគោរពដោយស្មើភាពគ្នាគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាច ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយចីរភាព។

ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌សកំពុងហើរចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យ ថាជាការទាមទារសេរីភាពនៅកម្ពុជា។

## គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក




គម្រោងនេះ គឺជាគម្រោងបន្តពីគម្រោងសង្កេតសវនាការ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ម.ស.ម.ក ដែលមានគោលដៅគាំទ្រសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមានគោលបំណងចម្បងចំនួនពីរ៖ ទី១បង្កើនការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការ និងទី២ ផ្សព្វផ្សាយគោលគំនិតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។ ក្នុងគោលបំណងទី១ គម្រោងបានធ្វើការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយជាលទ្ធផលបានបោះពុម្ពផ្សាយនូវរបាយការណ៍ និងធ្វើការតស៊ូមតិដោយផ្អែកលើភស្តុតាង ដើម្បីបង្កើននូវការគោរពតាមបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការ និងវិស័យយុត្តិធម៌នៅកម្ពុជា។ គម្រោងបាននឹងកំពុងសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៣ មក ហើយនៅសាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ចាប់តាំងពីខែមិថុនា/កក្កដា ឆ្នាំ២០២២។ នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទីប្រាំបួន

ដែលគម្រោងបានផលិតឡើង និងជារបាយការណ៍ទីបីដែលបានបញ្ចូលទិន្នន័យពីការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ទាំងអស់។

ក្នុងគម្រោងនេះ ម.ស.ម.ក ក៏បានផលិត**កម្រងមេរៀន**ដែលមានសេចក្តីពន្យល់ពេញលេញ វីដេអូ ខិត្តប័ណ្ណព័ត៌មាន និងសំណួរអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។ កម្រងមេរៀននេះអាចស្វែងរកបាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org)។

## សំណួរ និងមតិចូលរួម

លោកអ្នកអាចស្វែងរករបាយការណ៍នេះ និងរបាយការណ៍មុនៗនៅលើគេហទំព័ររបស់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ www.cchrcambodia.org និងនៅលើគេហទំព័រ Sithi Portal។ ប្រសិនបើលោកអ្នកមានចម្ងល់ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org ។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ៖ +៨៥៥(០)២៣ ៧២ ៦៩ ០១

cc BY NC SA

# មាតិកា


មាតិកា ..... 3

បញ្ជីពាក្យកាត់ ..... 5

ខ្លឹមសារសង្ខេប ..... 6

១. សេចក្តីផ្តើម ..... 8

១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ..... 8

១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ ..... 8

១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា ..... 9

១.២ វិសាលភាព និងវិធីសាស្រ្ត ..... 12

២. ទិដ្ឋភាពទូទៅ ..... 16

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការទាំងអស់បានគោរព ..... 19

៣.១ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រាប់គ្រាន់ដើម្បីរៀបចំការពារក្តី ..... 19

៣.២ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ ..... 20

៣.៣ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ..... 21

៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការមួយចំនួនបានគោរព ..... 26

៤.១ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ..... 26

៤.២ សិទ្ធិមានវត្តមាននៅពេលសវនាការ ..... 32

៤.៣ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ..... 36

៤.៤ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ..... 39

៤.៥ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ..... 49

៤.៦ វិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ..... 55

៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរពពេញលេញ ..... 61

៥.១ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ..... 61

៥.២ សិទ្ធិទទួលបានមេធាវី ........................................................................ 64
៥.៣ សិទ្ធិមានសេរីភាព ........................................................................ 72
៥.៤ សិទ្ធិបង្ហាញភស្តុតាង ........................................................................ 77
៥.៥ សិទ្ធិកុមារទំនាស់នឹងច្បាប់ ........................................................................ 80
៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........................................................................ 88
៦.១ អនុសាសន៍រួម ........................................................................ 88
៦.២ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព ........................................................................ 89
៦.៣ អនុសាសន៍ស្តីពីសិទ្ធិទទួលបានមេធាវី ........................................................................ 89
៦.៤ អនុសាសន៍ស្តីពីសិទ្ធបង្ហាញភស្តុតាង ........................................................................ 90
៦.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ........................................................................ 90
៦.៦ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ ........................................................................ 91
៦.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........................................................................ 91
៦.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ........................................................................ 91
៦.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........................................................................ 92
៦.១០ អនុសាសន៍ទាក់ទងនឹងវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ........................................................................ 92
៦.១១ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ........................................................................ 93

# បញ្ជីពាក្យកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ |
| ក្រមសីលធម៌ | ជាឯកសារដែលកំណត់អំពីកាតព្វកិច្ចមិនជ្រៀតជ្រែក មិនលម្អៀង និងការរក្សាការសម្ងាត់ដែលអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ត្រូវគោរពតាម |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត |
| ច្បាប់រៀបចំអង្គការតុលាការ | ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ |
| ច្បាប់ឧត្តមប្រឹក្សានៃអង្គចៅក្រម | ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា |
| ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃ |
| ក.យ | ក្រសួងយុត្តិធម៌ |
| អង្គការមិនមែនរដ្ឋាភិបាល | អង្គការមិនមែនរដ្ឋាភិបាល |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| រដ្ឋាភិបាល | រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| ស.ស.ស.ម | សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស |
| ការពិនិត្យជាសកលតាមកាលកំណត់ | យូភីអ |

# ខ្លឹមសារសង្ខេប

ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌចំនួន ៥៨២ នៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ[1] ដើម្បីវាយតម្លៃការប្រកាន់ខ្ជាប់នូវសិទ្ធិសំខាន់ៗក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមានចែងក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញអំពីការវិភាគទិន្នន័យដែលប្រមូលបាន ក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងពង្រឹងដំណើរការគ្រប់គ្រងយុត្តិធម៌ក្នុងប្រទេសកម្ពុជា។ របាយការណ៍ក៏បានប្រៀបធៀបទិន្នន័យអំឡុងឆ្នាំនេះជាមួយនឹងទិន្នន័យនៃអំឡុងពេលធ្វើរបាយការណ៍មុនៗ ដើម្បីកំណត់និន្នាការ និងវិភាគការវិវឌ្ឍនៃការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។

របាយការណ៍បានរកឃើញថា សម្រាប់ឆ្នាំ២០២៤នេះ តុលាការគោលដៅទាំងបួន បានគោរពតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពោលគឺសិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃចោទប្រកាន់។ គួរឱ្យសាទរផងដែរ ដែលសាលាឧទ្ធរណ៍ចំនួនបី ក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន បានគោរពសិទ្ធិសំខាន់ៗមួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងនោះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ នេះបានបង្ហាញអំពីវឌ្ឍនភាពល្អប្រសើរ បើធៀបនឹងឆ្នាំ២០២៣ សាលាឧទ្ធរណ៍ចំនួនបីបានធានាអនុវត្តសិទ្ធិជាមូលដ្ឋានចំនួនតែ ២ ប៉ុណ្ណោះ។ ក្នុងឆ្នាំ២០២៤ មានសាលាឧទ្ធរណ៍ចំនួនពីរ បានគោរពនូវសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ដែលនេះជាវឌ្ឍនភាពល្អប្រសើរ បើគិតពីឆ្នាំ២០២៣ មក ពុំមានតុលាការណាមួយបានធានានូវវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីនោះឡើយ។

សិទ្ធិសំខាន់ៗចំនួន ៤ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនទាន់ត្រូវបានសាលាឧទ្ធរណ៍ទាំងបួន គោរពពេញលេញនៅឡើយ ដូចជា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សិទ្ធិមានសេរីភាពសិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិមានមេធាវី។ ទោះបីជាការអនុវត្តនេះបានបង្ហាញអំពីវឌ្ឍនភាពប្រសើរ បើធៀបនឹងឆ្នាំមុនដែលមានសិទ្ធិចំនួន ៦ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសាលាឧទ្ធរណ៍ទាំងបួនមិនទាន់បានគោរពពេញលេញក៏ដោយ ក៏មានជាចំណុចគួរឱ្យយកចិត្តទុកដាក់ផងដែរ ឧទាហរណ៍ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងនៅបន្តមិនទាន់បានប្រសើរនៅឡើយ។ ជារួម តាំងពីឆ្នាំ២០២៣មក សិទ្ធិនេះមិនទាន់បានលើកកម្ពស់ឱ្យបានពេញលេញនៅឡើយ ដាក់ស្តែងនៅឆ្នាំ

[1] គម្រោងនេះបានចាប់ផ្តើមសង្កេតសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងនៅសាលាឧទ្ធរណ៍ព្រះសីហនុ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២។

២០២៤ មានចំនួន១៥ ករណី កើតនៅសាលាឧទ្ធរណ៍ចំនួនបី ក្នុងចំណោមតុលាការទាំងបួនដែលជនជាប់ចោទបានលើកឡើងថាមានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មដើម្បីបង្ខំឱ្យពួកគាត់សារភាពនៅដំណាក់កាលនគរបាលយុត្តិធម៌។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ បង្ហាញអំពីវឌ្ឍនភាពប្រសើរតាំងពីឆ្នាំ២០២៣ មក ដោយតុលាការបានគោរពនូវសិទ្ធិសំខាន់ៗចំនួន ៧ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោម ១៤ បើធៀបនឹងឆ្នាំ២០២៣ មានតែចំនួន ៤ ប៉ុណ្ណោះ។ តុលាការនេះក៏បានគោរពសិទ្ធិចំនួន ៣ បន្ថែមទៀតដែលមិនធ្លាប់មាននៅឆ្នាំ២០២៣ រួមមាន សិទ្ធិមានវត្តមានក្នុងសវនាការ ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ សាលាឧទ្ធរណ៍ភ្នំពេញក៏បានបង្ហាញពីការរីកចម្រើនផងដែរ ដោយតុលាការនេះបានគោរពនូវសិទ្ធិសំខាន់ៗចំនួន ៧ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលស្រដៀងនឹងសាលាឧទ្ធរណ៍ត្បូងឃ្មុំដែរ សាលាឧទ្ធរណ៍ភ្នំពេញធានានូវការអនុវត្តប្រសើរបន្ថែមថ្មីទៀត ដូចជាបានប្រកាន់ខ្ជាប់នូវវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។

សាលាឧទ្ធរណ៍ព្រះសីហនុ បានគោរពសិទ្ធិសំខាន់ៗចំនួន ៦ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ គួរឱ្យកត់សម្គាល់ថា សិទ្ធិមានមេធាវីមិនទាន់មានលក្ខណៈប្រសើរទេ បើធៀបនឹងឆ្នាំមុន។ ដោយឡែកសាលាឧទ្ធរណ៍បាត់ដំបង បានគោរពសិទ្ធិសំខាន់ៗចំនួន ៥ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោម ១៤ ដោយប្រសើរជាងឆ្នាំ២០២៣ ។ គួរកត់សម្គាល់ថា សាលាឧទ្ធរណ៍បាត់ដំបងបានអនុវត្តប្រសើរនូវសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈបើធៀបនឹងឆ្នាំមុន។

ពុំមានទិន្នន័យច្រើនទេពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន (កុមារទំនាស់នឹងច្បាប់) គឺមានតែសាលាឧទ្ធរណ៍បាត់ដំបងប៉ុណ្ណោះដែលមានទិន្នន័យនេះ ដែលនេះអាចធ្វើការវាយតម្លៃបានថាសិទ្ធិនេះមិនទាន់ត្រូវបានធានាពេញលេញនៅឡើយ។ នៅតុលាការគោលដៅ ករណីកុមារទំនាស់នឹងច្បាប់ភាគច្រើន គឺជនជាប់ចោទត្រូវបានឃុំខ្លួន។

# ១. សេចក្តីផ្តើម

## ១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសសរស្តម្ភស្នូលនៃនីតិរដ្ឋ និងជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ សិទ្ធិនេះមានវិសាលភាពហួសពីសវនាការលើបុគ្គលម្នាក់ៗ ដោយហេតុថាការលើកកម្ពស់ ឬការរំលោភសិទ្ធិនេះ នឹងឆ្លុះបញ្ចាំងអំពីគុណភាព និងស្ថានភាពនៃប្រព័ន្ធច្បាប់ក្នុងដែនយុត្តាធិការដែលប្រកាន់ខ្ជាប់នូវនីតិរដ្ឋ។ ធាតុផ្សេងៗនៃសិទ្ធិទាំងនេះ មានគោលបំណងធានានូវភាពត្រឹមត្រូវ និងតម្លាភាពក្នុងការអនុវត្តច្បាប់ ដើម្បីធានាសិទ្ធិរបស់ជនជាប់ចោទ និងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ ដើម្បីជាផលប្រយោជន៍ដល់សង្គមទាំងមូល។ ធាតុទាំងនោះ រួមបញ្ចូលក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌទាំងមូល ដោយគិតពីពេលចាប់ផ្តើម នីតិវិធី ឬការឃាត់ខ្លួនជនសង្ស័យ រហូតដល់បណ្តឹងតវ៉ាជាស្ថាពរត្រូវបានបញ្ចប់។[2]

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ

មូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានចែងក្នុងមាត្រា១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ក្នុងចំណោមលិខិតុបករណ៍ផ្សេងៗទៀត។[3] មាត្រា ១០ នៃ ស.ស.ស.ម និងមាត្រា ១៤ (១)នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ ក.អ.ស.ព.ន ពន្យល់បន្ថែមអំពីធាតុផ្សេងៗទៀតនៃការជំនុំជម្រះដោយយុត្តិធម៌ដែលមានជាអាទិ៍ដូចជា សិទ្ធិ និងគោលការណ៍ ដូចតទៅ (សំដៅដល់ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌")៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិក្នុងការនិយាយជាមួយមេធាវីរបស់ខ្លួនមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិមានមេធាវី សិទ្ធិទទួលបានការការពារប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។

[2] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "តើអ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/bdfnh66h

[3] ស.ស.ស.ម (ឆ្នាំ១៩៤៨); ក.អ.ស.ព.ន (ឆ្នាំ១៩៦៦); មាត្រា ៨ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៦៩); មាត្រា ៧ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (ឆ្នាំ១៩៨១) មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៥០) មាត្រា ៤៧-៥០ នៃធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប (ឆ្នាំ២០០០) Art. ៤៧-៥០។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើ ក.អ.ស.ព.ន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានបញ្ចូលកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជា។[4] ដូច្នេះ បញ្ញត្តិនៃ ក.អ.ស.ព.ន ត្រូវអនុវត្តដោយផ្ទាល់ក្នុងតុលាការកម្ពុជា ដូចបានបញ្ជាក់ក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧។[5] នៅក្នុងការពិនិត្យចុងក្រោយបំផុតរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២២ អំពីការអនុវត្តនូវសិទ្ធិមនុស្សដែលអនុលោមទៅនឹង ក.អ.ស.ព.ន. របស់គណៈកម្មាធិការសិទ្ធិមនុស្សបានបង្ហាញនូវការព្រួយបារម្ភមួយចំនួនទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលរួមមាន ការចោទប្រកាន់ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិមិនត្រឹមត្រូវនៅកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ និងមន្ទីរឃុំឃាំង ការឃុំខ្លួនបណ្តោះអាសន្នលើមនុស្សជាច្រើន និងឯករាជ្យភាពរបស់តុលាការ។[6]

### ១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា

ក្របខ័ណ្ឌគ្រឹះសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌មានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះផ្តល់ឱ្យមានការបែងចែកអំណាច និងប្រព័ន្ធតុលាការឯករាជ្យ ដែលធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ដូចខាងក្រោម៖

- គ្មានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ។
- គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោស ចាប់ខ្លួន ឬឃុំខ្លួនឡើយ លើកលែងតែធ្វើឡើងស្របតាមច្បាប់។
- ហាមដាច់ខាតចំពោះការបង្ខិតបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយ ឬការធ្វើទុក្ខទោសផ្សេងៗដែលដាក់ទណ្ឌកម្មបន្ថែមលើជននៅក្នុងឃុំ ឬជនជាប់ឃុំ។
- ចម្លើយសារភាពដែលទទួលបានតាមរយៈការបង្ខំលើរាងកាយ ឬផ្លូវចិត្ត មិនត្រូវបានទទួលស្គាល់ជាភស្តុតាងនៃពិរុទ្ធភាពឡើយ។
- រាល់វិមតិសង្ស័យដែលកើតឡើងនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោស រហូតទាល់តែតុលាការសម្រេចជាស្ថាពរលើសំណុំរឿងនោះ។
- ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិការពារខ្លួនតាមរយៈបណ្តឹងឧប្បាស្រ័យទៅតុលាការ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ចែងអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[7] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ចែងលម្អិតអំពីការប្រព្រឹត្តចំពោះជនសង្ស័យ ជនត្រូវចោទ និងជន

---

[4] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (ឆ្នាំ១៩៩៣) https://tinyurl.com/58rn4thj

[5] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ២, https://tinyurl.com/3p3z9zzn

[6] គណៈកម្មាធិការសិទ្ធិមនុស្ស (HRC), "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយលើកទីបីរបស់កម្ពុជា (CCPR/C/KHM/CO/3), វាក្យខណ្ឌ ២២, ២៦, ៣២

[7] ក្រមព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០១០), https://tinyurl.com/2hrdjbf7

ជាប់ចោទ។[8] ក្រមនេះ ចែងអំពីតួនាទី និងទំនួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតដំបូងរហូតដល់ពេលឃាត់ខ្លួន និងក្នុងអំឡុងពេលនៃដំណើរការរឿងក្តីព្រហ្មទណ្ឌទាំងមូល រហូតដល់បណ្តឹងតវ៉ាបញ្ចប់ជាស្ថាពរ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦[9] ចែងអំពីបទដ្ឋាន និងនីតិវិធីសម្រាប់ដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ និងការពារសិទ្ធិរបស់ពួកគេក្នុងអំឡុងពេលដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។[10]

បន្ថែមលើនេះ ច្បាប់គ្រឹះចំនួនបីទាក់ទងនឹងតុលាការ ពោលគឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[11] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[12] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[13] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ ក្នុងគោលបំណងពង្រឹងនូវឯករាជ្យ តម្លាភាពរបស់តុលាការ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ យ៉ាងណាក្តី ច្បាប់ទាំងនេះទទួលរងនូវការរិះគន់។[14]

នៅខែមិថុនា ឆ្នាំ២០០៣ រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ[15] មួយដែលផ្តោតសំខាន់លើគោលការណ៍ចំនួនបួនរួមមានៈ សិទ្ធិបុគ្គល គោលការណ៍ប្រជាធិបតេយ្យសេរី ការបែងចែកអំណាចនិងនីតិរដ្ឋ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០១៩-២០២៣ បានគូសបញ្ជាក់ពីអាទិភាពសំខាន់ៗ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ រួមមានៈ ការធ្វើឱ្យប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់មានភាពប្រសើរឡើង ការពង្រឹងទំនុកចិត្តរបស់សាធារណជនចំពោះវិស័យតុលាការ និងការប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌។[16] នៅខែសីហា ឆ្នាំ២០២៣ រដ្ឋាភិបាលបានដាក់ចេញនូវ “យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១” ដែលចាត់ទុក “ការធ្វើឱ្យមានភាពប្រសើរឡើង និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌” ជាអាទិភាពមួយក្នុងចំណោមកិច្ចការផ្សេងទៀត។ រដ្ឋាភិបាលបានប្តេជ្ញាថានឹងផ្តោតសំខាន់លើការបង្កើនសមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្តល់មេធាវីការពារដល់ជនក្រីក្រ និងជនងាយរងគ្រោះ ក៏ដូចជាការពង្រឹងប្រសិទ្ធភាពនៃដំណើរការរបស់តុលាការ ការធ្វើ

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“ក្រមនីតិវិធីព្រហ្មទណ្ឌ”) (ឆ្នាំ២០០៧), https://tinyurl.com/3tk7sk6c

[9] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦), https://tinyurl.com/2vxr7293

[10] យូនីសេហ្វ “សំណួរ-ចម្លើយអំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅកម្ពុជា” (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦), https://tinyurl.com/46ftzbjk

[11] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ (ឆ្នាំ២០១៤), https://tinyurl.com/csk3c96f

[12] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា (ឆ្នាំ២០១៤), https://tinyurl.com/y8zhk6yc

[13] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឆ្នាំ២០១៤), https://tinyurl.com/yc2t8kwz

[14] ម.ស.ម.ក គោលដៅយុត្តិធម៌ API អាដហុក អង្គការតម្លាភាពកម្ពុជា និង IFEX “របាយការណ៍រួមស្តីពីសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា”(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨),https://tinyurl.com/545deb9s; ម.ស.ម.ក “ការវិភាគច្បាប់ សេចក្តីព្រាងច្បាប់ចំនួនបីទាក់ទងនឹងតុលាការ” (ឆ្នាំ២០១៤), https://tinyurl.com/jzmpp4un; *សូមមើលផងដែរ* មតិយោបល់របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិលើសេចក្តីព្រាងច្បាប់គ្រឹះចំនួនបីទាក់ទងនឹងតុលាការ (ខែឧសភា ឆ្នាំ២០១៤)៖ https://tinyurl.com/ys4jypw5; https://tinyurl.com/yt3ud573; https://tinyurl.com/yufd4442.

[15] ក្រុមប្រឹក្សាស្តារនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា “ការអនុវត្តគោលនយោបាយរដ្ឋាភិបាល” (ឆ្នាំ២០០៤) វាក្យសព្ទ ១៦, https://tinyurl.com/bddka8a

[16] ក្រសួងផែនការ “ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣” ទំព័រ ២០៥-២០៦ វាក្យសព្ទ ៤.២១(៧), https://tinyurl.com/yep76sfa

ទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីកែលម្អការផ្តល់យុត្តិធម៌ និងការជំរុញឱ្យមានការអភិវឌ្ឍយន្តការដោះស្រាយវិវាទ។[17]

ការអភិវឌ្ឍមួយចំនួនដែលអាចនាំឱ្យមានការកែលម្អគួរឱ្យកត់សម្គាល់លើកំណែទម្រង់ច្បាប់ និង តុលាការក៏បានធ្វើឡើងក្នុងអំឡុងពេលធ្វើរបាយការណ៍នេះដែរ៖

- នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌ បានប្រកាសអំពីដំណើរការកែសម្រួលក្រមព្រហ្មទណ្ឌកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធតុលាការរបស់ប្រទេសឱ្យស្របតាមបទដ្ឋានអន្តរជាតិ និង ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។ ក្រសួងបានបញ្ជាក់ថា ខ្លួនកំពុងសហការជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីធានាថាការកែទម្រង់នេះឱ្យឆ្លើយតបទៅនឹងតម្រូវការសង្គមនាពេលបច្ចុប្បន្ន និង អនាគត និងថាកំណែទម្រង់នេះមានគោលដៅលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងភាពត្រឹមត្រូវក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីឆ្លើយតបនឹងគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន។ ជាពិសេស ការផ្តោតសំខាន់ទៅលើការការពារសិទ្ធិរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ រួមទាំងសិទ្ធិមានមេធាវី សិទ្ធិទទួលបានការការពារប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[18]
- នៅខែមករា ឆ្នាំ២០២៥ ក្រសួងយុត្តិធម៌បានប្រកាសពីការបង្កើតក្រុមការងារស្រាវជ្រាវយុទ្ធសាស្ត្រ គោលនយោបាយ និងការវិភាគ។ ក្រុមការងារដែលមានសមាជិក ១២ រូបនេះ នឹងទទួលបន្ទុកស្រាវជ្រាវ វិភាគ និងផ្តល់យោបល់លើយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធតុលាការ ក៏ដូចជាការពិនិត្យ និងផ្តល់យោបល់លើការរៀបចំច្បាប់។[19]
- នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សាតុលាការ បានប្រកាសពីការដាក់ពិន័យលើចៅក្រមចំនួន ១៤ រូប និងព្រះរាជអាជ្ញាចំនួន ៩ រូប ពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនត្រឹមត្រូវ។ ក្នុងចំណោមនោះ មាន ៤ ករណីគ្រាន់តែជាការស្តីបន្ទោសដោយពាក្យសំដី ខណៈ ១១ ករណីទៀតបានទទួលលិខិតព្រមានជាផ្លូវការ។ បន្ថែមពីលើនេះ បុគ្គលចំនួនបីរូប ត្រូវបានព្យួរពីការដំឡើងឋានៈ ហើយអ្នកដែលនៅសល់ត្រូវបានផ្ទេរដោយបង្ខំ ដកតំណែង និងមានការបណ្តេញព្រះរាជអាជ្ញារងម្នាក់ចេញពីក្របខ័ណ្ឌផងដែរ។ ក្រសួងយុត្តិធម៌បានបញ្ជាក់ថា វិធានការវិន័យនេះបង្ហាញពីការប្តេជ្ញាចិត្តក្នុងការកែទម្រង់ប្រព័ន្ធតុលាការ។[20]

---

[17] រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" (ខែសីហា ឆ្នាំ២០២៣) ទំព័រ៣១ https://tinyurl.com/3nu67vh4

[18] ខ្មែរថាមស៍ "ក្រសួងធ្វើសេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌ" ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ https://www.khmertimeskh.com/501547983/ministry-drafting-criminal-law/

[19] ខ្មែរថាមស៍ 'ក្រសួងបង្កើតក្រុមការងារកំណែទម្រង់យុត្តិធម៌" ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ https://www.khmertimeskh.com/501420008/ministry-establishes-a-working-group-for-justice-reform/

[20] Camboja News "មានចៅក្រម និងព្រះរាជអាជ្ញាជាង២០នាក់ ប្រឈមនឹងវិធានការវិន័យ រួមទាំងការព្យួរ ការផ្អាក និង ការបណ្តេញចេញ" ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ https://cambojanews.com/over-20-judges-prosecutors-face-disciplinary-action-including-suspensions-demotions-and-one-dismissal/

គំនិតផ្តួចផ្តើមទាំងនេះ អាចត្រូវបានចាត់ទុកថាជាការខិតខំប្រឹងប្រែងគួរឱ្យកោតសរសើរដែលរដ្ឋាភិបាលអនុវត្តអនុសាសន៍ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ដែលខ្លួនបានទទួលយកនាពេលថ្មីៗនេះ ក្នុងអំឡុងពេលការពិនិត្យជាសកលតាមកាលកំណត់ជុំទីបួន(«យូភីអ») នៅក្នុងខែឧសភា ឆ្នាំ២០២៤។[21] ក្នុងអំឡុងពេលនៃការពិនិត្យជាសកលតាមកាលកំណត់នេះ រដ្ឋាភិបាលបានទទួលយកអនុសាសន៍មួយចំនួនទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ «ការជំនុំជម្រះដោយយុត្តិធម៌ ជានាជាពិសេសថា ជនដែលរងការចោទប្រកាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌមានសិទ្ធិជួបជាមួយអ្នកនៅខាងក្រៅ គ្រួសារ និងមេធាវីរបស់ខ្លួន ដូចដែលមានចែងនៅក្នុងច្បាប់ និងបទដ្ឋានអន្តរជាតិនានា ដែលត្រូវបានគោរព និងប្រកាន់ខ្ជាប់គ្រប់សំណុំរឿងទាំងអស់។»[22] រដ្ឋាភិបាលក៏បានទទួលយកនូវអនុសាសន៍ចំនួនបួនទាក់ទងនឹងឯករាជ្យភាពរបស់តុលាការ អនុសាសន៍ចំនួនបីទាក់ទងនឹងសិទ្ធិទទួលបានយុត្តិធម៌ និងមួយទៀតផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការ និងច្បាប់។[23] ម.ស.ម.ក បានស្វាគមន៍ចំពោះការទទួលយកអនុសាសន៍ទាំងនេះ ព្រមទាំងបានតស៊ូមតិឱ្យមានការពង្រឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការទទួលបានយុត្តិធម៌ក្នុងដំណើរការ «យូភីអ»។[24]

## ១.២ វិសាលភាព និងវិធីសាស្ត្រ

អំឡុងពេលធ្វើរបាយការណ៍នេះ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក បានចូលរួមសង្កេតសវនាការនៃសំណុំរឿងព្រហ្មទណ្ឌនៅតុលាការគោលដៅទាំងបួនជាប្រចាំ។ អ្នកសង្កេតសវនការបានប្រើតារាងសង្កេតការណ៍សវនាការ ("តារាងសង្កេតការណ៍សវនាការ"[25]ដែលរួមមានសំណួរជាង ៨០ ដែលផ្តោតសំខាន់លើសិទ្ធិសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមានសិទ្ធិដូចខាងក្រោមនេះ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានសេរីភាព
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

---

[21] ការិយាល័យឧត្តមស្នងការ ការពិនិត្យជាសកលតាមពេលកំណត់កម្ពុជា https://www.ohchr.org/en/hr-bodies/upr/kh-index

[22] UNGA, របាយការណ៍របស់ក្រុមការងារពិនិត្យជាសកលតាមពេលកំណត់ A/HRC/៥៧/១៧, វាក្យខណ្ឌ ១៣៩.៦៤ https://docs.un.org/en/A/HRC/57/17

[23] ម.ស.ម.ក " "អនុសាសន៍វដ្តទី ៤ ដែលទទួលយកដោយរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការទទួលបានយុត្តិធម៌" ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០២៤https://www.ម.ស.ម.កcambodia.org/en/publications/infographics/4th-cycle-upr-recommendations-supported-by-rgc-pertaining-to-access-to-justice-2024

[24] ម.ស.ម.ក "របាយការណ៍រួមស្តីពីការពិនិត្យជាសកលតាមពេលកំណត់នៃព្រះរាជាណាចក្រកម្ពុជា ទាក់ទិននឹងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា" ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២៤ https://ម.ស.ម.កcambodia.org/en/publications/general-reports/joint-submission_4th-upr_access-to-justice

[25] ម.ស.ម.ក "តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" https://tinyurl.com/3jcd458

- សិទ្ធិទទួលបានមេធាវី
- សិទ្ធិមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង
- សិទ្ធិបង្ហាញភស្តុតាង (រួមមានសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ
- សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់
- សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីយុត្តិធម៌ និងមិនលម្អៀង ("ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី")។

ក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមគាំទ្រក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការណ៍សវនាការ និងសកម្មភាពសង្កេតសវនាការរបស់ខ្លួនដល់តំណាងតុលាការ ព្រមទាំងក្រសួងយុត្តិធម៌។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធមួយទំព័រភ្ជាប់ជាមួយតារាងសង្កេតការណ៍សវនាការ សម្រាប់ប្រើនៅក្នុងសវនាការពាក់ព័ន្ធនឹងកុមារ (កុមារទំនាស់នឹងច្បាប់)។ ផ្អែកលើតារាងសង្កេតការណ៍សវនាការ ម.ស.ម.ក បានចងក្រងគោលការណ៍ណែនាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ("គោលការណ៍ណែនាំស្តីអំពីតារាងសង្កេតការណ៍សវនាការ")[26] ដើម្បីផ្តល់នូវការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ ដើម្បីធានាឱ្យមានការបកស្រាយដូចគ្នាទាំងអស់។ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ក៏បានទទួលនូវឯកសារក្របខ័ណ្ឌច្បាប់ដែលរៀបរាប់អំពីច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនានាទុកជាមូលដ្ឋានសម្រាប់បញ្ជាក់ពីសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការ។

នៅក្នុងការសង្កេតសវនាការនេះ ម.ស.ម.ក បានយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិប្តឹងឧទ្ធរណ៍ រួមបញ្ចូលទាំងសិទ្ធិទទួលបានការពិនិត្យសំណុំរឿងឡើងវិញដោយពេញលេញផងដែរ មានន័យថាបណ្តឹងឧទ្ធរណ៍ត្រូវតែពាក់ព័ន្ធទាំងទិដ្ឋភាពផ្នែកច្បាប់ សត្យានុម័តនៃការផ្តន្ទាទោស និងការកាត់ទោសលើបុគ្គលនោះ។ ពោលគឺត្រូវផ្តល់នូវ"ការវាយតម្លៃពេញលេញលើភស្តុតាង និងកិច្ចដំណើរការជំនុំជម្រះ។"[27] ដើម្បីបញ្ជាក់ពីការប្តេជ្ញាគោរពតាមគោលការណ៍អន្តរជាតិដែលអនុវត្តចំពោះការសង្កេតសវនាការ ម.ស.ម.ក បានបង្កើតក្រុមសីលធម៌

---

[26] ម.ស.ម.ក "គោលការណ៍ណែនាំអំពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក" https://tinyurl.com/ywr3twde

[27] ក.អ.ស.ព.ន, មាត្រា ១៤ (៥) ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥ គណៈកម្មាធិការសិទ្ធិ មនុស្ស "សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌" (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), CCPR/C/GC/៣២, វាក្យខណ្ឌ ៤៨, https://tinyurl.com/ymw9vvcs គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, *V. P. Domukovsky et al. v. Georgia* (ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៨) *GAOR*, A/៥៣/៤០ (លេខ II) ទំព័រ ១១១ វាក្យខណ្ឌ ១៨.១១, https://tinyurl.com/mvntuakv

សម្រាប់អ្នកសង្កេតសវនាការ ដែលមានចែងអំពីការមិនជ្រៀតជ្រែក មិនលម្អៀង និងរក្សាការសម្ងាត់ ដែលអ្នកសង្កេតសវនាការត្រូវគោរពតាម។[28]

ក្រុមអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក មិនបានកំណត់គោលដៅលើការជំនុំជម្រះជាក់លាក់ណាមួយឡើយ។ ការសង្កេតសវនាការធ្វើឡើង ស្របតាមកាលវិភាគរបស់តុលាការ គឺមិនបានកំណត់ដោយជាក់លាក់ចំពោះសវនាការណាមួយនោះទេ។ វិធីសាស្ត្រនេះធានាថា ដំណើរការនៃប្រមូលទិន្នន័យប្រព្រឹត្តទៅដោយមិនលំអៀង និងមានលក្ខណៈជាតំណាង។ នៅពេលដែលអ្នកសង្កេតសវនាការចូលរួមសង្កេតសវនាការ រាល់ព័ត៌មានត្រូវបានកត់ត្រាភ្លាមៗដោយបញ្ចូលទៅក្នុងតារាងសង្កេតការណ៍សវនាការ។ ទិន្នន័យដែលប្រមូលបានផ្តោតទាំងស្រុងលើដំណើរការសវនាការ ដោយមិនមានការសម្ភាសន៍ ឬកិច្ចសន្ទនាបន្ថែមឡើយ លើកលែងតែក្នុងករណីដែលអ្នកសង្កេតសវនាការត្រូវការព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសម្រេចតែប៉ុណ្ណោះ។ ក្រោយបញ្ចប់សវនាការនីមួយៗ ទិន្នន័យត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់ ម.ស.ម.ក។ បន្ទាប់មក ទិន្នន័យទាំងនេះត្រូវបាន ម.ស.ម.ក វិភាគដើម្បីកំណត់អំពីការអនុវត្តល្អ និងចំណុចមិនទាន់ប្រសើរក្នុងការជំនុំជម្រះនីមួយៗ។ លទ្ធផលនៃការវិភាគទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃពីវឌ្ឍនភាព និងចំណុចដែលធ្វើឱ្យប្រសើរឡើងនៃតុលាការគោលដៅនីមួយៗ។

សម្រាប់គោលបំណងនៃការវិភាគនេះ ម.ស.ម.ក នឹងចាត់ទុកថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគោរព ប្រសិនបើសិទ្ធិនេះទទួលបានការគោរពយ៉ាងហោចណាស់ចំនួន ៨០% នៃសវនាការដែលបានសង្កេតក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ ទោះបីយ៉ាងនេះក្តី ក្នុងករណីដែលមានការបំពានលើសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន និងសិទ្ធិដាច់ខាត (សូមមើលទំព័រទី៥៣) ម.ស.ម.ក នឹងកំណត់ថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនត្រូវបានគោរពដោយមិនផ្អែកលើចំនួននៃភាគរយនោះឡើយ។ ម.ស.ម.ក បានសង្កេតសវនាការក្នុងឆ្នាំ២០២៤ មានចំនួន ៥៨២ សំណុំរឿង គឺទាបជាងឆ្នាំមុន ដែលមានចំនួន ៧៧២ សំណុំរឿង ដោយសារមានបញ្ហាហិរញ្ញវត្ថុ និងធនធានមនុស្ស។ ម.ស.ម.ក សង្ឃឹមថានឹងដោះស្រាយបញ្ហាប្រឈមទាំងនេះ ដើម្បីបន្តការសង្កេតសវនាការរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ ម.ស.ម.ក ធានាថាសាលាឧទ្ធរណ៍ទាំងអស់មានឱកាសក្នុងការផ្តល់ធាតុចូលរបស់ខ្លួនលើរបកគំហើញទាំងនោះមុនពេលរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ។ នៅឆ្នាំ២០២៤ ម.ស.ម.ក បានប្រជុំជាមួយតុលាការគោលដៅ ដើម្បីបង្ហាញលទ្ធផលដែលបានរកឃើញពីសកម្មភាពសង្កេតសវនាការរបស់ខ្លួន និងសុំការបំភ្លឺផ្សេងៗប្រសិនបើចាំបាច់។ ក្នុងអំឡុងពេលធ្វើកិច្ចប្រជុំទាំងនោះ តុលាការបានស្វាគមន៍ចំពោះការរួមចំណែក និងការខិតខំប្រឹងប្រែងរបស់ ម.ស.ម.ក

---

[28] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ បោះពុម្ពលើកទីពីរ" (ឆ្នាំ២០១៤), https://tinyurl.com/nnhppm6b; គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស "តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ មគ្គុទ្ទេសក៍ជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់" (ឆ្នាំ២០០០), https://tinyurl.com/y9ymx3z7; អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប "ការសង្កេតសវនាការជំនុំជម្រះ៖ សៀវភៅណែនាំយោងសម្រាប់អ្នកប្រតិបត្តិ" (ឆ្នាំ២០០៨), https://tinyurl.com/2p88e64s; គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ "ការសង្កេតការណ៍ការជំនុំជម្រះ" (ឆ្នាំ២០០២), https://tinyurl.com/3a3b3u9r
ម.ស.ម.ក "ក្រមសីលធម៌សង្កេតសវនាការ" https://tinyurl.com/3fxvhxz6

ក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណដល់តុលាការទាំងអស់នូវរាល់កិច្ចសហការនានា និងការផ្ដល់កិច្ចសន្ទនាដ៏មានសារៈសំខាន់នេះ។

លើសពីនេះ សេចក្ដីព្រាងរបាយការណ៍ចុងក្រោយនេះ ក៏ត្រូវបានបញ្ជូនទៅប្រធានតុលាការ និងអគ្គព្រះរាជអាជ្ញាអមតុលាការគោលដៅទាំងអស់ ដើម្បីពិនិត្យផ្ដល់យោបល់ និងអនុសាសន៍។ ម.ស.ម.ក បានទទួលធាតុចូលពីតុលាការក្នុងអំឡុងពេលធ្វើកិច្ចប្រជុំពិគ្រោះយោបល់នៅថ្ងៃទី៥ ខែសីហាឆ្នាំ២០២៥ (សាលាឧទ្ធរណ៍ព្រះសីហនុ), ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ (សាលាឧទ្ធរណ៍បាត់ដំបង), ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥, សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានផ្ដល់ធាតុចូលរបស់ខ្លួនតាមរយៈលិខិតចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៥។ ធាតុចូលរបស់តុលាការទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ ដើម្បីបង្ហាញអំពីការប្រឈមនានាដែលអ្នកជំនាញផ្នែកយុត្តិធម៌កំពុងជួបប្រទះ។ ម.ស.ម.ក ក៏បានផ្ញើសេចក្ដីព្រាងនៃរបាយការណ៍នេះទៅក្រសួងយុត្តិធម៌នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ផងដែរ។

## ២. ទិដ្ឋភាពទូទៅ

ផ្នែកនេះ កំណត់ពីទិន្នន័យដើមដែលបានកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការចំនួន ៥៨២ សំណុំរឿងពីការសង្កេតសវនាការនៅតុលាការចំនួន ៤ នៅចន្លោះថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

*តួលេខទី ១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតក្នុងឆ្នាំ២០២៤*

| *សាលាឧទ្ធរណ៍* | *ភ្នំពេញ* | *បាត់ដំបង* | *ព្រះសីហនុ* | *ត្បូងឃ្មុំ* | *សរុប* |
|---|---|---|---|---|---|
| *ចំនួនសំណុំរឿង* | ២៧៦ | ១៨២ | ៣៦ | ៨៨ | ៥៨២ |
| *ចំនួនបទឧក្រិដ្ឋ*[29] | ១២១ | ៥៨ | ១២ | ២៥ | ២១៦ |
| *ចំនួនបទមជ្ឈិម*[30] | ១៥០ | ១២១ | ២៣ | ៦២ | ៣៥៦ |
| *ចំនួនបទលហុ*[31] | ៥ | ៣ | ១ | ១ | ១០ |
| *ចំនួនជនជាប់ចោទ* | ៣៦៥ | ២៩០ | ៤១ | ១២៦ | ៨២២ |
| *ចំនួនជនជាប់ចោទជាកុមារ* | ១ | ៧ | ០ | ១ | ៩ |
| *ចំនួនជនជាប់ចោទជាស្ត្រី* | ៦០ | ៣៧ | ៣ | ១៣ | ១១៣ |

ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន (មេធាវីការពារ) និងដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ទាំងពីរភាគីទាក់ទងនឹងបញ្ហារដ្ឋប្បវេណី) អាចប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមដែលចេញដោយសាលាដំបូង។[32] តួលេខទី ២ បានបង្ហាញថាភាគីជនជាប់ចោទបានបណ្ដឹងឧទ្ធរណ៍ភាគច្រើន(៨៨%)។

*តួលេខទី ២៖ ភាគីដែលបានប្ដឹងឧទ្ធរណ៍នៅក្នុងសវនាការដែលបានសង្កេត នៅឆ្នាំ២០២៤*[33]




[29] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពីប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៦)។
[30] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ ថ្ងៃ និងរហូតដល់ប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៧)។
[31] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារតិចជាង ឬស្មើប្រាំមួយថ្ងៃ ឬពិន័យជាប្រាក់ប៉ុណ្ណោះ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៨)
[32] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។
[33] ទិន្នន័យនេះ គឺផ្អែកលើចំនួនសំណុំរឿងសរុបដែលត្រូវបានសង្កេតក្នុងឆ្នាំ ២០២៤ (៥៨២)។

តារាងខាងក្រោមនេះ ម.ស.ម.ក បានកំណត់ថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព (ដោយពណ៌បៃតង) និងសិទ្ធិដែលមិនទាន់ត្រូវបានគោរពពេញលេញ (ដោយពណ៌ទឹកក្រូច)។ ចំពោះសញ្ញាព្រួញចង្អុលឡើងលើ (↑) សំដៅលើសិទ្ធិដែលត្រូវបានគោរពលើកដំបូងនៅក្នុងឆ្នាំ២០២៤ ដែលបង្ហាញអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់បើធៀបនឹងរយៈពេលនៃរបាយការណ៍មុន។ រីឯសញ្ញាព្រួញចង្អុលចុះក្រោម (↓) បង្ហាញពីសិទ្ធិដែលត្រូវបានគោរពក្នុងឆ្នាំ២០២៣ ប៉ុន្តែមិនបានគោរពពេញលេញនៅឆ្នាំ២០២៤ ដែលនេះបង្ហាញពីការខកខាននូវការគោរពតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ដូចឆ្នាំកន្លងមក។ ដោយឡែក សម្រាប់ពណ៌ប្រផេះបង្ហាញថា ម.ស.ម.ក មិនអាចប្រមូលទិន្នន័យគ្រប់គ្រាន់ ដើម្បីវាយតម្លៃថាតើសិទ្ធិជាក់លាក់ណាមួយត្រូវបានគោរព ឬយ៉ាងណា។

*តួលេខទី ៣៖ ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗក្នុងឆ្នាំ២០២៤ ដោយតុលាការគោលដៅ*

| សាលាឧទ្ធរណ៍ / សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ | ភ្នំពេញ | បាត់ដំបង | ព្រះសីហនុ | ត្បូងឃ្មុំ |
|---|---|---|---|---|
| សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី | | | | |
| សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ | | | | |
| សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ | | ↑ | | |
| សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ | ↑ | ↑ | ↑ | |
| សិទ្ធិមានវត្តមាននៅពេលសវនាការ | | ↓ | | ↑ |
| សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល | | | | |
| សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស | ↑ | | | |
| សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង | | | | ↑ |
| ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី | ↑ | | | ↑ |
| សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ | | | | |
| សិទ្ធិទទួលបានមេធាវី | | | ↓ | |
| សិទ្ធិមានសេរីភាព | | | | |
| សិទ្ធិបង្ហាញភស្តុតាង | | | | |
| សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ | | | | |

ផ្នែកខាងក្រោមនេះ គឺការវិភាគទៅលើការអនុវត្តរបស់តុលាការពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ គោលបំណងនៃការវិភាគ ជាដំបូង របាយការណ៍ នឹងបង្ហាញអំពីទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពដោយសាលាឧទ្ធរណ៍ទាំងបួន ហើយបន្ទាប់មកបង្ហាញពីការអនុវត្តដែលមិនទាន់បានគោរពពេញលេញនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការនាំងអស់បានគោរព

### ៣.១ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រាប់គ្រាន់ដើម្បីរៀបចំការពារក្តី

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ខ) | មាត្រា ៤៨, ៩៨, ១៤៥, ២៥៩ & ៣១៩ | មាត្រា ២៩ |

ជនណាដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ គួរត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។ រយៈពេល "គ្រប់គ្រាន់ "គឺអាស្រ័យលើកាលៈទេសៈជាក់ស្តែងនៃសំណុំរឿងនីមួយៗ។[34] ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំបានកំណត់ថា ជនជាប់ចោទត្រូវតែមានលទ្ធភាពរៀបចំឱ្យបានត្រឹមត្រូវដើម្បីតតាំងនឹងភស្តុតាងរបស់អយ្យការ ការស៊ើបអង្កេត និងបង្ហាញសាក្សីរបស់ខ្លួន។ នេះជាតួនាទីរបស់មេធាវីការពារក្នុងការស្នើសុំពន្យារពេលសវនាការជំនុំជម្រះ ប្រសិនបើខ្លួនយល់ឃើញថា ពេលវេលាសម្រាប់ការរៀបចំការពារក្តីនោះមិនគ្រប់គ្រាន់។[35]

មធ្យោបាយចាំបាច់សម្រាប់រៀបចំការពារក្តី រួមមានការទទួលបានឯកសារសំណុំរឿង និងភស្តុតាងដើម្បីឱ្យជនជាប់ចោទដឹងច្បាស់អំពីបទចោទប្រកាន់លើពួកគេ ហើយដើម្បីឱ្យពួកគេអាចផ្តល់ការណែនាំគ្រប់ជ្រុងជ្រោយដល់មេធាវីរបស់ខ្លួន។[36] ជាពិសេស រាប់បញ្ចូលទាំងការទទួលបានភស្តុតាងទាំងឡាយដែលព្រះរាជអាជ្ញាគ្រោងនឹងបង្ហាញនៅក្នុងតុលាការ និងភស្តុតាងដោះបន្ទុក។ នៅដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍នេះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេនៅក្នុងការប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង ដែលមានសំអាងហេតុត្រឹមត្រូវ និងកំណត់ហេតុនៃការជំនុំជម្រះ។[37] លើសពីនេះ ជនជាប់ចោទត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយផ្ទាល់។ បទប្បញ្ញត្តិនេះជានានូវការគោរពចំពោះគោលការណ៍ស្មើភាពគ្នា និងតម្រូវឱ្យជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ ព្រមទាំង ត្រូវមានមធ្យោបាយដែលអាចអនុញ្ញាតឱ្យមានទំនាក់ទំនងដោយសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ។[38]

---

[34] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[35] ដូចខាងលើ.

[36] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៣។

[37] ដូចខាងលើ, វាក្យខណ្ឌ ៤៩, សូមមើល [37] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១៧៩៧/២០០៨ រវាង *Mennen* និងប្រទេសហូឡង់ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០), CCPR/C/៩៩/D/១៧៩៧/២០០៨, វាក្យខណ្ឌ ៨.២.-៨.៤, https://tinyurl.com/z2x7tu9e

[38] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣៤ សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/yckvz5

ទោះបីជា ម.ស.ម.ក មិនទទួលបាននូវព័ត៌មានចាំបាច់ទាំងអស់ដែលពាក់ព័ន្ធនឹងការសង្កេតសវនាការលើបណ្តឹងឧទ្ធរណ៍ ដើម្បីវាយតម្លៃថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តី និងទំនាក់ទំនងជាមួយមេធាវីក៏ដោយ ក៏មានព័ត៌មានដែលបង្ហាញថាសិទ្ធិទាំងនេះត្រូវបានគោរពដោយតុលាការគោលដៅទាំងបួនដែរ។ បន្ថែមពីនេះ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោម ៤៥៩ នាក់ (៥៥%) ដែលមេធាវីការពាររបស់ពួកគេត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។

ជនជាប់ចោទភាគច្រើនទទួលបានមេធាវីនៅមុនដំណើរការនីតិវិធីជំនុំជម្រះ ហើយមិនមានសំណុំរឿងណាមួយដែលមេធាវីរបស់ជនជាប់ចោទ បានលើកឡើងពីបញ្ហាកង្វះខាតពេលវេលាក្នុងការរៀបចំការពារក្តីនោះទេ។ ម.ស.ម.ក សាទរចំពោះសាលាឧទ្ធរណ៍ទាំងនោះដែលបានគោរពយ៉ាងខ្ជាប់ខ្ជួននូវសិទ្ធិជួបនិយាយជាមួយមេធាវីរបស់ខ្លួនមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីតាំងពីឆ្នាំ២០១៤។

| | |
|---|---|
| **គ្មានជនជាប់ចោទណាម្នាក់**ដែលមេធាវីរបស់ខ្លួនត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។ | **មិនមានមេធាវីការពារឱ្យជនជាប់ចោទណាមួយ ក្នុងចំណោម ៤៥៩ នាក់** បានលើកពីបញ្ហាកង្វះពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តីនោះទេ។ |

## ៣.២ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣១៧ | មាត្រា ៧ |

សេចក្តីសម្រេចរបស់តុលាការ ត្រូវតែប្រកាសជាសាធារណៈដែលនេះគឺជាមូលដ្ឋានគ្រឹះធានានូវតម្លាភាព និងគណនេយ្យភាព។[39] យោងតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.ន ទោះបីជានៅពេលដែលសាធារណៈជនមិនត្រូវបានឱ្យចូលរួមក្នុងសវនាការក៏ដោយ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុផ្លូវច្បាប់ ត្រូវតែបង្ហាញជាសាធារណៈ។[40] សេចក្តីសម្រេចជាសាធារណៈ ជំរុញឱ្យមានតម្លាភាព និងគណនេយ្យភាព ដែលនាំឱ្យចៅក្រមធ្វើសកម្មភាពដោយភាពហ្មត់ចត់បំផុត និងធានាឱ្យមានការផ្តល់យុត្តិធម៌ដោយស្មើភាព។ វិធាននេះមានការលើកលែងតែមួយចំនួនប៉ុណ្ណោះ ដូចជានៅពេលសេចក្តីសម្រេចមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដើម្បីផលប្រយោជន៍របស់កុមារ។[41]

[39] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/5ssncyyy

[40] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៩។

[41] ដូចខាងលើ.

ក្នុងកំឡុងពេលធ្វើបាយការណ៍នេះ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈត្រូវបានគោរពដោយតុលាការចំនួនបី ក្នុងចំណោមតុលាការទាំងបួន នៅគ្រប់សំណុំរឿងទាំងអស់ដែលបានស្តាប់ (៧៩ ក្នុងចំណោម ៥៨២ សំណុំរឿង)។ ម.ស.ម.ក ស្វាគមន៍ចំពោះសាលាឧទ្ធរណ៍ទាំងនោះបានគោរពយ៉ាងជាប់ជាប្រចាំចំពោះសិទ្ធិនេះចាប់តាំងពីឆ្នាំ ២០១៤ មក។ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក បានស្តាប់សាលដីកាតែចំនួនមួយប៉ុណ្ណោះនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ទោះបីជាសាលដីកានេះត្រូវបានប្រកាសជាសាធារណៈក៏ដោយ ក៏នៅតែមិនអាចវាយតម្លៃថា តើតុលាការបានគោរពសិទ្ធិនេះជាប់ជាប្រចាំ ឬយ៉ាងណា ក្នុងឆ្នាំ២០២៤ ដោយសារខ្វះទិន្នន័យលើសំណុំរឿងចំនួន ៨៧ ផ្សេងទៀតមិនបានស្តាប់។

**ម.ស.ម.ក បានស្តាប់សាលដីកាទាំងអស់ចំនួន ៧៩** ហើយសាលដីកាទាំងនោះត្រូវបានប្រកាស **ជាសាធារណៈ** និង ១ សំណុំរឿងបានប្រកាសជាអសាធារណៈទាក់ទងនឹងកុមារទំនាស់នឹងច្បាប់នៅសាលាឧទ្ធរណ៍បាត់ដំបង។

## ៣.៣ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣) (ក) និង (ប) | មាត្រា ៣២២, ៣២៥, ៣៣០, ៣៣១ និង ៣៩៦ | មាត្រា ៦ និង ៥១ |

ជនជាប់ចោទបទព្រហ្មទណ្ឌ ត្រូវទទួលបានការជូនដំណឹង "ភ្លាមៗ" អំពីប្រភេទនៃបទល្មើសដែលបានចោទប្រកាន់មកលើពួកគេ។ ចៅក្រមមានកាតព្វកិច្ចផ្តល់ការពន្យល់ឱ្យបានគ្រប់គ្រាន់ និងធានាថាជនជាប់ចោទយល់អំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើពួកគេ ធ្វើដូច្នេះ ពួកគេអាចរៀបចំមេធាវីការពារបានត្រឹមត្រូវ។[42] ព័ត៌មានទាក់ទងនឹងការចោទប្រកាន់ ត្រូវតែផ្តល់ជូនភ្លាមៗ នៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានកំណត់ជាសាធារណៈថាជាជនជាប់ចោទ។ ការជូនដំណឹងនេះអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ (លុះត្រាតែមានការបញ្ជាក់ជា

[42] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់" (ខែកញ្ញា ឆ្នាំ២០២២ https://tinyurl.com/5h6ec5vz

លាយលក្ខណ៍អក្សរនៅពេលក្រោយ) ឬជាលាយលក្ខណ៍អក្សរ ដែលព័ត៌មានបង្ហាញទាំងអង្គច្បាប់ និងអង្គហេតុសម្រាប់ជាមូលដ្ឋាននៃការចោទប្រកាន់។[43]

គួរកត់សម្គាល់ថា អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យនៅពេលចាប់ផ្តើមសវនាការរបស់សាលាឧទ្ធរណ៍ ជនជាប់ចោទគួរដឹងច្បាស់ជាមុនអំពីបទចោទប្រកាន់មកលើពួកគេ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមគប្បីរំឭកជនជាប់ចោទអំពីព័ត៌មានទាំងនេះ និងដើម្បីធានាថាជនជាប់ចោទយល់ច្បាស់អំពីព័ត៌មាននេះ ជាពិសេសនៅក្នុងករណីដែលការចោទប្រកាន់អាចមានការផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលឃាត់ខ្លួន/ការចោទប្រកាន់ដំបូង និងការជំនុំជម្រះជាក់ស្តែង។ បន្ថែមពីនេះ មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា វិធានដែលអនុវត្តចំពោះមុខតុលាការដំបូងក៏ត្រូវយកមកអនុវត្តចំពោះមុខសាលាឧទ្ធរណ៍ដែរ។

ម.ស.ម.ក បានកត់ត្រាថាចៅក្រមដែលបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទចំនួន១០០%នៃសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅតាមសាលាឧទ្ធរណ៍ទាំងបួន។ នេះគឺជាវឌ្ឍនភាពដ៏សំខាន់មួយបើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ដែលតួលេខពេលនោះមានចំនួនត្រឹមតែ ៨៨,៦% ប៉ុណ្ណោះ ហើយនៅក្នុងឆ្នាំ២០២២ មានតែ ៥៩,៧%។ ចៅក្រមក៏បានប្រាប់បញ្ជាក់អំពីកាលបរិច្ឆេទនៃបទល្មើស ទីតាំងនៃបទល្មើស មាត្រាច្បាប់ និងភាគីពាក់ព័ន្ធ ជាលទ្ធផល ប្រាប់ពីកាលបរិច្ឆេទបទល្មើសចំនួន ៩៤% ប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើសចំនួន ៩១% មាត្រាច្បាប់ចំនួន ៧០% និងប្រាប់ពីភាគីពាក់ព័ន្ធចំនួន ៩៩%។ តុលាការក៏បានផ្តល់អ្នកបកប្រែដល់ជនជាប់ចោទទាំងអស់ដែលត្រូវការមានចំនួន ១០០% (៣៤ សំណុំរឿង)ផងដែរ។ វិធីសាស្ត្រកំណត់ថាសិទ្ធិនេះត្រូវបានគោរពបើសិនជាភាគរយជារួម៖ ពីការប្រាប់បទប្រកាន់ទាំងអស់ ការប្រាប់ពីទីកន្លែងនៃការប្រព្រឹត្តិបទល្មើស កាលបរិច្ឆេទ មាត្រាច្បាប់ និងភាគីពាក់ព័ន្ធ ទទួលបានចាប់ពី ៨០% ឡើងទៅនោះកំណត់ថាសិទ្ធិនេះត្រូវបានគោរព ដែលខុសពីឆ្នាំមុនៗតម្រូវថាចាប់ពី ៨០% ឡើងទៅក្នុងលក្ខខណ្ឌភាគរយនីមួយៗនៃការប្រាប់បទប្រកាន់ទាំងអស់ ការប្រាប់ពីទីកន្លែងនៃការប្រព្រឹត្តិបទល្មើស កាលបរិច្ឆេទ មាត្រាច្បាប់ និងភាគីពាក់ព័ន្ធ។

## សាលាឧទ្ធរណ៍ភ្នំពេញ

ដូចគ្នានឹងសាលាឧទ្ធរណ៍ទាំងបីផ្សេងទៀតដែរ សាលាឧទ្ធរណ៍ភ្នំពេញក៏បានអានប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ចំនួន១០០% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៤ (២៧៦) ដែលមានការកើនឡើង បើធៀបនឹងឆ្នាំ២០២៣ ដែលតួលេខមានតែ ៨២,១% ហើយបើធៀបនឹងឆ្នាំ២០២២ មានត្រឹមតែ ៤៧,៩% នៃសំណុំរឿងដែលបានសង្កេតប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ចៅក្រមបានអានប្រាប់អំពីមាត្រាច្បាប់ពាក់ព័ន្ធក្នុងសំណុំរឿងដែលបានសង្កេតចំនួន ៥៦% (១៥៥ ក្នុងចំណោម ២៧៦) ដែលថយចុះបើ

[43] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ៦០៩/១៩៩៥, Nathaniel Williams v. និងចាម៉ៃកា *(ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧) CCPR/C/៦១/D/៦០៩/១៩៩៥* ដែលក្នុងនោះគណៈកម្មាធិការបានបញ្ជាក់បន្ថែមថា ព័ត៌មានលម្អិតអំពីការចោទប្រកាន់ត្រូវតែផ្តល់ជូននៅ "ពេលចាប់ផ្តើមការស៊ើបអង្កេតបឋម ឬនៅពេលកំណត់សវនាការមួយចំនួនផ្សេងទៀតដែលនាំទៅដល់ការសង្ស័យជាផ្លូវការយ៉ាងច្បាស់ប្រឆាំងនឹងជនជាប់ចោទ"។

ធៀបនឹងឆ្នាំ២០២៣ មានចំនួនដល់ទៅ ៦១%។ ទោះបីជាយ៉ាងណា សាលាឧទ្ធរណ៍ភ្នំពេញបានអនុវត្តល្អពាក់ព័ន្ធនឹងការអានប្រាប់អំពីកាលបរិច្ឆេទនៃប្រព្រឹត្តិបទល្មើសចំនួន ៩៦% និងភាគីពាក់ព័ន្ធចំនួន ៩៩% ក្នុងឆ្នាំ ២០២៤ ដោយឡែកមានការថយចុះចំពោះការអានប្រាប់ទីកន្លែងនៃការប្រព្រឹត្តបទល្មើសនៅឆ្នាំ២០២៤ មានត្រឹមតែ ៨៨% បើធៀបនឹងឆ្នាំ២០២៣ មានចំនួនដល់ទៅ ៩៤%។ ដូច្នោះ សិទ្ធិនេះត្រូវបានគោរពដោយមានភាគរយរហូតដល់ ៨៧,៨%។

*តួលេខទី ៤៖ ការវិវត្តនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៤)*[44]




## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបង ទទួលនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការគោរពសិទ្ធិយល់ដឹងអំពីប្រភេទនៃការចោទប្រកាន់ដែរ។ ចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទទាំង ១០០% ហើយបើធៀបនឹងឆ្នាំ ២០២៣ មានចំនួនត្រឹមតែ ៨៩% ប៉ុណ្ណោះ។ ចំពោះចៅក្រមដែលបានអាន

[44] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០១៤/២០១៥ សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០១៦/២០១៧ សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០១៧/២០១៨ សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០១៨/២០១៩ សំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០១៩/២០២០ សំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០២១ សំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០២២ សំណុំរឿងចំនួន ៣៣៦ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០២៣ សំណុំរឿងចំនួន ២៧៦ ដែលបានសង្កេតនៅតុលាការនេះនៅឆ្នាំ២០២៤។

ប្រាប់អំពីមាត្រាច្បាប់ដែលពាក់ព័ន្ធកើនឡើងដល់ ៧៧% នៃសំណុំរឿងដែលបានសង្កេត (១៤១ ក្នុងចំណោម ១៨២) បើធៀបនឹងឆ្នាំ២០២៣ មានចំនួនត្រឹមតែ ៦៤%។ ចៅក្រមបានអានប្រាប់អំពីកាលបរិច្ឆេទនៃបទល្មើសចំនួន ៨៩,៥% ទីកន្លែងនៃបទល្មើសចំនួន ៩៤,៥% និងភាគីពាក់ព័ន្ធចំនួន ៩៨,៩%។ ដូចនេះ ការអនុវត្តក្នុងការលើកកម្ពស់សិទ្ធិមានរហូតដល់ ៩១,៩៨%។ ខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងបានអះអាងថា នីតិវិធីសាលាឧទ្ធរណ៍មិនដូចគ្នាជាមួយសាលាដំបូងទេ សាលាឧទ្ធរណ៍ពិនិត្យតែលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ តើជនជាប់ចោទមិនពេញចិត្តត្រង់ចំណុចណានៃសេចក្ដីសម្រេច ឬប្ដឹងសុំបន្ធូរបន្ថយទោស។ ជាទូទៅ សាលាឧទ្ធរណ៍មិនសូវពិនិត្យកស្តុតាងសារជាថ្មីឡើយ ពីព្រោះសាលាដំបូងបានពិនិត្យរួចហើយ។[45]

## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ បានអនុវត្តល្អប្រសើរអំពីការអានប្រាប់ចោទប្រកាន់ពាក់ព័ន្ធទាំងអស់កើនដល់ ១០០% បើធៀបនឹងឆ្នាំ ២០២៣ មានចំនួនត្រឹមតែ ៩៧% ដោយឡែកការអានប្រាប់អំពីមាត្រាច្បាប់ពាក់ព័ន្ធមានការថយចុះជាបន្តបន្ទាប់ពី៧២% នៅឆ្នាំ២០២៤, ៧៦% នៅឆ្នាំ២០២៣ និង ៨៩,៨% នៅឆ្នាំ២០២២។ លើសពីនេះ ក៏មានការថយចុះផងដែរអំពីការអានប្រាប់ពីទីកន្លែងនៃការប្រព្រឹត្តបទល្មើសពីចំនួន ៨៨% នៅឆ្នាំ២០២៣ មកនៅត្រឹមតែ ៨៣% ក្នុងឆ្នាំ២០២៤ រីឯភាគីពាក់ព័ន្ធចំនួន ៩១% និងកាលបរិច្ឆេទនៃការប្រព្រឹត្តិបទល្មើសចំនួន ៨៦%។ ទោះបីជាយ៉ាងណា សិទ្ធិនេះនៅតែស្ថិតក្នុងលំដាប់នៃសិទ្ធិដែលត្រូវបានគោរព ដោយមានភាគរយជារួមរហូតដល់ ៨៦,៤%។

នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមតុលាការ បាននិយាយថា ចៅក្រមស៊ើបសួរគួរអានប្រាប់អំពីបទចោទប្រកាន់ដល់ជនជាប់ចោទបន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនរឿងរបស់ព្រះរាជអាជ្ញា ពោលគឺមិនមែនជាបន្ទុករបស់សាលាឧទ្ធរណ៍ទេ។ តំណាងតុលាការបានលើកឡើងថា ជាធម្មតា ចៅក្រមសាលាឧទ្ធរណ៍ត្រូវអានសំណុំរឿងទាំងមូល និងសេចក្ដីសម្រេចរបស់សាលាដំបូង បន្ទាប់មកចៅក្រម ត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ និងភាគីពាក់ព័ន្ធ មុនសួរថាតើផ្នែកណាមួយនៃសាលក្រមរបស់សាលាដំបូងដែលខ្លួនប្ដឹងជំទាស់ និងមូលហេតុ។ ជាទូទៅ ជនជាប់ចោទបដិសេធថាខ្លួនមិនបានប្រព្រឹត្របទល្មើស ឬលើកឡើងថាការផ្តន្ទាទោសនោះគឺធ្ងន់ធ្ងរពេក។ ដូច្នេះហើយ មិនចាំបាច់តម្រូវឱ្យចៅក្រមត្រូវអានប្រាប់ និងពន្យល់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នោះទេ។ ទោះជាយ៉ាងនេះក្ដី តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ថ្លែងថា ចៅក្រមនឹងអានប្រាប់ព្រមទាំងពន្យល់ដល់ជនជាប់ចោទ លុះត្រាណាតែជនជាប់ចោទនិយាយថា ខ្លួនមិនយល់អំពីបទចោទប្រកាន់លើ

[45] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ពួកគេ។[46] ដូច្នេះ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ណែនាំឱ្យ ម.ស.ម.ក ពិចារណាលើការវាស់វែងចំពោះសិទ្ធិដែលអនុវត្តនៅសាលាឧទ្ធរណ៍បានហើយ ពីព្រោះថាសិទ្ធិមួយចំនួនដែលសាលាឧទ្ធរណ៍មិនបានប្រាប់នោះ គឺដោយសារសាលាដំបូងបានប្រាប់រួចទៅហើយ ដូចនេះ ជនជាប់ចោទបានយល់ដឹងអំពីសិទ្ធិទាំងនេះរួចហើយ។[47]

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

ចំពោះសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអនុវត្តល្អប្រសើរក្នុងការគោរពសិទ្ធិជនជាប់ចោទពាក់ព័ន្ធនឹងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។ សិទ្ធិនេះត្រូវបានធានាជាប់ៗគ្នាបីឆ្នាំ ដោយសាលាឧទ្ធរណ៍ត្បូងឃ្មុំក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន។ តុលាការនេះរក្សានូវការលើកកម្ពស់សិទ្ធិនេះបាន ១០០% ថាចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់។ ការអានប្រាប់អំពីច្បាប់ពាក់ព័ន្ធនេះ សាលាឧទ្ធរណ៍ត្បូងឃ្មុំអនុវត្តបានល្អប្រសើរជាងតុលាការផ្សេងទៀត ដែលជាលទ្ធផលមានចំនួនដល់ ៩៦,៥% ទោះបីជាយ៉ាងនេះក្តី តួលេខនេះមានការថយចុះបន្តិច បើធៀបនឹងឆ្នាំមុន ដែលចៅក្រមបានអានប្រាប់ពីច្បាប់ពាក់ព័ន្ធបានរហូតដល់ ១០០% នៃសំណុំរឿងដែលបានសង្កេត។ ដូចនេះ តុលាការ គួររក្សាតួលេខដ៏ប្រសើរនេះ និងជៀសវាងការថយចុះ។ តុលាការនេះបានអនុវត្តល្អប្រសើរលើការអានប្រាប់អំពីកាលបរិច្ឆេទនៃការប្រព្រឹត្តិបទល្មើសចំនួន៩៩% ទីកន្លែងនៃបទល្មើសចំនួន ៩៦,៥% និងភាគីពាក់ព័ន្ធចំនួន ៩៩%។ ដូចនេះ ការអនុវត្តក្នុងការលើកកម្ពស់សិទ្ធិនេះមានដល់ ៩៨,២% ដែលជាតួលេខខ្ពស់ជាងគេ។

*តួលេខទី ៥៖ សិទ្ធិក្នុងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅតាមតុលាការគោលដៅ*[48]




---

[46] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[47] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញពីរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[48] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០២៤

# ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការមួយចំនួនបានគោរព

## ៤.១ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣៩២ | មាត្រា ៧ |

ជនគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានពិរុទ្ធភាព ឬគ្មានទោស នៅក្នុងការជំនុំជម្រះជាសាធារណៈ។[49] ករណីលើកលែងតែសវនាការសាធារណៈនោះអាចបង្ក "ការប៉ះពាល់យ៉ាងច្បាស់" ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬសីលធម៌ ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី (ជាពិសេស ក្នុងសំណុំរឿងរំលោភផ្លូវភេទមួយចំនួន) ឬវត្តមានកុមារដែលទំនាស់នឹងច្បាប់។ [50] ក្នុងករណីទាំងនេះ ការកាត់ក្តីនឹងប្រព្រឹត្តទៅដោយអសាធារណៈ។

*ការជានានៅក្នុងករណីនៃសវនាការអសាធារណៈ*

ទោះបីជាសាធារណជនទាំងអស់ ឬសាធារណជនមួយចំនួនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការដោយសារកាលៈទេសៈពិសេសក៏ដោយ ក៏សាធារណភាពនៅតែជានាការពារឱ្យមានដដែលផងដែរ។ ក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុផ្លូវច្បាប់ ត្រូវតែធ្វើឡើងជាសាធារណៈ។ [51] មានតែក្នុងករណីមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍៖ ប្រសិនបើមានភាពចាំបាច់ដើម្បីជាប្រយោជន៍របស់កុមារ) ទើបមានការលើកលែងចំពោះការជានានូវសាធារណភាពនេះ។

មានតែក្នុងកាលៈទេសៈពិសេសដែលច្បាប់កំណត់ប៉ុណ្ណោះ ទើបសាធារណជនទាំងអស់ ឬមួយផ្នែកមិនអាចត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការបាន។ [52] នៅក្នុងកាលៈទេសៈផ្សេងទៀត សវនាការត្រូវតែធ្វើឡើងជាសាធារណៈដោយរាប់បញ្ចូលទាំងសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយផងដែរ ហើយមិនគួរមានក្រុមមនុស្សជាក់លាក់ណាមួយត្រូវបានផាត់ចេញឡើយ។ [53] ជាផ្នែកមួយនៃសិទ្ធិនេះ តុលាការមានកាតព្វកិច្ចផ្សព្វផ្សាយព័ត៌មានអំពីពេលវេលា និងទីកន្លែងនៃសវនាការជាសាធារណៈ និងផ្តល់មធ្យោបាយគ្រប់គ្រាន់ក្នុងកម្រិតសមរម្យ

---

[49] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/2c67u8sn

[50] គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (អ.ស.ក) សេចក្តីពន្យល់ទូទៅលេខ ២៤ ស្តីពីសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៩) អ.ស.ក/C/GC/២៤ វាក្យខណ្ឌ ៦៧ https://tinyurl.com/2s4kka66

[51] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[52] ដូចខាងលើ.

[53] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

សម្រាប់សាធារណជនបានចូលរួម។[54] គួរមានការធានាថា សាធារណជន និងអ្នកសារព័ត៌មានដែលចង់ចូលរួមសវនាការដែលធ្វើឡើងជាសាធារណៈ មិនចាំបាច់មានការសួរនាំអំពីហេតុផលនៃការចូលរួមនោះទេ និងការតម្រូវឱ្យមានការចុះឈ្មោះចូលរួមសវនាការគួរតែជៀសវាងនៅគ្រប់ករណីទាំងអស់។

*តួលេខទី ៦៖ ភាគរយនៃសំណុំរឿងដែលមានការបិទផ្សាយកាលវិភាគសវនាការសរុប*[55]




ការបិទផ្សាយកាលវិភាគសវនាការដែលបង្ហាញអំពីកាលបរិច្ឆេទ ទីតាំង និងពេលវេលាចាប់ផ្តើមសវនាការនៅខាងក្រៅបន្ទប់សវនាការ ឬផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត គឺជាមធ្យោបាយដ៏សំខាន់មួយ ក្នុងការធានានូវការជំនុំជម្រះជាសាធារណៈ និងផ្តល់ព័ត៌មានដល់សាធារណជន និងជួយសម្រួលដល់ការចូលទៅកាន់បន្ទប់សវនាការដែលត្រូវជំនុំជម្រះនោះ។ ចំពោះការបន្តអនុវត្តរយៈពេល២ឆ្នាំមកនេះ មិនមានការបង្ហាញថាសាធារណជន ឬអ្នកសារព័ត៌មានត្រូវបានរារាំងក្នុងការចូល ឬបណ្តេញចេញពីបន្ទប់សវនាការនោះទេ ក្នុងចំណោមសំណុំរឿងដែលត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍ទាំងបួនក្នុងឆ្នាំ២០២៤។ សវនាការនៃសំណុំរឿងចំនួន ៨៨% ដែល ម.ស.ម.ក បានសង្កេត (៥១២ ក្នុងចំណោម ៥៨២) មានការបិទផ្សាយកាលវិភាគសវនាការនៅខាងក្រៅបន្ទប់សវនាការ និង/ឬបង្ហោះតាមអនឡាញ។ តួលេខនេះគឺជាចំនួនកើនឡើងបើធៀបនឹងឆ្នាំ២០២៣ ដែលមានត្រឹមតែ ៨៤% នៃសវនាការដែលបានសង្កេតប៉ុណ្ណោះ។ ទោះបីនេះជាវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលសាលាឧទ្ធរណ៍បាត់ដំបងបានធានាសិទ្ធិនេះជាលើកដំបូង យ៉ាងនេះក្តី ក៏សិទ្ធិនេះមិនត្រូវបានគោរពយ៉ាងពេញលេញនៅឡើយ ដោយហេតុថាសាលាឧទ្ធរណ៍ព្រះសីហនុមិនទាន់បានធានាសិទ្ធិនេះពេញលេញនោះទេ។

## សាលាឧទ្ធរណ៍ភ្នំពេញ

នៅក្នុងឆ្នាំ២០១៨ និង ២០១៩ សាលាឧទ្ធរណ៍ភ្នំពេញបានទទួលស្គាល់អំពីកង្វះខាតនៃការបិទផ្សាយកាលវិភាគសវនាការហើយបានជូនដំណឹងដល់ ម.ស.ម.ក ថាខ្លួននឹងចាត់វិធានការ ដើម្បីពង្រឹងការផ្សព្វផ្សាយព័ត៌មានអំពីកាលវិភាគសវនាការដល់សាធារណជន និងងាយស្រួលចូលរួមក្នុងដំណើរការសវនាការ។[56]

---

[54] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ២១៥/១៩៨៦, *រវាង* Van Meurs *និងប្រទេសហូឡង់ (ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០)* CCPR/C/៣៩/D/២១៥/១៩៨៦, វាក្យខណ្ឌ ៦.២, https://tinyurl.com/2nc55r5f

[55] ទិន្នន័យនេះ ផ្អែកលើសំណុំរឿងសរុបចំនួន ៥៨២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៤។

[56] នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើការរកឃើញដែលមាននៅក្នុងឆ្នាំ២០១៦/២០១៧ និងរបាយការណ៍ឆ្នាំ២០១៧/២០១៨។

*តួលេខទី ៧៖ ភាគរយនៃសំណុំរឿងដែលមានការបិទផ្សាយកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ*[57]




តុលាការបានបញ្ជាក់ថាការបង្ហាញកាលវិភាគសវនាការជាសាធារណៈ គឺជាកិច្ចការរដ្ឋបាល ហើយមិនមែនជាលក្ខខណ្ឌតម្រូវដោយច្បាប់នោះទេ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានផ្តល់អាទិភាពលើកិច្ចការនេះ និងបង្កើតគេហទំព័រ ដើម្បីបង្ហោះផ្សាយព័ត៌មានអំពីសំណុំរឿងដែលនឹងត្រូវសវនាការនាពេលខាងមុខ ក៏ដូចជាកាលវិភាគសវនាការ ផងដែរ។ ព័ត៌មានទាំងនោះ រួមមាន កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសវនាការ លេខសំណុំរឿង បទចោទប្រកាន់ និងឈ្មោះរបស់ចៅក្រម។

សាលាឧទ្ធរណ៍ភ្នំពេញ បានបិទផ្សាយកាលវិភាគសវនាការរបស់ខ្លួនមានចំនួន ៨៨% (២៤២ ក្នុងចំណោម ២៧៦) នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៤ ពោលគឺមានការថយចុះពី ៩៥% ក្នុងឆ្នាំ២០២៣។ ជាពិសេស ចំណុចប្រសើរគួរកត់សម្គាល់នោះគឺថាសំណុំរឿងចំនួន ៦១% (១៦៨ ក្នុងចំណោម ២៧៦) ត្រូវបានផ្សព្វផ្សាយតាមបណ្តាញអ៊ីនធឺណិត និងលើក្តារខៀនព័ត៌មានជាសាធារណៈ។ នេះជាវឌ្ឍនភាពល្អ បើធៀបនឹងឆ្នាំ២០២៣ ដែលការអនុវត្តពេលនោះមានត្រឹម ៤៩% %នៃសំណុំរឿងប៉ុណ្ណោះ។ ការបិទផ្សាយកាលវិភាគសវនាការនេះមានការថយចុះបន្តិច ដូច្នេះ តុលាការគួរអនុវត្តឱ្យកាន់តែប្រសើរជាងនេះដែលអនុលោមទៅតាមគោលការណ៍អនុវត្តល្អបំផុត។ ហេតុនេះ គួរតែបន្តការខិតខំបន្ថែមទៀតលើការលើកកម្ពស់សិទ្ធិនេះ។ ក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយតំណាងតុលាការ ម.ស.ម.ក បានលើកឡើងអំពីចំណុចដែលថា ជារឿយៗកាលវិភាគសវនាការដែលបានបិទនៅលើក្តារខៀនព័ត៌មាននោះ គឺជាន់ពីលើគ្នា ដែលធ្វើឱ្យអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក មិនអាចទទួលបានកាលវិភាគសវនាការនោះបានពេញលេញនោះទេ។ ជាការឆ្លើយតប តំណាងតុលាការបាននិយាយថា ចំពោះកិច្ចការនេះនឹងត្រូវពិនិត្យឡើងវិញ ថាតើក្តារខៀនព័ត៌មាន គួរនឹងពង្រីកទំហំ ឬយ៉ាងណា។[58] តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានគូសបញ្ជាក់ថាការដែលតម្រូវឱ្យមានការចុះឈ្មោះពេលចូលស្តាប់សវនាការ ដើម្បីធានាបាននូវសណ្តាប់ធ្នាប់មុនពេល និងក្នុងពេលសវនាការ ជាពិសេសសភាពចង្អៀតណែន ដែលបន្ទប់សវនាការនីមួយៗផ្ទុកចំនួនសាធារណៈចូលរួមមានកំណត់។[59]

---

[57] ទិន្នន័យនេះ ផ្អែកលើចំនួនសំណុំរឿងចំនួន ២៧៦ ដែលត្រូវបានសង្កេតនៅតុលាការនេះក្នុងឆ្នាំ២០២៤។

[58] នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[59] លិខិតលេខ ៩២៩ បេឧ/២៥ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ដោយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីឆ្លើយតបនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២៤ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

*តួលេខទី ៨៖ ការវិវត្តជាភាគរយនៃសំណុំរឿងដែលកាលវិភាគសវនាការត្រូវបានបិទផ្សាយនៅខាងក្រៅបន្ទប់សវនាការ (រហូតដល់ឆ្នាំ២០២២) និងនៅខាងក្រៅបន្ទប់សវនាការ ឬតាមអ៊ីនធឺណិត (ពីឆ្នាំ២០២២) នៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០២៤)*[60]




## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបង មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈនៅក្នុងឆ្នាំ២០២៤។ ជាក់ស្តែង តុលាការបានផ្សព្វផ្សាយកាលវិភាគសវនាការទាំងតាមអនឡាញ ឬក្តារខៀនព័ត៌មានរហូតដល់ ៩៣% នៃសំណុំរឿង (១៦៩ ក្នុងចំណោម ១៨២)។ នេះជាការអនុវត្តដ៏ប្រសើរបើធៀបនឹងឆ្នាំ២០២៣ ដែលមានត្រឹម ៧៥,១% ប៉ុណ្ណោះ ដែល ម.ស.ម.ក បានចាត់ទុកថាសិទ្ធិនោះមិនត្រូវបានគោរពដោយតុលាការនោះទេ។ មួយវិញទៀត សាលាឧទ្ធរណ៍បាត់ដំបងក៏បានផ្សព្វផ្សាយកម្មវិធីសវនាការរបស់ខ្លួន ទាំងតាមរយៈអ៊ីនធឺណិត និងនៅលើក្តារខៀនព័ត៌មាន មានចំនួន៧០%នៃសំណុំរឿង (១២៧ ក្នុងចំណោម ១៨២) ដោយកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានត្រឹមតែ ៤៣% ប៉ុណ្ណោះ។

ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថាតុលាការនឹងបិទផ្សាយកាលវិភាគសវនាការឱ្យបានទៀងទាត់ ហើយជាលទ្ធផលឆ្នាំ២០២៤ តុលាការបានសម្រេចដូចទិន្នន័យបង្ហាញខាងលើ។[61]សាលាឧទ្ធរណ៍បាត់ដំបងបានលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

[60] ទិន្នន័យនេះ គឺផ្អែកលើសំណុំរឿងសរុបចំនួន ១២៨ ដែលបានសង្កេតនៅក្នុងឆ្នាំ២០១៤/២០១៥, សំណុំរឿងសរុបចំនួន ៣៤០ ដែលបានសង្កេតនៅក្នុងឆ្នាំ២០១៦/២០១៧ សំណុំរឿងសរុបចំនួន ២១៣ ដែលបានសង្កេតនៅក្នុងឆ្នាំ២០១៧/២០១៨ សំណុំរឿងសរុបចំនួន ២៣៩ ដែលបានសង្កេតនៅក្នុងឆ្នាំ២០១៨/២០១៩ សំណុំរឿងសរុបចំនួន ២០៣ ដែលបានសង្កេតនៅក្នុងឆ្នាំ២០១៩/២០២០ សំណុំរឿងសរុបចំនួន ៨៥ ដែលបានសង្កេតនៅក្នុងឆ្នាំ២០២១ សំណុំរឿងសរុបចំនួន ២៥៧ ករណីដែលបានសង្កេតនៅក្នុងឆ្នាំ២០២២ សំណុំរឿងសរុបចំនួន ៣៣៦ ដែលបានសង្កេតនៅក្នុងឆ្នាំ២០២៣ និងសំណុំរឿងសរុបចំនួន ២៧៦ ដែលបានសង្កេតនៅក្នុងឆ្នាំ២០២៤។

[61] ម.ស.ម.ក បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយតំណាងតុលាការនៃសាលាឧទ្ធរណ៍បាត់ដំបងកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤។

យ៉ាងល្អប្រសើរនៅឆ្នាំ២០២២ តាមរយៈការបិទផ្សាយកាលវិភាគសវនាការមានចំនួនរហូតដល់ ៩៣.៧% (១៣៤ ក្នុងចំណោម ១៤៣) នៃសំណុំរឿងដែលបានសង្កេត ដូចនេះ ភាពល្អប្រសើរបែបហ្នឹង គួរត្រូវបានរក្សា។

*តួលេខទី ៩៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង*[62]




## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ គឺជាតុលាការគោលដៅតែមួយគត់ក្នុងចំណោមតុលាការទាំងបួន ដែលមិនទាន់គោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយសាធារណៈ ហើយមានវឌ្ឍនភាពតិចតួចចាប់តាំងពីឆ្នាំ២០២៣ ។ ការផ្សព្វផ្សាយកាលវិភាគសវនាការតាមប្រព័ន្ធអ៊ីនធឺណិត ឬនៅលើក្ដារខៀនព័ត៌មាន គឺមានត្រឹមតែ ៣៦% នៃសំណុំរឿង (១៣ ក្នុងចំណោម ៣៦) ប៉ុណ្ណោះ ដែលនេះបង្ហាញការថយចុះបន្តិចពី ៣៧% ក្នុងឆ្នាំ២០២៣។ ស្រដៀងទៅនឹងឆ្នាំមុនៗដែរ តុលាការបានបិទផ្សាយកម្មវិធីសវនាការតែលើក្ដារខៀនព័ត៌មានតែប៉ុណ្ណោះ ដោយមិនបានបង្ហោះតាមអ៊ីនធឺណិតនោះទេ។ ការបង្ហោះកម្មវិធីសវនាការតាមអ៊ីនធឺណិតមិនត្រឹមតែងាយស្រួលជាងការបិទលើក្ដារខៀនព័ត៌មានសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្ដល់ភាពងាយស្រួលដល់អ្នកពាក់ព័ន្ធ ឬសាធារណជនអាចទទួលព័ត៌មានទាំងនេះផងដែរមិនចាំបាច់ធ្វើដំណើរទៅតុលាការនោះឡើយ។

*តួលេខទី ១០៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ព្រះសីហនុ*[63]




របកគំហើញនេះ បានបង្ហាញថាសាលាឧទ្ធរណ៍ព្រះសីហនុគួរខិតខំបន្តទៀត ដើម្បីធ្វើការផ្សព្វផ្សាយកាលវិភាគសវនាការឱ្យបានទៀងទាត់ និងផ្ដោតជាពិសេសតាមរយៈតាមអនឡាញផងដែរ។ នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក តំណាងតុលាការបានអះអាងថាការបិទផ្សាយកាលវិភាគសវនា

[62] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១៨២ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ២០២៤។

[63] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៣៦ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ២០២៤។

ការនេះគឺជាកិច្ចការរដ្ឋបាល មិនមែនកំណត់ដោយច្បាប់នោះទេ។[64] នៅខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ បានលើកឡើងថា ការបិទកម្មវិធីសវនាការនេះនៅមានភាពចម្រូងចម្រាសនៅឡើយ ពីព្រោះថានៅពេលឈ្មោះរបស់ជនជាប់ចោទត្រូវបានផ្សព្វផ្សាយជាសាធារណៈ គឺវាអាចប៉ះពាល់សិទ្ធិរបស់គេ និងអាចនាំឱ្យមានការរើសអើងពីសហគមន៍របស់គេ ដោយហេតុថាពេលខ្លះពលរដ្ឋមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ពាក្យពេចន៍ ដូចជា ជនជាប់ចោទ និងទណ្ឌិតនៅឡើយ។[65]

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

*តួលេខទី ១១៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ*[66]




ចំពោះសាលាឧទ្ធរណ៍ត្បូងឃ្មុំ រក្សាបាននូវការផ្សព្វផ្សាយកាលវិភាគសវនាការរបស់ខ្លួនជាសាធារណៈទាំងនៅលើអនឡាញ ឬនៅលើក្តារខៀនព័ត៌មានរហូតដល់១០០% នៃសំណុំរឿងចំនួន ៨៨ ដែល ម.ស.ម.ក បានសង្កេតនៅក្នុងឆ្នាំ២០២៤ ដែលនេះ បានបង្ហាញថា តុលាការនេះបានអនុវត្តល្អបំផុត ក្នុងចំណោមតុលាការគោលដៅទាំងបួនពាក់ព័ន្ធនឹងការគោរពសិទ្ធិនេះ។ នេះគឺ២ឆ្នាំជាប់ៗគ្នាហើយដែលតុលាការនេះ សម្រេចបាននូវលទ្ធផលបែបនេះ ហើយក៏ជាឆ្នាំទី៣ជាប់ៗគ្នាដែរ ដែលតុលាការនេះបានគោរពសិទ្ធិនេះ។ តុលាការបានបន្តរក្សានូវភាពប្រសើរនេះជាប់ជានិច្ច ហើយដែលកើនឡើងនូវចំនួនបិទផ្សាយកាលវិភាគសវនាការទាំងទាំងតាមអនឡាញ និងនៅលើក្តារខៀនព័ត៌មានពី ៦២% ក្នុងឆ្នាំ២០២៣ ដល់ ៧៣% ឆ្នាំ២០២៤ ប្រសិនបើការផ្សព្វផ្សាយនេះអាចធ្វើឡើងបានត្រឹមតែមួយរបៀប នោះការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត/អនឡាញត្រូវបានជាជម្រើសល្អ មិនគួរមានត្រឹមតែបិទផ្សាយលើក្តារខៀនព័ត៌មាននោះទេ។

---

[64] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ របាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា (ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣) (ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤) ទំព័រ ២៤។ https://tinyurl.com/ម.ស.ម.ក-FTR-report-2023

[65] នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[66] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៨៨ ដែលបានសង្កេតនៅតុលាការនេះនៅក្នុងឆ្នាំ ២០២៤។

## ៤.២ សិទ្ធិមានវត្តមាននៅពេលសវនាការ[67]

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ច្បាប់ស្តីពីពន្ធនាគារ[68] |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ៣០០ | មាត្រា ៦ និង ៥១ | មាត្រា ៦២ |

ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ ដោយសារតែការធ្វើបែបនេះផ្តល់ឱកាសឱ្យពួកគេបានស្តាប់ និងឆ្លើយតបទៅនឹងភស្តុតាងដែលដាក់បន្ទុកលើពួកគេ និងអាចការពារខ្លួនបាន។[69] នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារ សវនាការត្រូវមានវត្តមាន "មេធាវី ឬជំនួយការផ្នែកច្បាប់សមស្របផ្សេងទៀត" និងវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ឬអ្នកមើលថែផ្សេងទៀត លុះត្រាតែមានការរកឃើញថាប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់កុមារ ឬតាមការស្នើសុំមិនចូលរួមសវនាការរបស់កុមារ។ [70]

សិទ្ធិមានវត្តមាននៅពេលសវនាការ អាចអនុវត្តបានចំពោះដំណើរបណ្តឹងឧទ្ធរណ៍ ប្រសិនបើពាក់ព័ន្ធនឹងបញ្ហានៃអង្គហេតុ និងអង្គច្បាប់[71] ដែលជាករណីកើតឡើងនៅកម្ពុជា។ ការជំនុំជម្រះដោយកំបាំងមុខ ពោលគឺអវត្តមានជនជាប់ចោទ គឺអាចអនុញ្ញាតបានតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងកាលៈទេសៈពិសេស និងនៅពេលដែលជាប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ[72]។ ទោះជាយ៉ាងនេះក្តី យុត្តិកម្មច្បាស់លាស់ត្រូវតែផ្តល់ជូនសម្រាប់ពួកគេ ហើយជនជាប់ចោទក៏អាចលះបង់សិទ្ធិមានវត្តមានក្នុងសវនាការបានផងដែរ។[73]

នៅក្នុងឆ្នាំ២០២៤ ជនជាប់ចោទ ៨៨% (៧២១នាក់ ក្នុងចំណោម ៨២២ នាក់) មានវត្តមាននៅក្នុងសវនាការដែលបានសង្កេត តួលេខនេះមានការកើនឡើងបើធៀបនឹងឆ្នាំ២០២៣ ដែលមានត្រឹមតែ ៨១,៦%។ សាលាឧទ្ធរណ៍ចំនួនបីក្នុងចំណោមបួន បានគោរពនូវសិទ្ធិមានវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដោយឡែកសាលាឧទ្ធរណ៍បាត់ដំបងមិនទាន់សម្រេចបានចំនួន ៨០%

[67] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមានវត្តមានពេលសវនាការ និងសិទ្ធិការពារខ្លួនឯងដោយផ្ទាល់ ឬតាមរយៈតំណាងផ្លូវច្បាប់" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/ytxdtkt4
[68] ច្បាប់ស្តីពីពន្ធនាគារ (ឆ្នាំ២០១១) https://tinyurl.com/37eyeh3t
[69] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ឃ)
គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣៦
[70] គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅ ២៤ វាក្យខណ្ឌ ៦៣, ៥៦
[71] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣៨៧/១៩៨៩, Karttunen ទល់នឹងប្រទេសហ្វាំងឡង់ (ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩២) CCPR/C/៤៦/D/៣៨៧/១៩៨៩, វាក្យខណ្ឌ ៧.៣ https://tinyurl.com/267vaeud
[72] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣៦
[73] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ០១៦/១៩៧៧, Mbenge ទល់នឹងប្រទេសហ្សៀ (ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣) CCPR/C/១៨/D/១៦/១៩៧៧ វាក្យខណ្ឌ ១៤.១, https://tinyurl.com/2e7vba3k

នោះទេ ដែលជាចាត់ថ្នាក់ថាសិទ្ធិនេះត្រូវបានគោរព។ ជាទូទៅ នេះគឺជាជំហានដ៏គួរឱ្យសាទរចំពោះការវិវឌ្ឍជាវិជ្ជមានសម្រាប់តុលាការគោលដៅ។

*តួលេខទី ១២៖ ភាគរយនៃសំណុំរឿងដែលជនជាប់ចោទមានវត្តមាននៅក្នុងសវនាការនៅតាមតុលាការគោលដៅ*[74]




## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញបានគោរពនូវសិទ្ធិមានវត្តមានក្នុងសវនាការជាទៀងទាត់ ចាប់តាំងពីឆ្នាំ២០១៧/២០១៨។ នៅឆ្នាំ២០២៤ ភាគរយនៃជនជាប់ចោទដែលមានវត្តមាននៅពេលសវនាការបានកើនឡើងដល់ ៩៤% (៣៤៣ ក្នុងចំណោម ៣៦៥)បើធៀបនឹងឆ្នាំ ២០២៣ មានត្រឹមតែ ៨១%។ តួលេខនេះ បង្ហាញអំពីលទ្ធផលគួរឱ្យកោតសរសើរក្នុងការត្រឡប់ទៅរកភាពល្អប្រសើរវិញ មិនតែប៉ុណ្ណោះ សាលាឧទ្ធរណ៍ភ្នំពេញក៏បានអនុវត្តល្អក្នុងការលើកកម្ពស់សិទ្ធិនេះរហូតដល់ចំនួន ៩០,២% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០១៩-២០២០។

នេះជាការវិវឌ្ឍគួរឱ្យកត់សម្គាល់នេះ ដោយសារកន្លងមកមានការលើកឡើងថាអវត្តមានរបស់ជនជាប់ចោទ ជារឿយៗតែងតែកើតមានដោយសារបញ្ហាកស្តុភារ បញ្ហាទំនាក់ទំនងរវាងតុលាការ និងមណ្ឌលអប់រំកែប្រែ ត្រូវបានដោះស្រាយតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់សាលាឧទ្ធរណ៍។ នៅក្នុងសំណុំរឿងមុនៗជាច្រើន គឺមិនមានការដឹកជញ្ជូនជនជាប់ចោទមកជូនតុលាការនោះ ដោយសារតែតុលាការបានបញ្ជូនព័ត៌មានទៅខុសមណ្ឌលអប់រំកែប្រែ ឬដោយសារតែមណ្ឌលអប់រំកែប្រែមិនបានផ្ដល់ព័ត៌មានបច្ចុប្បន្នភាពដល់តុលាការអំពីការផ្ទេរជនជាប់ឃុំទៅមណ្ឌលអប់រំកែប្រែផ្សេងទៀត។ បញ្ហានេះចាំបាច់ត្រូវដោះស្រាយតាមរយៈការកែលម្អការធ្វើកំណត់ត្រា និងទំនាក់ទំនងរវាងតុលាការ និងមណ្ឌលអប់រំកែប្រែ។ តាមរយៈការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តុលាការក៏បានពន្យល់ផងដែរថា តុលាការក៏អាចបើកសវនាការលើសំណុំរឿងដោយគ្មានវត្តមានរបស់ជនជាប់ចោទបាន ប្រសិនបើមេធាវីរបស់ពួកគេមានវត្តមាន ប្រសិនបើបណ្ដឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាមិនត្រឹម

[74] ទិន្នន័យនេះ គឺផ្អែកទៅលើចំនួនជនជាប់ចោទសរុប (៨២២ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតក្នុងឆ្នាំ២០២៤។

ត្រូវ ប្រសិនបើបណ្ដឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងដោយអយ្យការ ឬប្រសិនបើសំណុំរឿងកកស្ទះនៅតុលាការអស់រយៈពេលយូរ ហើយភាគីស្នើសុំឱ្យចៅក្រមជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ។[75]

*តួលេខទី ១៣៖ ការវិវឌ្ឍន៍នៃសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០២៤)*[76]

| តើជនជាប់ចោទមានវត្តមានពេលសវនាការដែរ ឬទេ? | មាន | គ្មាន |
|---|---|---|
| ២០១៤/២០១៥ | ៧៩% | ២១% |
| ២០១៦/២០១៧ | ៧២,៤% | ២៧,៦% |
| ២០១៧/២០១៨ | ៨២,៥% | ១៧,៥% |
| ២០១៨/២០១៩ | ៨០,៧% | ១៩,៣% |
| ២០១៩/២០២០ | ៩០,២% | ៩,៨% |
| ២០២១ | ៨៣,១% | ១៦,៩% |
| ២០២២ | ៨១,៨% | ១៨,២% |
| ២០២៣ | ៨១,៥% | ១៨,៥% |
| ២០២៤ | ៩៤% | ៦% |

## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបង បន្តមានការថយចុះនូវការគោរពសិទ្ធិមានវត្តមាននៅសវនាការរបស់ជនជាប់ចោទពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៣ លើសពីនេះក៏មានការថយចុះបន្ថែមទៀតចំពោះការធានាសិទ្ធិមានវត្តមាន

---

[75] លិខិតលេខ ៤៣២/២១ ចេញថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក ស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[76] ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ១២៩ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០១៤/២០១៥, ជនជាប់ចោទចំនួន ៤០៤ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៥៥៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៦០ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០១៧/២០១៨ ជនជាប់ចោទចំនួន ២៨៤ នាក់ ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០១៨/២០១៩, ជនជាប់ចោទចំនួន ២៣០ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០១៩/២០២០, ជនជាប់ចោទចំនួន ៩៨ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១១៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅក្នុងឆ្នាំ២០២១, ជនជាប់ចោទចំនួន ២៨៨ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០២២, ជនជាប់ចោទចំនួន ៣៧៥ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៤៦០ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៣៦ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០២៣ និងជនជាប់ចោទចំនួន ៣៤៣ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៦៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៧៦ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០២៤។

របស់ជនជាប់ចោទនៅពេលសវនាការក្នុងឆ្នាំ២០២៤ ដែរ។ ក្នុងអំឡុងនៃការធ្វើរបាយការណ៍នេះ ជនជាប់ចោទមានវត្តមានពេលសវនាការមាន ៧៧% នៃសវនាការដែលបានសង្កេត (២២៤ ក្នុងចំណោម ២៩០ នាក់) ដែលថយចុះ បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨២% និងឆ្នាំ២០២២ មានដល់ ៩១%។ ការថយចុះដែលគួរឱ្យកត់សម្គាល់ដែលស្ថិតនៅក្រោម ៨០% ជាចំណាត់ថ្នាក់ថា មិនទាន់បានការគោរពពេញលេញនូវសិទ្ធិមានវត្តមានពេលសវនាការ។នៅក្នុងឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការបានមានប្រសាសន៍ថា តុលាការនឹងចាត់វិធានការលើបញ្ហានេះយ៉ាងម៉ឺងម៉ាត់ ដោយសារតែវត្តមានរបស់ជនជាប់ចោទក្នុងសវនាការ គឺជាធាតុផ្សំដ៏ចម្បងមួយនៃលទ្ធភាពទទួលបានយុត្តិធម៌ និងថាតុលាការតម្រូវឱ្យជនជាប់ចោទគ្រប់រូបមានវត្តមាន រួមទាំងជនជាប់ចោទដែលបានស្នើសុំមិនបង្ហាញខ្លួនផងដែរ។ [77] ដោយមានការថយចុះជាបន្តបន្ទាប់អំពីវត្តមានរបស់ជនចាប់ចោទ សាលាឧទ្ធរណ៍បាត់ដំបងគួរមានវិធានការ ដើម្បីលើកកម្ពស់សិទ្ធិមានវត្តមានរបស់ជនជាប់ចោទបន្ថែមទៀត។ នៅខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងបានឆ្លើយតបថា តុលាការបានខិតខំប្រឹងប្រែងគោរពសិទ្ធិមានវត្តមានរបស់ជនជាប់ចោទ គឺចង់ឱ្យជនជាប់ចោទមានវត្តមានក្នុងសវនាការ ហើយជៀសវាងធ្វើសវនាការកំបាំងមុខដែលនេះអាចនឹងធ្វើឱ្យតុលាការត្រូវចំណាយពេលច្រើនទៀតលើបណ្តឹងទាស់របស់គាត់។ ក្នុងករណីអវត្តមានជនជាប់ចោទ គឺមានការយល់ព្រមពីភាគីផ្សេងឱ្យដំណើរការសវនាការ បើពុំដូច្នោះទេ សវនាការត្រូវលើកពេល។ តែការពន្យារពេលសវនាការនេះ អាចនាំឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ មួយវិញទៀតអវត្តមានរបស់ជនជាប់ចោទដោយសារជនជាប់ចោទខ្លួនឯងមិនព្រមចូលសវនាការ ឬបារម្ភពីការចាប់ខ្លួន ទោះបីតុលាការបានអញ្ជើញជាច្រើនដងហើយក៏ដោយ ដូចនេះ វាមិនមែនកំហុសរបស់តុលាការទេ ម្យ៉ាងទៀតក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតឱ្យមានសវនាការកំបាំងមុខដែរ ហេតុនេះសូមឱ្យ ម.ស.ម.ក គួរពិនិត្យមើលវិធីសាស្ត្រវាយតម្លៃរបស់ខ្លួនលើចំណុចនេះ។[78]

## សាលាឧទ្ធរណ៍ព្រះសីហនុ

នៅក្នុងឆ្នាំ២០២៤ សាលាឧទ្ធរណ៍ព្រះសីហនុរក្សានូវការលើកកម្ពស់សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ជនជាប់ចោទមានចំនួន ៨៥%នៃសវនាការដែលបានសង្កេត (៣៥ ក្នុងចំណោម ៤១ នាក់)។ តួលេខនេះមានការថយចុះបន្តិច បើធៀបនឹងឆ្នាំ២០២៣ មានចំនួន៩០% ទោះជាមានការថយចុះបែបនេះក្តី នេះនៅតែជាតួលេខគួរឱ្យសាទរ បើធៀបនឹងឆ្នាំ២០២២ ដែលមានត្រឹមតែ ៧៤,៧%ប៉ុណ្ណោះក្នុងចំណោមសវនាការដែល ម.ស.ម.ក បានសង្កេត។

---

[77] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[78] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានប្រកាន់ភ្ជាប់យ៉ាងហ្មត់ចត់នូវការលើកកម្ពស់សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ជនជាប់ចោទក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួននៅក្នុងឆ្នាំ២០២៤ ដោយមានចំនួន ៩៤% (១១៩ ក្នុងចំណោម ១២៦ នាក់) នៃសវនាការដែលបានសង្កេត។ នេះមិនត្រឹមតែជាតួលេខខ្ពស់បំផុតក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួនប៉ុណ្ណោះទេ ថែមទាំងមានការវិវឌ្ឍឡើងដែលគួរឱ្យកត់សម្គាល់ពី ៧៣% នៅឆ្នាំ២០២៣ ដែលជាចំណាត់ថ្នាក់ថាមិនទាន់បានការគោរពសិទ្ធិនេះពេញលេញកាលនោះ និងទាបជាងគេនៅក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន។ តំណាងតុលាការ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំបានសង្កត់ធ្ងន់ទៅលើមូលដ្ឋានគ្រឹះនៃសិទ្ធិក្នុងឆ្នាំ២០២៣ អំឡុងពេលពិគ្រោះយោបល់ជាមួយ ម.ស.ម.ក និងបានកត់សម្គាល់ថា កន្លងមកតុលាការនៅតែបន្តកោះហៅជនជាប់ចោទឱ្យចូលរួមក្នុងសវនាការ ទោះបីជាជនជាប់ចោទនោះបានបោះបង់សិទ្ធិមិនចូលរួមសវនាការដោយសារហេតុផលមួយចំនួនក៏ដោយ។[79] សាលាឧទ្ធរណ៍ក៏បានកត់សម្គាល់ផងដែរថា សាលាឧទ្ធរណ៍បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធានាឱ្យមានវត្តមានជនជាប់ចោទដូចជាការចេញដីកាកោះហៅច្រើនដង អនុញ្ញាតឱ្យមានការលើកពេលសវនាការ និងការធ្វើសវនាការកំបាំងមុខប្រសិនបើចាំបាច់តែប៉ុណ្ណោះ។[80]

## ៤.៣ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

| ច្បាប់អន្តរជាតិ | ច្បាប់ជាតិ |
|---|---|
| **ក.អ.ស.ព.ន** | **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន** |
| មាត្រា ១៤ (៣) (គ) | មាត្រា ៥៧ |

មាត្រា ១៤ (៣)(គ) នៃ ក.អ.ស.ព.ន ធានាថា ជនគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវទទួលបានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ ការពន្លឿននីតិវិធី គឺជាធាតុដ៏សំខាន់មួយនៃការជំនុំជម្រះដោយយុត្តិធម៌។[81] សម្រាប់ជនជាប់ចោទជានីតិជន ច្បាប់ជាតិមិនមានបទប្បញ្ញត្តិណាមួយចែងថាសាលាឧទ្ធរណ៍ត្រូវចាត់ការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងពេលវេលាជាក់លាក់ឡើយ។ តែមាត្រា ៥៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយកុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំ តុលាការត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ ខែ យ៉ាងយូរ លើកលែងតែមានមូលហេតុសត្យានុម័តមិនអាចជម្នះបាន។ សម្រាប់គោលបំណងនៃការវិភាគនេះ ម.ស.ម.ក នឹងចាត់ទុកថាសិទ្ធិទទួលបាន

---

[79] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[80] នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

[81] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ២៧។

ការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានគោរព ប្រសិនបើតុលាការជំនុំជម្រះលើសំណុំរឿងក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍។

*តួលេខទី ១៤៖ ចន្លោះពេលរវាងការទទួលបានបណ្ដឹងឧទ្ធរណ៍ រហូតដល់ថ្ងៃសវនាការលើបណ្ដឹងឧទ្ធរណ៍ទាំងនោះរបស់តុលាការគោលដៅ*[82]

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | សាលាឧទ្ធរណ៍បាត់ដំបង | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | សាលាឧទ្ធរណ៍សីហនុ | សរុប សំណុំរឿង |
|---|---|---|---|---|---|
| តិចជាង ៦ ខែ | ២០៦ | ១៧២ | ៤៨ | ៣០ | **៤៥៦** |
| ចាប់ពី ៦ ខែដល់ ១ ឆ្នាំ | ៣៤ | ៨ | ៣ | ១ | **៤៦** |
| លើសពី ១ ឆ្នាំដល់ ២ ឆ្នាំ | ១១ | ០ | ១ | ២ | **១៤** |
| លើសពី ២ ឆ្នាំ ដល់ ៣ ឆ្នាំ | ៧ | ០ | ០ | ០ | **៧** |
| លើសពី ៣ ឆ្នាំ | ៧ | ០ | ០ | ០ | **៧** |
| មិនមានទិន្នន័យ | ១១ | ២ | ៣៦ | ៣ | **៥២** |
| **សរុប** | **២៧៦** | **១៨២** | **៨៨** | **៣៦** | **៥៨២** |

## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញ បានជំនុំជម្រះលើសំណុំរឿងក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍ មានចំនួន ៧៧.៧% (២០៦ ក្នុងចំណោម ២៦៥) នៃសំណុំរឿងដែលបានសង្កេត។ នេះជាវឌ្ឍនភាពដ៏ល្អប្រសើរ បើធៀបទៅនឹងឆ្នាំមុនដែលមានចំនួន ៦១,៩% ទោះបីមានភាពប្រសើរក្ដី តែតួលេខនេះនៅមិនទាន់គ្រប់គ្រាន់ក្នុងការចាត់ទុកថាសិទ្ធិនេះ ត្រូវបានគោរពពេញលេញនៅឡើយទេ ហើយនេះក៏ជាតួលេខមួយដែលទាបក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួន។ ចំណុចដែលគួរឱ្យកត់សម្គាល់នោះ គឺមានសំណុំរឿងចំនួន ១១ ដែលជនជាប់ចោទត្រូវចំណាយពេល ១ ឆ្នាំ ដល់២ ឆ្នាំ មុននឹងទទួលបានការជំនុំជម្រះ មានចំនួន ៧សំណុំរឿងដែលជនជាប់ចោទត្រូវរង់ចាំ ២ឆ្នាំ ដល់ ៣ឆ្នាំ មុននឹងទទួលបានការជំនុំជម្រះ ហើយការដែលកត់សម្គាល់ខ្លាំងបំផុតនោះគឺថាមាន ៧ សំណុំរឿងបន្ថែមទៀតដែលជនជាប់ចោទត្រូវរង់ចាំសវនាការលើសំណុំរឿងរបស់ខ្លួនលើសពី ៣ ឆ្នាំឡើង។ ការពន្យារពេលបែបនេះ នាំឱ្យជនជាប់ចោទស្ថិតក្នុងភាពមិនច្បាស់លាស់ដែលបានប៉ះពាល់ដល់ការអនុវត្តសិទ្ធិរបស់ពួកគេនេះឱ្យបានពេញលេញ ថាតើពួកគេត្រូវជាប់ឃុំខ្លួនច្បាស់លាស់ក្នុងកម្រិតណា។ តាមរយៈការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បានកត់សម្គាល់ថាការពន្យារពេលមួយចំនួន គឺដោយសារតែបណ្ដឹងទាស់របស់ជនជាប់ចោទប្រឆាំងនឹងសេចក្ដីសម្រេចកំបាំងមុខដែលនេះជាបញ្ហារបស់សំណុំរឿងផ្ទាល់ និងថាសាលាឧទ្ធរណ៍បានផ្ដល់អាទិភាពដល់សំណុំរឿងពាក់ព័ន្ធនឹង

[82] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៥៨២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៤។

កុមារទំនាស់នឹងច្បាប់ សំណុំរឿងមានទោសជាប់ពន្ធនាគារតិចតួច សំណុំរឿងដែលប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា និងសំណុំរឿងពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍។ [83] ទោះបីជាមានការវិវឌ្ឍទៅមុខក៏ដោយ ក៏សាលាឧទ្ធរណ៍គួរបន្តខិតខំបន្ថែមទៀតដើម្បីពន្លឿនដំណើរការសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងនោះ។

## សាលាឧទ្ធរណ៍បាត់ដំបង

សវនាការធ្វើឡើងតិចជាងប្រាំមួយខែបន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍មានចំនួន ៩៥.៥% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត នៅសាលាឧទ្ធរណ៍បាត់ដំបងក្នុងឆ្នាំ២០២៤ (១៧២ ក្នុងចំណោម ១៨០)។ ទោះបីជាតួលេខនេះគួរឱ្យសាទរ និងខ្ពស់បំផុតក្នុងចំណោមតុលាការទាំងបួន តែតួលេខនេះ ប្រហាក់ប្រហែលគ្នាតួយ៉ាង ៩៥,៣% ក្នុងឆ្នាំ២០២៣ និង ៩៦,៤% នៅឆ្នាំ២០២២។ នៅក្នុងការពិគ្រោះយោបល់លើកមុនជាមួយ ម.ស.ម.ក តំណាងមកពីតុលាការ និងមហាអយ្យការសាលាឧទ្ធរណ៍បានកត់សម្គាល់ឃើញថាកត្តាដែលបណ្តាលឱ្យមានការពន្យារពេលជំនុំជម្រះ រួមមាន ការស្នើសុំពន្យារពេលសវនាការដោយជនជាប់ចោទ ឬមេធាវីការពារសិទ្ធិរបស់គេ ជនជាប់ចោទបានប្តឹងទាស់នឹងសាលដីកាកំបាំងមុខ និងករណីដែលជនជាប់ចោទមិនបានទទួលដីកាកោះហៅ។ [84] យ៉ាងណាក្តីតួលេខនេះមានកម្រិតខ្ពស់គួរឱ្យសាទរ ដូចនេះសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានគោរព និងធ្វើឱ្យប្រសើរថែមទៀតដោយជៀសវាងការថយចុះ។

## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ បានដំណើរការសំណុំរឿងតិចជាងប្រាំមួយខែបន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ និងចុះលេខលើបណ្តឹងឧទ្ធរណ៍នោះ មានចំនួន ៩០.៩% នៃសំណុំរឿងដែលបានសង្កេត (៣០ ក្នុងចំណោម ៣៣ ) តួលេខនេះបង្ហាញពីការថយចុះ បើធៀបនឹងឆ្នាំ២០២៣ មានចំនួនរហូតដល់ ៩៥,៣% ។ មាន១ សំណុំរឿង ដែលជនជាប់ចោទត្រូវរង់ចាំសវនការលើសំណុំរឿងរបស់ខ្លួនពី ៦ ខែ ដល់១ឆ្នាំ និងមាន២ សំណុំរឿង ដែលជនជាប់ចោទត្រូវរង់ចាំសវនាការលើសំណុំរឿងរបស់ខ្លួនពី ១ ឆ្នាំ ដល់២ឆ្នាំ។ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការសាលាឧទ្ធរណ៍ព្រះសីហនុ បានបញ្ជាក់កាលពីមុននៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក ថាការជំនុំជម្រះជនជាប់ចោទដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានពន្លឿនដោយមានការលើកទឹកចិត្តពីក្រសួងយុត្តិធម៌។ [85] ទោះបីជាយ៉ាងណាក៏ដោយ ករណីខ្លះអាចមានការយឺតយ៉ាវដោយសារកត្តា ករណីជនជាប់ចោទនៅក្រៅឃុំ ជនជាប់ចោទបានប្តឹងទាស់នឹងសាលដីកាកំបាំងមុខ ឬជនជាប់ចោទត្រូវបានកោះហៅច្រើនដងតែមិនចូលរួមក្នុងសវនាការ។ ទោះបីមានតួលេខថយចុះតែសិទ្ធិទទួល

---

[83] នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារគម្រោងសិទ្ធិមនុស្សមនុស្សរបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើបេកគំហើញសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[84] នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

[85] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

បានការជំនុំជម្រះដោយគ្មានការពន្យារពេលនេះនៅតែបន្តការលើកកម្ពស់ ដូចនេះសាលាឧទ្ធរណ៍គួរបន្តការធ្វើឱ្យប្រសើរឡើងថែមទៀតដើម្បីជៀសវាងការថយចុះ។

### សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានការវិវឌ្ឍគួរឱ្យកត់សម្គាល់លើដំណើរការជំនុំជម្រះក្នុងរយៈពេលតិចជាងប្រាំមួយខែ បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍ ចំនួនកើនឡើងដល់ ៩២% (៤៨ ក្នុងចំណោម ៥២) នៅឆ្នាំ ២០២៤ បើធៀបនឹងឆ្នាំ២០២៣ មានត្រឹមតែ ៨៣,៣%។ នេះគឺជាភាពល្អប្រសើរដែលគួរឱ្យកត់សម្គាល់ ក្នុងការធានាថាដំណើរការលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទអាចប្រព្រឹត្តដោយទាន់ពេលវេលា ដូចនេះសាលាឧទ្ធរណ៍ត្បូងឃ្មុំគួររក្សានូវការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលនេះបន្តទៀត។

## ៤.៤ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (២) | មាត្រា ៣៨ | មាត្រា ៥ |

ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅអំឡុងពេលស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌ និងដំណើរការជំនុំជម្រះទាំងមូល រហូតដល់បណ្ដឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ។[86] យោងតាមន័យនេះ បុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញតាមច្បាប់ និងតាមរយៈសេចក្ដីសម្រេចស្ថាពរ។ ជាគោលការណ៍ បន្ទុកភស្តុតាងស្ថិតនៅលើស្ថាប័នតំណាងអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ។[87] ទោះបីជាជនជាប់ចោទមិននិយាយអ្វី និងមិនបង្ហាញភស្តុតាងអ្វីក៏ដោយ ក៏ពួកគេត្រូវតែបានរួចទោសដែរ ប្រសិនបើអយ្យការមិនបានបង្ហាញភស្តុតាងដាក់បន្ទុកចាំបាច់គ្រប់គ្រាន់សម្រាប់ការផ្ដន្ទាទោស ម្យ៉ាងវិញទៀត ជនជាប់ចោទមិនមែនជាអ្នកដែលត្រូវបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថាខ្លួនគ្មានទោសនោះទេ។[88]

កត្តាមួយចំនួនអាចត្រូវបានយកមកពិចារណាក្នុងការវាយតម្លៃថា តើមានការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទដែរឬទេ។ កត្តាដែលអាចប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺជាលក្ខណៈដែលបង្ហាញថាជនជាប់ចោទមានពិរុទ្ធភាពក្នុងអំឡុងពេលសវនា

[86] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១) ជំពូកទី ៦ ទំព័រ ១២៩ https://tinyurl.com/35w2rrm6; អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្ដីពីការជំនុំជម្រះដោយយុត្តិធម៌" (២០១៤) ទំព័រ ១២៥ ផ្នែកទី ១៥.១។

[87] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣០។

[88] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/4mj9dmre

ការ ដូចជា ការដាក់ខ្នោះជើង ខ្នោះដៃ ជាប់ទ្រុង ឬឯកសណ្ឋានពន្ធនាគារជាដើម។[89] ការអនុវត្តល្អបំផុតជាអន្តរជាតិនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌបង្ហាញថា ជនជាប់ចោទគួរមានសម្លៀកបំពាក់របស់ខ្លួន នៅពេលបង្ហាញខ្លួនចំពោះមុខតុលាការ ជាសញ្ញានៃការគោរពសេចក្តីថ្លៃថ្នូរ និងឋានៈរបស់ពួកគេក្នុងនាមជាអ្នកគ្មានទោស។[90] នៅពេលដែលជនជាប់ចោទត្រូវបានតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានដូចគ្នាទៅនឹងទណ្ឌិត អាចឱ្យមានលក្ខណៈបុរេវិនិច្ឆ័យថាពួកគេពួកគេមានពិរុទ្ធភាពរួចហើយ ដែលការធ្វើបែបនេះជះឥទ្ធិពលអវិជ្ជមានលើសេចក្តីសម្រេចរបស់ចៅក្រម និងលទ្ធផលចុងក្រោយនៃសំណុំរឿង។

វិធានរបស់អង្គការសហប្រជាជាតិឆ្នាំ២០១៥ ស្តីពីបទដ្ឋានអប្បបរសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ("វិធាននែលសាន់ម៉ាន់ដឺឡា") ដែលតំណាងឱ្យការអនុវត្តល្អបំផុត ត្រូវបានទទួលស្គាល់ជាអន្តរជាតិលើការប្រព្រឹត្តទៅលើជនជាប់ឃុំចែងថា ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះដែលមានសេចក្តីសម្រេចស្ថាពរ គួរត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេនៅពេលជំនុំជម្រះ ឬប្រសិនបើពួកគេពាក់ឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវតែមានលក្ខណៈខុសពីទណ្ឌិត។[91] ដូចគ្នានេះដែរ ជនជាប់ចោទដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនៃការដំណើរការនីតិវិធីព្រហ្មទណ្ឌ រហូតដល់មានការផ្តន្ទាទោសជាស្ថាពរ។

នៅកម្ពុជា បញ្ហាជនជាប់ឃុំបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារ គឺជាបន្ទុករបស់អគ្គនាយកដ្ឋានពន្ធនាគារ។ ឯកសណ្ឋានដែលអ្នកជាប់ទោសត្រូវប្រើប្រាស់មានចែងនៅក្នុងនិតិវិធីពន្ធនាគារ លេខ ០៥ (៤.១) "ឯកសណ្ឋានអ្នកជាប់ទោស និងបរិក្ខាក្នុងបន្ទប់ឃុំឃាំង" នៃនីតិវិធីពន្ធនាគារ ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ៖ "មន្ត្រីពន្ធនាគារដែលទទួលជនជាប់ទោស ត្រូវជានាថា នៅពេលជនជាប់ទោសត្រូវបានទទួលឱ្យចូលក្នុងពន្ធនាគារ ពួកគេត្រូវទទួលបាននូវឯកសណ្ឋាន និងបរិក្ខាក្នុងបន្ទប់ឃុំឃាំងដូចតទៅ៖ អាវពណ៌ខៀវឆ្នូតសនៅកចំនួនពីរ ខោជើងវែងពណ៌ខៀវឆ្នូតសពីចំហៀងចំនួនពីរ"។ ប្រកាសឆ្នាំ២០១៣ បានកំណត់ថា បុគ្គលដែលមិនទាន់ត្រូវតុលាការបានកាត់ទោស ឬការកាត់ទោសរបស់គេមិនទាន់ចូលជាស្ថាពរ ហើយដែលអ្នកទាំងនេះត្រូវអាជ្ញាធរឃុំខ្លួនត្រូវស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។[92] ថ្វីបើបទប្បញ្ញត្តិនៃការប្រើប្រាស់ឯកសណ្ឋានខុសគ្នាសម្រាប់បុគ្គលទណ្ឌិត និងបុគ្គលដែលការកាត់ទោសរបស់គេមិនទាន់ចូលជាស្ថាពរ មានភាពប្រសើរឡើងក្តី ដើម្បីធានាថាសិទ្ធិទទួលការសន្មតជាមុនថាគ្មានទោសត្រូវបានគោរពពេញលេញ ជនជាប់ចោទទាំងអស់ដែលការកាត់ទោសរបស់គេមិនទាន់ចូលជាស្ថាពរ អាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន

---

[89] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាកខណ្ឌ ៣០, ECtHR, Samoila និង Cionca ទល់នឹង Romania (ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៨) ពាក្យស្នើសុំ លេខ ៣៣០៦៥/០៣, វាក្យខណ្ឌ ៩៩-១០១, https://tinyurl.com/yaebnffc

[90] ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក៖ *ឯកសណ្ឋានជនជាប់ឃុំ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស* (ឆ្នាំ២០១៧), https://tinyurl.com/FTR-Prison-Uniforms-2017

[91] មហាសន្និបាតអង្គការសហប្រជាជាតិ វិធានបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ សេចក្តីសម្រេចលេខ ៧០/១៧៥ (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥) វិធានលេខ ១៩៖ សម្លៀកបំពាក់ និងការដេក https://tinyurl.com/3hrbhupp

[92]កាសែតភ្នំពេញប៉ុស្តិ៍ *ជនសង្ស័យស្លៀកពាក់ពណ៌ទឹកក្រូចចាស់* ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ https://web.archive.org/web/20131018080921/https:/www.phnompenhpost.com/national/suspects-wear-saffron

ចូលរួមក្នុងដំណើរការសវនាការបាន។ [93] ជនជាប់ចោទដែលការកាត់ទោសរបស់ពួកគេមិនទាន់ចូលជាស្ថាពរ ហើយបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាទណ្ឌិតគឺផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ប្រកាសឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងនីតិវិធីពន្ធនាគារលេខ ៥។ ការធ្វើបែបនេះក៏ជាការមិនអនុលោមតាមច្បាប់សិទ្ធិមនុស្ស អន្តរជាតិ ដែលធានាដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងបទដ្ឋានអន្តរជាតិ ដូចជា វិធាននៃ លសាន់ម៉ាន់ដឺឡា ជាពិសេស វិធានលេខ ៩ ដែលចែងអំពីសម្លៀកបំពាក់ និងការដេក។

ជាតុផ្សេងទៀតនៃសិទ្ធិនេះរួមមាន ថាតើមានការអានប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ដែរឬទេ មានការទាញសេចក្ដីសន្និដ្ឋានថាមានពិរុទ្ធពីការនៅស្ងៀមរបស់ជនជាប់ចោទដែរឬទេ និងមានសេចក្ដី ថ្លែងអំពីពិរុទ្ធភាពណាមួយរបស់ចៅក្រមមុនពេលចេញសេចក្ដីសម្រេច/សាលដីកាដែរឬទេ។ សម្រាប់សិទ្ធិនៅ ស្ងៀម ច្បាប់កម្ពុជាបានដាក់បន្ទុកនេះទៅលើចៅក្រមស៊ើបសួរអំឡុងពេលជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោម ការពិនិត្យ។ [94] ទោះជាយ៉ាងណាក៏ដោយ ម.ស.ម.ក លើកទឹកចិត្តឱ្យចៅក្រមសាលាឧទ្ធរណ៍ឱ្យអនុវត្តនូវការ ប្រតិបត្តិល្អជាប្រចាំ ដោយមិនត្រឹមតែអានប្រាប់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់អំពីសិទ្ធិនោះដល់ ជនជាប់ចោទផងដែរ ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្តបានល្អិតល្អន់អំពីការនិយាយនៅក្នុងសវនាការ។

កត្តាទាំងបួនដែលរួមមាន ការដាក់ខ្នោះដៃ ឱ្យប្រើប្រាស់ឯកសណ្ឋានពន្ធនាគារ ការខកខានអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀម និងការសន្និដ្ឋាន ឬការទាញសេចក្ដីសន្និដ្ឋាន ឬថ្លែងការណ៍អំពីពិរុទ្ធភាពណាមួយ ដោយចៅក្រម ត្រូវបានយកមកពិចារណានៅក្នុងសំណុំរឿងដែលបានសង្កេតនៅក្នុងតុលាការនីមួយៗក្នុង ចំណោមតុលាការគោលដៅទាំងបួន ដើម្បីវាយតម្លៃអំពីការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោ ស។ នៅក្នុងតុលាការគោលដៅទាំងបួន មានភាពប្រសើរដែលអាចប្រៀបធៀបគ្នាបានទៅលើការគោរពសិទ្ធិនេះ ដោយមានតុលាការចំនួនពីរក្នុងចំណោមបួនបានគោរពសិទ្ធិនេះ ដែលខុសពីឆ្នាំ២០២៣ ដែលមានតែសាលា ឧទ្ធរណ៍ព្រះសីហនុតែប៉ុណ្ណោះដែលបានគោរពសិទ្ធិនេះ។ គួរកត់សម្គាល់ផងដែរថា កាលពីឆ្នាំ២០២២ មិនមាន តុលាការណាមួយបានគោរពសិទ្ធិនេះទេ។ ជារួម មិនមានការកត់ត្រាអំពីសំណុំរឿងណាមួយពីតុលាការទាំងបួន ដែលថាជនជាប់ចោទត្រូវបានដាក់ខ្នោះដៃក្នុងអំឡុងសវនាការនោះទេ ហើយក៏មិនមានការកត់ត្រាអំពីហេតុ ការណ៍ណាមួយ ដែលចៅក្រមទាញសេចក្ដីសន្និដ្ឋានថាមានពិរុទ្ធពីការនៅស្ងៀមរបស់ជនជាប់ចោទ ឬថ្លែង ការណ៍អំពីពិរុទ្ធភាពមុនពេលចេញសាលដីកា នៅក្នុងសវនាការដែល ម.ស.ម.ក បានសង្កេតនោះដែរ។ នៅក្នុង តុលាការគោលដៅទាំងបួនមាន ២៥% នៃសំណុំរឿងដែលបានសង្កេត (១៤០ ក្នុងចំណោម ៥៥៥ សំណុំរឿង) ចៅក្រមបានខកខានអានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេទេ។ ទោះបីនេះគឺជាភាគ

[93] ព្រឹត្តិបត្រព័ត៌មានស្ដីពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ ម.ស.ម.ក៖ *ឯកសណ្ឋានជនជាប់ទោស ខែធ្នូ ឆ្នាំ ២០២៤* https://www.cchrcambodia.org/en/publications/factsheets/newsletter-on-right-to-presumption-of-innocence-uniform-for-prisoners

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៣។

រយនេះមានភាពប្រសើរឡើងបើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួន ៣៤% ទោះយ៉ាងនេះក្តី នេះបង្ហាញថា ជនជាប់ចោទមិនបានយល់ដឹងអំពីសិទ្ធទទួលការសន្មតទុកជាមុនថាគ្មានទោសដ៏សំខាន់មួយនេះ។

*តួលេខទី ១៥៖ ចំនួនជនជាប់ចោទដែលចៅក្រមបានអានប្រាប់ និងពន្យល់ អំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ*[95]




ចំពោះឯកសណ្ឋានពន្ធនាគារ ម.ស.ម.ក ស្នើឱ្យសាលាឧទ្ធរណ៍គោលដៅទាំងអស់ទទួលយកការអនុវត្តល្អជាអន្តរជាតិដែលអនុញ្ញាតឱ្យជនជាប់ចោទប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួន ឱ្យដូចជនជាប់ចោទដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ នេះអាចត្រូវបានចាត់ទុកថាបានគោរពដែរ ប្រសិនបើជនជាប់ចោទស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ជាទូទៅមានការប្រសើរ ចំនួនជនជាប់ចោទដែលស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ ជំនួសឱ្យឯកសណ្ឋានពណ៌ខៀវជាទណ្ឌិត។ ក្នុងឆ្នាំ២០២៤ ម.ស.ម.ក បានកត់ត្រាថាមានចំនួន ២៩% (១៨៧ ក្នុងចំណោម ៦៤៣ នាក់) នៃសំណុំរឿងដែលបានសង្កេតនៅក្នុងតុលាការទាំងបួន ជនជាប់ចោទត្រូវបានបន្តការឃុំខ្លួន និងមានពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវ វាមានភាពប្រសើរជាងបន្តិច បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៣៦,៥% ហើយក្រៅពីនោះ ជនជាប់ចោទមានឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូចចាស់។ ទោះបីមានភាពប្រសើរគួរកត់សម្គាល់ក្តី តែទិន្នន័យនេះមានភាពខុសគ្នារវាងសាលាឧទ្ធរណ៍ទាំងបួន មានតែសាលាឧទ្ធរណ៍ចំនួនពីរប៉ុណ្ណោះដែលបានលើកកម្ពស់សិទ្ធិនេះ។ នេះជាវឌ្ឍនភាពល្អប្រសើរបើធៀបនឹងឆ្នាំ២០២៣ ដែលមានតែសាលាឧទ្ធរណ៍មួយប៉ុណ្ណោះ ដែលបានគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ ទោះជាយ៉ាងណាក៏ដោយ ការស្លៀកបំពាក់ស៊ីវិលគួរត្រូវលើកកម្ពស់ដើម្បីធានាឱ្យបានពេញលេញស្របតាមការអនុវត្តល្អ។

*តួលេខទី ១៦៖ ការគោរពសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសដោយតុលាការគោលដៅ*[96]

[95] ទិន្នន័យនេះគឺផ្អែកលើជនជាប់ចោទចំនួន ៧២១ (ក្នុងចំណោម ៨២២) ដែលមានវត្តមាននៅពេលសវនាការ។

[96] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៨២២ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៥៨២ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ជនជាប់ចោទអវត្តមាន ឬមិនជាប់ពន្ធនាគារ។

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | | | សាលាឧទ្ធរណ៍បាត់ដំបង | | | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | | | សាលាឧទ្ធរណ៍ព្រះសីហនុ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ |
| តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅអំឡុងពេលសវនាការដែរឬទេ? | ០ | ៣១១ | ៥៤ | ០ | ២០០ | ៩០ | ០ | ១០៣ | ២៣ | ០ | ២៩ | ១២ |
| តើចៅក្រមបានធ្វើសេចក្ដីថ្លែងណាមួយអំពីពិរុទ្ធភាពរបស់ជនជាប់ចោទមុនពេលចេញសាលដីកាដែរឬទេ? | ០ | ៣៦៥ | ០ | ០ | ២៩០ | ០ | ០ | ១២៦ | ០ | ០ | ៤១ | ០ |
| តើមានអ្វីមួយដែលបង្ហាញថាចៅក្រមទាញការសន្និដ្ឋានអំពីពិរុទ្ធភាពដោយផ្អែកលើការនៅស្ងៀមរបស់ជនជាប់ចោទឬដែរឬទេ? | ០ | ៣៤៣ | ២២ | ០ | ២១៥ | ៧៥ | ០ | ១១៨ | ៨ | ០ | ៣៥ | ៦ |

**សាលាឧទ្ធរណ៍ភ្នំពេញ**

នៅក្នុងសំណុំរឿងចំនួន ៤១% (១១០ ក្នុងចំណោម ២៦៦) ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងឆ្នាំ២០២៤ ចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ដែលបង្ហាញពីវឌ្ឍនភាពប្រសើរ បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួនត្រឹមតែ ១៩% នៃសំណុំរឿងដែលបានសង្កេត។ ភាពប្រសើរនេះបានកើតឡើងតាមរយៈការផ្លាស់ប្ដូរមួយចំនួន ក្រោយពេលមានការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក។ នៅក្នុងឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញទទួលស្គាល់ថា ពេលខ្លះ ចៅក្រមមិនបានប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ហើយតុលាការបាននិយាយថា តុលាការនឹងណែនាំចៅក្រមទាំងអស់ឱ្យធ្វើកិច្ចការនេះជាប្រព័ន្ធ និងជាប្រចាំ។[97]

ជាលើកដំបូងនៅក្នុងរយៈពេលជាច្រើនឆ្នាំ ដែលសាលាឧទ្ធរណ៍ភ្នំពេញឈានដល់កម្រិតកំណត់នៃការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ដោយមានចំនួន ៩៦% នៃជនជាប់ចោទ (៣០០ ក្នុងចំណោម ៣១១ នាក់) បង្ហាញខ្លួនពេលសវនាការដោយស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ នេះជាវឌ្ឍន

[97] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតរបស់ ម.ស.ម.ក។

ភាពគួរឱ្យកោតសរសើររបស់សាលាឧទ្ធរណ៍ភ្នំពេញ បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួនត្រឹមតែ ៧៦%។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក នៅក្នុងឆ្នាំ២០២០ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍នេះបានអះអាងថា បញ្ហាឯកសណ្ឋានពន្ធនាគារមិនស្ថិតក្រោមសិទ្ធិអំណាចរបស់ខ្លួននោះទេ ហើយជាទំនួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារទៅវិញទេ។[98] នៅក្នុងឆ្នាំ២០២៣ តុលាការបានប្រាប់ ម.ស.ម.ក ថា ខ្លួននឹងយកបញ្ហានេះទៅពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធនាគារ។[99]

*តួលេខទី១៧៖ ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់និងពន្យល់ជនជាប់ចោទនូវសិទ្ធិនៅស្ងៀមរបស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៤)[100]*




ទន្ទឹមនឹងមានវឌ្ឍនភាព និងការខិតខំប្រឹងប្រែងនេះ ក៏នៅមានភាពល្អប្រសើរគួរកត់សម្គាល់បន្ថែមទៀត ដោយហេតុថា មានសំណុំរឿងចំនួនតែ ១១ ដែលជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវប៉ុណ្ណោះ នេះជាចំនួនតិចតួចបើធៀបទៅនឹងចំនួនសរុប។ យ៉ាងណាក្តី ទិន្នន័យនេះមានតិចតួចក៏ដោយ ក៏នៅបង្ហាញថានេះមានការបំពានសិទ្ធិនេះដែរ និងអាចមានផលប៉ះពាល់ដល់លទ្ធផលចុងក្រោយនៃសំណុំរឿងនីមួយៗ។ គួរកត់

---

[98] នៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយឯកឧត្តមប្រធាន និងឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តមអគ្គព្រះរាជអាជ្ញា និងឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ និងឯកឧត្តមអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ឆ្នាំ២០១៨/២០១៩ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[99] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[100]ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នីមួយៗ។

សម្គាល់ថាមូលដ្ឋានគ្រឹះនៃការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស នៅក្នុងសំណុំរឿងនីមួយៗ មានសារៈសំខាន់ខ្លាំងនៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍។

*តួលេខទី ១៨៖ ភាគរយនៃជនជាប់ចោទដែលបានបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញដោយឯកសណ្ឋានជនជាប់ទោសពណ៌ខៀវ (ឆ្នាំ២០២១-២០២៤)*[101]




## សាលាឧទ្ធរណ៍បាត់ដំបង

នៅសាលាឧទ្ធរណ៍បាត់ដំបង ចៅក្រមបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទចំនួន ៥៩% (១០១ ក្នុងចំណោម ១៧២ សំណុំរឿង) ដែលមានការថយចុះគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំមុន មានចំនួនរហូតដល់ ៧០%នៃសំណុំរឿងដែលបានសង្កេត។ នេះជាការខកខានគួរកត់សម្គាល់ ដែលសាលាឧទ្ធរណ៍បាត់ដំបងធ្លាប់ទទួលបានទិន្នន័យប្រសើរជាងគេក្នុងចំណោមតុលាការគោលដៅទាំងបួន។

*តួលេខទី ១៩៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំនៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍បាត់ដំបង*[102]




អ្វីដែលគួរឱ្យកត់សម្គាល់គឺ ជនជាប់ចោទដែលត្រូវឃុំខ្លួនបានបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ខៀវនៅសាលាឧទ្ធរណ៍បាត់ដំបងមានចំនួន ៥៨% នៃសំណុំរឿងដែលបាន ម.ស.ម.ក បានសង្កេត (១១៦ ក្នុងចំណោម ២០០ សំណុំរឿង)។ ទោះបីជាតួលេខនេះបង្ហាញអំពីភាពប្រសើរឡើងបើធៀបទៅនឹងឆ្នាំមុន ដែលជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវមាន

[101] ទិន្នន័យបង្ហាញនៅក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញអំឡុងពេលធ្វើរបាយការណ៍នីមួយៗ។

[102] ទិន្នន័យបង្ហាញនៅក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍បាត់ដំបង ឆ្នាំ ២០២៤ (២៩០ ជនជាប់ឃុំ)។

រហូតដល់ ៦៥,១%សំណុំរឿងដែលបានសង្កេត។ ការដែលជនជាប់ចោទបានបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ខៀវពេលសវនាការមានភាគរយខ្ពស់ក្នុងរយៈពេលពីរឆ្នាំជាប់គ្នានោះគឺជាចំណុចគួរយកចិត្តទុកដាក់។ ដូចដែលបានរៀបរាប់ខាងលើ ស្ថានភាពនេះជាសារមួយបង្ហាញថា ពួកគេមានពិរុទ្ធមុនពេលចេញសាលដីកា ដែលអាចបង្ហាញអំពីការជះឥទ្ធិពលដល់លទ្ធផលនៃការសម្រេចក្តីរបស់ជនជាប់ចោទ។

រកគំហើញនេះ បង្ហាញថាសិទ្ធិនេះមិនទាន់បានលើកកម្ពស់ពេញលេញនៅឡើយក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នា។ នៅក្នុងកិច្ចប្រជុំជាមួយ ម.ស.ម.ក តំណាងតុលាការបានបង្ហាញពីការព្រួយបារម្ភចំពោះបញ្ហាសន្តិសុខនៅពេលដែលជនជាប់ចោទប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេចូលសវនាការ។[103]
ដូចនេះ គួរត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាថាជនជាប់ចោទដែលបង្ហាញខ្លួននៅតុលាការយ៉ាងហោចណាស់ក្នុងឯកសណ្ឋានពណ៌ទឹកក្រូចចាស់ ដែលនាំឱ្យមានការលើកកម្ពស់សិទ្ធិសន្មតទុកជាមុខថាគ្មានទោស។ ខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានអះអាងថាជនជាប់ចោទដែលបានពាក់ឯកសណ្ឋានពណ៌ខៀវ (ជាឯសណ្ឋានសម្រាប់ទណ្ឌិត) មិនមែនជាការទទួលខុសត្រូវរបស់តុលាការនោះទេ វាស្ថិតក្នុងដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធនាគារ តែយ៉ាងណាមានពន្ធនាគារមួយចំនួនបានអនុវត្តល្អ ដោយនាំជនជាប់ចោទមកជំនុំជម្រះមានសំលៀកបំពាក់ពណ៌ទឹកក្រូចចាស់។ ដូចនេះ តុលាការនឹងជជែកបន្តទៀតជាមួយពន្ធនាគារផ្សេងទៀត ដើម្បីធានាថា ជនជាប់ចោទមិនត្រូវប្រើប្រាស់ឯកសណ្ឋានទណ្ឌិតនោះទេ ហើយ ម.ស.ម.ក គួរជជែកពិភាក្សាបញ្ហានេះជាមួយអគ្គនាយកដ្ឋានពន្ធនាគារផងដែរ។[104]

## សាលាឧទ្ធរណ៍ព្រះសីហនុ

[103] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[104] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

### *តួលេខទី ២០៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំនៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ព្រះសីហនុ*[105]




សាលាឧទ្ធរណ៍ព្រះសីហនុបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទពីសិទ្ធិនៅស្ងៀមរបស់ពួកគេនៅក្នុងកម្រិតតិចនៅឡើយ។ ចៅក្រមបានខកខានអានប្រាប់ និងពន្យល់សិទ្ធិនេះនៅក្នុងសំណុំរឿងចំនួន ៩១% នៃសំណុំរឿងបានសង្កេតក្នុងឆ្នាំ ២០២៤ ចំនួននេះមានការកើនឡើង បើធៀបនឹងឆ្នាំ ២០២៣ មានចំនួនត្រឹមតែ ៨៦% ប៉ុណ្ណោះ។ តួលេខនេះ បង្ហាញអំពីផលប៉ះពាល់ដល់ការយល់ដឹងរបស់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ខ្លួនក្នុងអំឡុងសវនាការ ដែលជាលទ្ធផល អាចជះឥទ្ធិពលដល់ការចូលរួមរបស់ពួកគេ និងធ្វើឱ្យមានហានិភ័យចំពោះការឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ក្នុងចំនួន ៦% (២ ក្នុងចំណោម ៣២) នៃសំណុំរឿង ដែលចៅក្រមបានប្រាប់ជនជាប់ចោទអំពីសិទ្ធិនេះ។ នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ បានបញ្ជាក់ថាជាទូទៅជនជាប់ចោទបានដឹងអំពីសិទ្ធិរបស់ខ្លួនរួចហើយនៅក្នុងសាលាដំបូង។[106] ទោះជាមានបែបនេះក្តី ក៏មិនត្រូវសន្និដ្ឋានថាជនជាប់ចោទបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងដំណើរការសវនាការនៅសាលាឧទ្ធរណ៍នោះទេ ដូចនេះ សាលាឧទ្ធរណ៍គួរអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះផងដែរ។ នៅខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថាការប្រាប់ឱ្យជនជាប់ចោទប្រើសិទ្ធិនៅស្ងៀម តុលាការអាចលំបាកក្នុងការវិនិច្ឆ័យលើសំណុំរឿង ពីព្រោះខ្វះព័ត៌មានគ្រប់ជ្រុងជ្រោយពីជនជាប់ចោទ។[107]

ទោះបីជាមានទិន្នន័យអំពីការពន្យល់ប្រាប់សិទ្ធិយ៉ាងនេះក្តី សាលាឧទ្ធរណ៍ព្រះសីហនុមានការវិវឌ្ឍជាវិជ្ជមាន គួរឱ្យកត់សម្គាល់លើចំនួនជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូចចាស់អំឡុងពេលសវនាការ ដែលមានជនជាប់ចោទ ៩០%(២៦ ក្នុងចំណោម ២៩ នាក់) ក្នុងសវនាការដែល ម.ស.ម.ក បានសង្កេត។ ទោះជាយ៉ាងនេះក្តីតួលេខនេះថយចុះ បើធៀបនឹងឆ្នាំ២០២៣ មានរហូតដល់ ៩៨%។ ម.ស.ម.ក ស្វាគមន៍ចំពោះសាលាឧទ្ធរណ៍ព្រះសីហនុ ដែលបន្តគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

[105] ទិន្នន័យបង្ហាញនៅក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ព្រះសីហនុក្នុងឆ្នាំ២០២៤ (៤១ ជនជាប់ឃុំ)។

[106] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន ។

[107] នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

និងអាចអនុញ្ញាតឱ្យជនជាប់ចោទប្រើប្រាស់សម្លៀកបំពាក់ស៊ីវិលនាពេលខាងមុខ។ នៅក្នុងខែមីនា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ បានប្រាប់ ម.ស.ម.ក ថា តុលាការបានណែនាំមន្ត្រីពន្ធនាគារជួយធ្វើយ៉ាងណាឱ្យជនជាប់ចោទដែលបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ស៊ីវិល[108] ប៉ុន្តែហាក់បីដូចជាមិនទាន់បានអនុវត្តនៅឡើយ។

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

*តួលេខទី ២១៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំខ្លួននៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ[109]*




សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានការវិវឌ្ឍល្អប្រសើរ ចំពោះការអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទ ដោយចៅក្រមបានអានប្រាប់ និងពន្យល់ចំនួន ៤៨% នៃសំណុំរឿងដែលបានសង្កេត។ តួលេខនេះគឺបង្ហាញការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៣ មានត្រឹមតែ ៣៥%។ ការវិវឌ្ឍនេះគឺឆ្លុះបញ្ចាំងឱ្យឃើញភាពប្រសើរទៅមុខពីមួយឆ្នាំទៅមួយឆ្នាំរបស់សាលាឧទ្ធរណ៍ត្បូងឃ្មុំក្នុងការគោរពសិទ្ធិនេះ ដូចនេះ តុលាការគួរមានវិធានការចាំបាច់ ដើម្បីធានាបន្តនូវវឌ្ឍនភាពទាំងនេះ។

យ៉ាងណាមិញ ចំពោះការស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវវិញ តុលាការនេះមិនទាន់បានលើកកម្ពស់សិទ្ធិនេះពេញលេញនៅឡើយទេ។ ជនជាប់ចោទដែលមានឯកសណ្ឋានពណ៌ខៀវមានចំនួន ៥៥% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតក្នុងអំឡុងពេលរាយការណ៍។ តួលេខនេះគឺជាការកើនឡើងគួរឱ្យកត់សម្គាល់ ដោយហេតុថានៅក្នុងឆ្នាំ២០២៣ មានចំនួនត្រឹមតែ ៤៩% ប៉ុណ្ណោះ។ សម្រាប់ឆ្នាំទី២បន្តបន្ទាប់នេះ តួលេខនេះបង្ហាញថា ជនជាប់ចោទម្នាក់ក្នុងចំណោមពីរនាក់ដែលសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់គេមិនត្រូវគោរព ហើយនេះគឺគួរជាចំណុចត្រូវយកចិត្តទុកដាក់។

នៅក្នុងខែសីហាឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការបានបញ្ជាក់ថាតុលាការបានទិញសម្លៀលបំពាក់ស៊ីវិលរួចរាល់ហើយ ដើម្បីប្តូរឯកសណ្ឋានពន្ធនាគារ សម្រាប់ជនជាប់ចោទក្នុងពេលសវ

---

[108] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[109] ទិន្នន័យបង្ហាញនៅក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលជាប់ឃុំ និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំឆ្នាំ២០២៤ (១២៦ ជនជាប់ឃុំ)។

នាការ ប៉ុន្តែមិនទាន់មានការអនុវត្តនៅឡើយ។[110] ម.ស.ម.ក ស្នើឱ្យតុលាការមានវិធានការចាំបាច់ដើម្បីធានាថា សម្លៀកបំពាក់ស៊ីវិលគួរត្រូវបានប្រើប្រាស់សម្រាប់ជនជាប់ចោទនៅក្នុងគ្រប់សំណុំរឿងនាពេលខាងមុខ។

## ៤.៥ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

| ច្បាប់អន្តរជាតិ | | | ច្បាប់កម្ពុជា | | |
|---|---|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | អនុសញ្ញាប្រឆាំងទារុណកម្ម | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ៥ | មាត្រា ១៤(៣)(ឆ) និង មាត្រា ៧ | មាត្រា ១៥ | មាត្រា ៣៨ | មាត្រា ១៤៥ និងមាត្រា ៣២១ | មាត្រា ៥ និង មាត្រា ៦ |

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដែលត្រូវបានធានាដោយមាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន មានសមាសធាតុមួយចំនួន។[111] ទីមួយ មាត្រានេះ មានន័យថា គ្មានការបង្ខិតបង្ខំទាំងផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលដើម្បីបង្ខំជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ក្នុងសំណុំរឿងព្រហ្មទណ្ឌឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។[112] ទីពីរ មាត្រានេះ មានន័យថា បុគ្គលទាំងនេះ មិនអាចត្រូវបានបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយមិនត្រូវផ្តល់ភស្តុតាងដែលអាចប្រើប្រាស់ប្រឆាំងនឹងខ្លួនឯងបានឡើយ[113] ប្រសិនបើជនណាម្នាក់បដិសេធក្នុងការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួងឯង ឬរក្សាសិទ្ធិនៅស្ងៀម សេចក្តីសន្និដ្ឋានអវិជ្ជមានណាមួយដែលធ្វើឡើងដោយចៅក្រមចេញពីស្ថានភាពនេះ ត្រូវបានហាមឃាត់។ [114] ការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ

---

[110] នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

[111] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/8jy3ynnj

[112] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៤១ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៩១២/២០០០, *Deolall* ទល់នឹងប្រទេសហ្គីយ៉ាន (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤) CCPR/C/៨២/D/៩១២/២០០ វាក្យខណ្ឌ ៥.១, https://tinyurl.com/9ch8r85e គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, *Khuseynova* និង *Butaeva* ទល់នឹងប្រទេសតាហ្ស៊ីគីស្ថាន (ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨) CCPR/C/៩៤/D/១២៦៣–១២៦៤/២០០៤ វាក្យខណ្ឌ ៨.៣, https://tinyurl.com/3768t8cd, អ.វ.ត.ក, កាំង ហ្គេកអ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១) អង្គជំនុំជម្រះសាលាដំបូង (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២) វាក្យខណ្ឌ ៣៦០។

[113] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឆ), អ.ស.ក មាត្រា ៤០(២)(ខ)(iv)។

[114] *ECtHR*, Condron និងចក្រភពអង់គ្លេស (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០) ពាក្យស្នើសុំលេខ ៣៥៧១៨/៩៧ វាក្យខណ្ឌ ៥៦ https://tinyurl.com/yc4tphd8;

អាចមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសនោះទេ ប៉ុន្តែព្រះរាជអាជ្ញាអាចត្រូវបានយកមកពិចារណា នៅពេលវាយតម្លៃភស្តុតាង។[115] ក្នុងករណីសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ ច្បាប់សិទ្ធិមនុស្សអន្តរជាតិគឺទូទៅចែងថាកុមារទំនាស់នឹងច្បាប់មិនត្រូវបានបង្ខិតបង្ខំ "ឱ្យផ្តល់សក្ខីកម្ម" ឡើយ។[116]

ជាតុផ្សំសំខាន់ផ្សេងទៀតនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងគឺជាការហាមឃាត់ដាច់ខាតចំពោះការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឯង ឬដាក់ទណ្ឌកម្មឯទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប។ សិទ្ធិនេះ មានចែងនៅក្នុងមាត្រា ៧ នៃ ក.អ.ស.ព.ន មាត្រា ៥ នៃ ស.ស.ស.ម និងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មរបស់អង្គការ សហប្រជាជាតិដែលកម្ពុជាបានផ្ដើសច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ការហាមឃាត់ការធ្វើទារុណកម្មត្រូវបានចាត់ទុកថាជា "បទដ្ឋាន ដាច់ខាត" នៅក្នុងច្បាប់អន្តរជាតិ ឬបទដ្ឋានជូស ខូហ្សិន (jus cogens) ដែលមានន័យថា មិនមានកាលៈទេសៈណាមួយសិទ្ធិនេះមិនត្រូវបានដកហូត។ មិនថានៅក្នុងបរិបទណាក៏ដោយ បដិប្បញ្ញត្តិគឺមិនត្រូវបានអនុញ្ញាតឡើយ មិនថាក្នុងគ្រាមានជម្លោះ ឬក្នុងគោលបំណងរក្សាសន្តិសុខជាតិ ហើយមិនថាបុគ្គលនោះស្ថិតក្នុងឋានៈជាឧក្រិដ្ឋជន ឬសង្ស័យជាភេរវករនោះទេ គ្មានកាលៈទេសៈណាដែលការធ្វើទារុណកម្ម និងអំពើទុច្ចរិតត្រូវបានផ្តល់ភាពត្រឹមត្រូវឡើយ។ លើសពីនេះ សេចក្តីថ្លែង ឬភស្តុតាងណាមួយដែលទទួលបានតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើទុក្ខទោសផ្សេងទៀត ត្រូវតែបដិសេធ ចោល។[117] ផ្ទុយទៅវិញ នេះជាភស្តុតាងដែលអាចប្រើតែជាមូលដ្ឋាន ដើម្បីបញ្ជាក់ថាមានអំពីបង្ខិតបង្ខំធ្វើទារុណកម្ម ឬធ្វើទុក្ខទោសផ្សេងៗ។[118]

ដូចដែលបានកំណត់ក្នុងបទដ្ឋាន និងការអនុវត្តសិទ្ធិមនុស្សអន្តរជាតិ ក្នុងការទទួលបានមេធាវីភ្លាមៗបន្ទាប់ពីបុគ្គលម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ពួកគេ គឺជាការការពារជាមូលដ្ឋានមួយប្រឆាំងនឹងការប្រើប្រាស់ការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើទុក្ខទោសលើបុគ្គលដែលត្រូវបានឃាត់ ឬឃុំខ្លួន។[119] យោងតាម

---

ECtHR, *Beckles* និងចក្រភពអង់គ្លេស (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២) ពាក្យស្នើសុំលេខ ៤៤៦៥២/៩៨ វាក្យខណ្ឌ ៥៨ https://tinyurl.com/3bw72a74

[115] ដូចខាងលើ.

[116] អ.ស.ក មាត្រា ៤០(២)(ខ)(iv)។

[117] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ លេខ ៣២ វាក្យខណ្ឌ ៤១

[118] ដូចខាងលើ.

[119] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ លេខ ៣២, ទ៣៤ គណៈកម្មការអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្ម (UNCAT) សេចក្តីពន្យល់ទូទៅ លេខ ២, CAT/C/GC/២ (ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨) ទ១៣ https://tinyurl.com/UNCAT-GC-2 , UNGA, "របាយការណ៍បណ្តោះអាសន្នរបស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក, A/៧១/២៩៨, (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦) https://tinyurl.com/UNSR-Torture-2016 *ECtHR*, Salduz នឹងប្រទេសតួកគី (ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨) ៣៦៣៩១/០២ វាក្យខណ្ឌ ៥៥ https://tinyurl.com/ECHR-Salduz-v-Turkey, គណៈកម្មការអាហ្វ្រិកសម្រាប់សិទ្ធិមនុស្ស និងប្រជាជន "គោលការណ៍ និងឯកសារណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជំនួយផ្នែកច្បាប់នៅអាហ្វ្រិក" (ឆ្នាំ២០០៣) M(១)(F) https://tinyurl.com/ACHPR-Guidelines, UNGA, "គោលការណ៍ និងឯកសារណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ៖ សេចក្តីសម្រេច/អនុម័តដោយមហាសន្និបាត" A/RES/៦៧/១៨៧, (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣), https://tinyurl.com/UNGA-Res-

ច្បាប់កម្ពុជា ជាពិសេស មាត្រា ៩៨ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "បន្ទាប់ផុតរយៈពេលម្ភៃបួនម៉ោងនៃការឃាត់ខ្លួននៅជំណាក់កាលនគរបាល អ្នកជាប់ឃុំអាចស្នើសុំនិយាយជាមួយមេធាវី ឬអ្នកផ្សេងទៀតដែលខ្លួនចង់ជួបបាន" ។ ដូច្នេះ បញ្ញត្តិនេះមិនសមស្របនឹងកាតព្វកិច្ចរបស់កម្ពុជាចំពោះច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិនោះទេ ដោយសារវាធ្វើឱ្យបុគ្គលម្នាក់ៗប្រឈមនឹងហានិភ័យនៃការបង្ខិតបង្ខំ ការធ្វើទារុណកម្ម និង/ឬ ការធ្វើទុក្ខទោស ដោយសារតែការអំឡុងពេលឃាត់ខ្លួន ២៤ ម៉ោងដំបូងនេះ គឺពិតជាសារៈសំខាន់បំផុតសម្រាប់ការទប់ស្កាត់ពីការធ្វើទារុណកម្ម ដោយហេតុថា នេះគឺជាពេលដែលបុគ្គលនោះស្ថិតក្នុងភាពងាយរងគ្រោះបំផុត។[120]

ដូចដែលអនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិដ៏ឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាបបានបញ្ជាក់ថា "ការធ្វើទារុណកម្ម និងការធ្វើទុក្ខទោសនៅកន្លែងឃុំឃាំងមិនមែនកើតឡើងតែស្ថានភាពនេះទេ តែជាងនេះទៅទៀត គឺដោយសារការខ្វះចន្លោះនូវបទប្បញ្ញត្តិ និងភាពអសកម្មរបស់តុលាការដែលបង្កើតឱ្យមានការអនុវត្តជាក់ស្តែងបែបនេះ"។[121] អនុគណៈកម្មាធិការបានផ្តល់អនុសាសន៍ជូនថា រដ្ឋភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មដែលប្រទេសកម្ពុជាជាប្រទេសហត្ថលេខីមួយតាំងពីឆ្នាំ ២០០៧ មក ត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុម័ត "វិធានការច្បាប់ រដ្ឋបាលតុលាការ ឬវិធានការផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់អំពើទារុណកម្មលើដែនដីណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន"។[122]

គួររំឭកផងដែរថា នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់ខ្លួនសម្រាប់ការពិនិត្យលើប្រទេសកម្ពុជាក្នុងឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិមនុស្សបានសម្តែងការព្រួយបារម្ភថា ទោះបីជាមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ ហាមឃាត់ការធ្វើទារុណកម្ម និងអំពើឃោរឃៅ ប៉ុន្តែច្បាប់នេះ មិនបានផ្តល់និយមន័យផ្លូវច្បាប់ណា

---

67-187 , កម្មាធិការអឺរ៉ុបស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប "ការទទួលបានមេធាវីដើម្បីជាមធ្យោបាយនៃការបង្ការការធ្វើបាប" CPT/Inf (ឆ្នាំ២០១១) ២៨-ផ្នែកទី ១ (ឆ្នាំ២០១១), https://tinyurl.com/CPTAccesstoLawyer

120 ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីកាស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប *Manfred Nowak",* A/HRC/១៣/៣៩, (ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០១០), ៥២ https://tinyurl.com/UNSR-Torture-2010, UNGA, "របាយការណ៍បណ្តោះអាសន្នរបស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" A/៦៨/២៩៥, (ថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១៣), ទ៧៣ https://tinyurl.com/UNSR-Torture-rep-2013, ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងសំណួរនៃការធ្វើទារុណកម្ម និងការឃុំខ្លួន" E/CN.4/២០០៣/៦៨, (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០២) ទ២៦(ធ) https://tinyurl.com/គណៈកម្មាធិការសិទ្ធិមនុស្ស-Torture-2002

121 អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប "សេចក្តីថ្លែងការណ៍បណ្តោះអាសន្នស្តីពីតួនាទីនៃការត្រួតពិនិត្យប្រព័ន្ធតុលាការ និងដំណើរការត្រឹមត្រូវក្នុងការទប់ស្កាត់ការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ ដែលអនុម័តដោយអនុគណៈកម្មាធិការស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាបផ្សេងទៀត។ CAT/OP/១ (ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២)&១៨ https://tinyurl.com/CAT-OP-2012

122 ដូចខាងលើ.

មួយអំពីការធ្វើទារុណកម្ម និងការធ្វើបាបនោះឡើយ។[123] គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរនូវការព្រួយបារម្ភរបស់ខ្លួនពាក់ព័ន្ធនឹងសមត្ថភាពដែលគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ដើម្បីចុះទស្សនកិច្ចទៅកាន់ពន្ធនាគារ និងសម្ភាសន៍អ្នកជាប់ឃុំ ក៏ដូចជាឯករាជ្យភាពរបស់ខ្លួន។ [124] លើសពីនេះ គណៈកម្មាធិការក៏មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចោទប្រកាន់ធ្ងន់ធ្ងរអំពីទារុណកម្ម និងការធ្វើបាបដែលកើតឡើងនៅក្នុងមណ្ឌលឃាត់ខ្លួនរបស់នគរបាល និងកន្លែងឃុំឃាំងផ្សេងទៀតដែលក្នុងករណីខ្លះបានបណ្តាលឱ្យស្លាប់ផងដែរ។[125]

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោម ៨២២ នាក់ បានលើកឡើងថាពួកគាត់ត្រូវបានស្តាប់ចម្លើយដោយគ្មានវត្តមានមេធាវីនោះទេនៅដំណាក់ស៊ើបអង្កេត។ នេះគឺជាឆ្នាំទី២ហើយ ដែលមិនមានករណីបែបនេះត្រូវបានរាយការណ៍ និងចំណែកឆ្នាំ២០២២ ម.ស.ម.ក បានកត់ត្រា មានប្រាំមួយនាក់។ ក្នុងឆ្នាំ២០២៤ ជនជាប់ចោទចំនួន ២នាក់ ក្នុងចំណោម ៧២៣ នាក់ បានរាយការណ៍ថា ពួកគេរងការគំរាមកំហែងឱ្យសារភាព។ ករណីនេះកើតឡើងនៅសាលាឧទ្ធរណ៍ភ្នំពេញ ដែលជាចំណុចគួរកត់សម្គាល់ និងយកចិត្តទុកដាក់ដើម្បីធានាការលើកកម្ពស់សិទ្ធិនេះ។ ទោះបីជាយ៉ាងណាជាតួលេខនេះមានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០២៣ មានជនជាប់ចោទចំនួន ៥ នាក់ បានរាយការណ៍ថាមានការគំរាមកំហែង (១នាក់នៅសាលាឧទ្ធរណ៍ភ្នំពេញ ១ នាក់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងបីទៀតនៅសាលាឧទ្ធរណ៍បាត់ដំបង)។

*តួលេខទី ២២៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង*[126]




ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទិននឹងចំណុចនេះ គួរមានការកត់សម្គាល់ថា មានចំនួន ២% (១៥ ក្នុងចំណោម ៧២០ នាក់ដែលជាជនជាប់ចោទ ឬមេធាវីរបស់ពួកគេបានចូលរួមសវនាការ) បានលើកឡើងថាខ្លួនទទួលរងនូវអំពើហិង្សា ឬការធ្វើទារុណកម្ម ដើម្បីឱ្យផ្តល់ចម្លើយសារភាពក្នុងអំឡុងពេលស៊ើបអង្កេតដោយ

[123] គណៈកម្មាធិការសិទ្ធិមនុស្ស (HRC) "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយលើរបាយការណ៍តាមកាលកំណត់របស់កម្ពុជា (CCPR/C/KHM/CO/៣), វាក្យខណ្ឌទី ២២, https://tinyurl.com/HRC-Concluding-Obs-2022

[124] ដូចខាងលើ.

[125] គណៈកម្មាធិការសិទ្ធិមនុស្ស "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ" វាក្យខណ្ឌ ២២

[126] ទិន្នន័យនេះ គឺផ្អែកលើចំនួនជនជាប់ចោទសរុបដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ទាំងជនជាប់ចោទ និងមេធាវីជនជាប់ចោទ មិនមានវត្តមាន ដូច្នេះហើយគ្មាននរណាម្នាក់លើកពីបញ្ហានោះឡើយ។

មន្ត្រីនគរបាលយុត្តិធម៌។ តួលេខនេះ បង្ហាញថាមិនមានអ្វីប្រែប្រួលនោះទេ បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួន ១,៧% (១៦ ក្នុងចំណោម ៩១៩) ហើយឆ្នាំ២០២២ ដែលមានចំនួន ២,៥% (ជនជាប់ចោទ ១៧ នាក់)។ ទោះបីជាតួលេខនេះមានការធ្លាក់ចុះជាលំដាប់ចាប់តាំងពីឆ្នាំ ២០១៩-២០២០ យ៉ាងណាក៏ដោយ ម.ស.ម.ក កត់សម្គាល់ឃើញថា ការលើកឡើងពីការអំពើហិង្សា ឬការធ្វើទារុណកម្មមកលើជនសង្ស័យនៅក្នុងកន្លែងឃាត់ខ្លួនរបស់នគរបាលនៅតែមានជាបន្តបន្ទាប់ ពោលគឺឃើញថាមានការធ្លាក់ចុះចំនួនតិចតួច។ នេះគឺជាចំណុចគួរឱ្យយកចិត្តទុកដាក់ចាំបាច់ ដោយសារការហាមឃាត់ការធ្វើទារុណកម្ម គឺមានលក្ខខណ្ឌពិសេសនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិថាជាបទដ្ឋានដាច់ខាត។

*តួលេខទី ២៣៖ និន្នាការពាក់ព័ន្ធនឹងការលើកឡើងរបស់ជនជាប់ចោទពីអំពើហិង្សា ឬការធ្វើទារុណកម្មពីសំណាក់នគរបាលយុត្តិធម៌ ដើម្បីបង្ខិតបង្ខំឱ្យសារភាពនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅទាំងបួន (ចាប់ពីឆ្នាំ២០២២)*[127]




**វាក្យសព្ទច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ៖**

- **សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាន៖** សិទ្ធិដែលរដ្ឋាភិបាលមិនអាចព្យួរការអនុវត្តបានក្នុងកាលៈទេសៈនៃ "ការដាក់ប្រទេសក្នុងគ្រាអាសន្ន" ក្រោមមាត្រា ៤ នៃ ក.អ.ស.ព.ន។
- ***សិទ្ធិដាច់ខាត៖*** សិទ្ធិដែលមិនត្រូវបានអនុញ្ញាតឱ្យមានការរិតត្បិតណាមួយ។
- **បទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិទូទៅ (ជូស ខូស្សិន)៖** "បទដ្ឋានដែលត្រូវបានសហគមន៍អន្តរជាតិនៃបណ្តារដ្ឋទាំងអស់ទទួលយក និងទទួលស្គាល់ថាជាបទដ្ឋានមួយដែលមិនអាចធ្វើបដិប្បញ្ញត្តិ

---

[127] ទិន្នន័យនេះផ្អែកលើភាគរយនៃជនជាប់ចោទដែលបានលើកឡើងថា មានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មមកលើពួកគេដើម្បីបង្ខិតបង្ខំពួកគេឱ្យសារភាពចំពោះបទល្មើសដែលចោទប្រកាន់មកលើពួកគេនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ (រហូតដល់ឆ្នាំ២០២១) និងភាគរយជនជាប់ចោទដែលបានលើកឡើងដូចគ្នានៅចំពោះមុខតុលាការគោលដៅទាំងបួន ក្នុងសំណុំរឿងដែលជនជាប់ចោទ ឬមេធាវីរបស់ពួកគេមានវត្ត មានចូលរួមសវនាការ (ចាប់ពីឆ្នាំ២០២២ ទៅ)។ ដោយហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្តប់ទូទាំងប្រទេស មុនពេលដែល សាលាឧទ្ធរណ៍ទាំងបីចាប់ផ្តើមដំណើរការ ក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការទាំងមូល។ និន្នាការនេះក៏ត្រូវអនុវត្តចំពោះតួលេខចាប់ពីឆ្នាំ២០២២ ទៅមុខដែរ ក្នុងពេលដែល ម.ស.ម.ក បានចាប់ផ្តើមសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីនោះ។ តួលេខក្នុងឆ្នាំ២០២១ ត្រូវបានបង្ហាញពីចន្លោះទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពដែលស្ថិតក្រោមយុត្តាធិការរបស់សាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។

បាន ហើយអាចកែប្រែបានតាមរយៈបទដ្ឋានដែលនៅក្រោមច្បាប់អន្តរជាតិទូទៅដែលមានលក្ខណៈដូចគ្នាតែប៉ុណ្ណោះ”។[128]

## សាលាឧទ្ធរណ៍ភ្នំពេញ

នៅឆ្នាំ២០២៤ ការលើកឡើងថាមានការធ្វើទារុណកម្ម និងហិង្សាក្នុងកន្លែងឃាត់ខ្លួនរបស់នគរបាលភាគច្រើននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ បើធៀបនឹងឆ្នាំ២០២៣ មានការប្រែប្រួល ដែលពេលនោះករណីភាគច្រើន ត្រូវបានលើកឡើងដោយជនជាប់ចោទនៅចំពោះមុខសាលាឧទ្ធរណ៍ព្រះសីហនុ។ មានជនជាប់ចោទចំនួន ១១ នាក់ ដែលបានលើកឡើងថា ខ្លួនបានទទួលរងការធ្វើទារុណកម្ម និងហិង្សានៅចំពោះមុខតុលាការភ្នំពេញ ដែលតួលេខនេះបង្ហាញថាមានការកើនឡើងស្ទើរតែបីដងបើធៀបនឹងឆ្នាំ ២០២៣ មានតែ ៤ នាក់ប៉ុណ្ណោះ ។ គួរកត់សម្គាល់ថានៅឆ្នាំ២០២៤ ជនជាប់ចោទបានលើកឡើងថាខ្លួនបានទទួលរងការគំរាមកំហែងឱ្យសារភាព គឺកើតមាននៅសាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ មិនមានការលើកឡើងបែបនេះនៅសាលាឧទ្ធរណ៍ផ្សេងទៀតទេ។ ចំណុចនេះ តុលាការមិនទាន់បានគោរពពេញលេញនៅឡើយចំពោះ សិទ្ធិមិនត្រូវបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង។

ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក ពាក់ព័ន្ធនឹងការរកឃើញរបស់ខ្លួននេះ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ បានថ្លែងថា ជនជាប់ចោទអះអាងថាពួកគេត្រូវបានគេធ្វើទារុណកម្ម ដើម្បីគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ទោះជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍បានលើកឡើងថា ក្នុងករណីដែលជនចោទលើកឡើងថាខ្លួនទទួលរងការធ្វើទារុណកម្ម ឬអំពើហិង្សា សាលាឧទ្ធរណ៍នឹងធ្វើការស៊ើបអង្កេតឡើងវិញ ក្នុងករណីដែលសាលាដំបូងមិនបានស៊ើបអង្កេតលើចំណុចនេះឱ្យបានហ្មត់ចត់ ឬមិនមានចាត់វិធានការណាមួយជាក់លាក់។ សាលាឧទ្ធរណ៍ក៏បានបញ្ជាក់ផងដែរថា ខ្លួននឹងណែនាំឱ្យសាលាដំបូង ធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវអំពីការលើកឡើងរបស់ជនជាប់ចោទពាក់ព័ន្ធនឹងការធ្វើទារុណកម្ម និងអំពើហិង្សានេះ។[129]

## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបង មានការវិវឌ្ឍល្អប្រសើរក្នុងឆ្នាំ២០២៤ ដោយមិនមានការលើកឡើងណាមួយពីជនជាប់ចោទថាមានការគំរាមកំហែងនៅដំណាក់កាលស៊ើបអង្កេតនោះទេ បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួន ៣ នាក់។[130] ទោះបីជាយ៉ាងណា មានការលើកឡើងថាមានការធ្វើទារុណកម្ម និងហិង្សាលើជនជាប់ចោទ

---

[128] គណៈកម្មការច្បាប់អន្តរជាតិ "របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៅសម័យប្រជុំលើកទី ៧១ របស់ខ្លួន" សេចក្តីបន្ថែមលេខ ១០ (A/៧៤/១០) (ឆ្នាំ២០១៩) វាក្យខណ្ឌ ៥៦, https://tinyurl.com/42tkj27m

[129] នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើការរកឃើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[130] ម.ស.ម.ក របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ក្នុងប្រទេសកម្ពុជា (ថ្ងៃទី០១ ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣) ទំព័រ ៤៤-៤៥។

មានការថយចុះតិចតួចពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺមានចំនួន២ នាក់ក្នុងឆ្នាំ២០២៤ និង៣នាក់ នៅឆ្នាំ២០២៣។ ខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានលើកឡើងថា កន្លងមកជនជាប់ចោទមិនបានបដិសេធចម្លើយរបស់គាត់នោះទេ នៅដំណាក់កាលមុនៗ ដូចជា ដំណាក់កាលចោទប្រកាន់ ស៊ើបសួរ និងជំនុំជម្រះនៅសាលាដំបូង ផ្ទុយទៅនៅក្នុងសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទបានបដិសេធចម្លើយរបស់គាត់ និងបានលើកហេតុផលថា ការផ្តល់ចម្លើយទាំងនោះមានការបង្ខិតបង្ខំ ឬហិង្សាដោយនគរបាលយុត្តិធម៌ តែជនជាប់ចោទទាំងនោះគ្មានអ្វីជាសំអាងនោះទេ។ ម្យ៉ាងទៀត បើសិនសាលាឧទ្ធរណ៍បានដឹងថាមានការបដិសេធចម្លើយដែលមានក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ នុះតុលាការនឹងកោះហៅមន្ត្រីដែលរងការចោទប្រកាន់មកសាកសួរ ប៉ុន្តែជនជាប់ចោទទើបតែលើកពីបញ្ហានេះក្នុងអំឡុងពេលសវនាការសាលាឧទ្ធរណ៍។[131]

### សាលាឧទ្ធរណ៍ព្រះសីហនុ

នៅឆ្នាំ២០២៤ សាលាឧទ្ធរណ៍ព្រះសីហនុ មានវឌ្ឍនភាពមួយចំនួនពាក់ព័ន្ធនឹងការគោរពសិទ្ធិមិនត្រូវបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ដោយពុំមានជនជាប់ចោទណាម្នាក់បានលើកឡើងថាមានការគំរាមកំហែងមកលើខ្លួននៅដំណាក់កាលស៊ើបអង្កេត នៅចំពោះមុខតុលាការក្នុងអំឡុងពេលធ្វើបាយការណ៍នេះនោះទេ។ មានតែពីរនាក់ប៉ុណ្ណោះដែលជនជាប់ចោទដែលលើកឡើងថាបានទទួលរងការធ្វើទារុណកម្ម ឬហិង្សានៅក្នុងកន្លែងឃាត់ខ្លួនរបស់នគរបាល បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨ នាក់ ដែលនេះបង្ហាញពីការថយចុះ ។

### សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំតែមួយគត់ក្នុងចំណោមតុលាការគោលដៅទាំងបួន ដែលមិនមានការលើកឡើងពីជនជាប់ចោទថាមានការគំរាមកំហែង និងការធ្វើទារុណកម្ម ឬហិង្សាលើពួកគេ។ ដូចនេះ មិនមានការប៉ះពាល់ដល់សិទ្ធិមិនត្រូវបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯងនោះឡើយ។ នេះជាចំណុចប្រសើរគួរឱ្យកត់សម្គាល់ពីវឌ្ឍនភាពល្អប្រសើរជាងឆ្នាំមុន ដែលកាលនោះមានតែមួយនាក់ប៉ុណ្ណោះ។ ដូចនេះ សូមឱ្យតុលាការ បន្តការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បន្ថែមទៀត។

## ៤.៦ ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា |
|---|---|

[131] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ក្រមសីលធម៌ចៅក្រមកម្ពុជា |
|---|---|---|---|
| មាត្រា ១៤(១) និង ១៤(៥) | មាត្រា ១២៨ និង ១៣២ | មាត្រា ៨, ៥០ និង ៧៧ | មាត្រា ២ និង ៨ |

មាត្រា ១៤(១) នៃ ក.អ.ស.ព.ន ធានាសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច និងមិនលម្អៀង គឺជាសសរស្តម្ភនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[132] ប្រសិនបើគ្មានការគោរពសិទ្ធិនេះទេ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ផ្សេងទៀតលែងមានប្រយោជន៍ហើយ។ ជាការពិត សាលាជម្រះក្តីដែលមិនមានសមត្ថកិច្ច និងលម្អៀង មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌ឱ្យបានត្រឹមត្រូវនោះទេ។ ដូចនេះ ចៅក្រមត្រូវតែប្រកាន់ខ្ជាប់វិជ្ជាជីវៈគ្រប់ពេលដើម្បីបង្ហាញថាមានសមត្ថកិច្ច និងមិនលម្អៀង។

វិសាលភាពដែលតុលាការបំពេញកាតព្វកិច្ចនៃភាពមិនលំអៀងនេះ ត្រូវបានលើកឡើងថាជាចំណុចនៃការព្រួយបារម្ភដោយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ទោះបីជារដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីពង្រឹងឯករាជ្យភាពរបស់ខ្លួនក៏ដោយ។[133] ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងវដ្តទីបួននៃ «យូភីអ» នាពេលថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួនបីទាក់ទងនឹងប្រព័ន្ធតុលាការ និងឯករាជ្យភាពតុលាការ ដែលជាការបង្ហាញអំពីការលើកទឹកចិត្តថា រដ្ឋាភិបាលមានបំណងបន្តធ្វើការដើម្បីដោះស្រាយបញ្ហានេះ។

នៅកម្ពុជា ការប្រតិបត្តិរបស់ចៅក្រម គឺមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ចៅក្រមកម្ពុជា ដែលតម្រូវឱ្យចៅក្រមមិនរងសម្ពាធពីគ្រប់ទម្រង់នៃឥទ្ធិពលណាមួយពីសំណាក់គូភាគី ឬបុគ្គល ក្រុម ឬស្ថាប័នណាមួយ និងធ្វើសេចក្តីសម្រេចលើសំណុំរឿងដោយមនសិការ ការគោរព ការអត់ធ្មត់ សុជីវធម៌ និងសីលធម៌បំផុត ដើម្បីធានានូវយុត្តិធម៌ជូនដល់ភាគី។ ហេតុដូច្នេះហើយ តុលាការត្រូវចំណាយពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីសិក្សាសំណុំរឿងឱ្យបានហ្មត់ចត់ ក្នុងគោលបំណងធានាថាសំណុំរឿងត្រូវបានវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងច្បាស់លាស់ ហើយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពយ៉ាងពេញលេញ។

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ និងសម្រាប់រយៈពេលបីឆ្នាំជាប់ៗគ្នា គ្មានចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់ បានរើសអើងចំពោះភាគីណាមួយឡើយ រួមទាំងជនជាប់ចោទផងដែរ។ សាទរ ចំពោះការប្រតិបត្តិល្អរបស់ចៅក្រម និងព្រះរាជអាជ្ញាដែលគ្មានការបំភិតបំភ័យឬប្រើពាក្យសំដីមិនសមរម្យដល់ភាគីណាមួយនោះទេ។

[132] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/3s3n2489

[133] គណៈកម្មាធិការសិទ្ធិមនុស្ស "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ" វាក្យខណ្ឌ ៣២

ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច (ទូរស័ព្ទ អាយផេត ថេប្លេត ជាដើម) ដោយចៅក្រម ព្រះរាជអាជ្ញា ឬមេធាវីការពារក្តី សរុបមានចំនួន ៨ ករណី។ ចំនួន ៣ ករណី គឺពាក់ព័ន្ធនឹងនឹងចៅក្រម ៤ ករណី ពាក់ព័ន្ធនឹងព្រះរាជអាជ្ញា និង១ករណីពាក់ព័ន្ធនឹងមេធាវីការពារក្តី។ សាលាឧទ្ធរណ៍បាត់ដំបង មានករណីនេះច្រើនជាងគេក្នុងចំណោមតុលាការគោលដៅទាំងបួន ក្នុងនោះមាន ៦ ករណីក្នុងចំណោម ៨ ករណី បានកើតឡើងនៅសាលាឧទ្ធរណ៍បាត់ដំបង ចំនួន ២ ករណីគឺចៅក្រមបានសន្ទនាតាមទូរស័ព្ទដោយខ្លី ៣ ករណីគឺព្រះរាជអាជ្ញា ក្នុងនោះមានចំនួន ១ ករណី គឺបន្តការសន្ទនាតាមទូរស័ព្ទ និង១ ករណីទៀតដោយមេធាវីការពារក្តីសន្ទនាតាមទូរស័ព្ទខ្លី។ មានការកើនឡើងនូវចំនួនករណីនេះគួរកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៣ មានករណីចំនួន២ ប៉ុណ្ណោះដែលចៅក្រម និងព្រះរាជអាជ្ញាប្រើទូរស័ព្ទក្នុងអំឡុងពេលដំណើរការនីតិវិធី។

នៅសាលាឧទ្ធរណ៍ព្រះសីហនុមានចំនួន ២ ករណី ដែលចៅក្រមម្នាក់បានសន្ទនាតាមទូរស័ព្ទខ្លី និងព្រះរាជអាជ្ញាម្នាក់បានបន្តសន្ទនាតាមទូរស័ព្ទ។ មិនមានករណីមេធាវីការពារធ្វើការសន្ទនាតាមទូរស័ព្ទ នៅឆ្នាំ ២០២៣ នោះទេ ដែលនេះជាការប្រសើរ តែក្នុង ឆ្នាំ២០២៤ មានចំនួន ១ ករណី។ សាលាឧទ្ធរណ៍ភ្នំពេញ និង សាលាឧទ្ធរណ៍ត្បូងឃ្មុំ អនុវត្តបានល្អ ដោយមិនមានករណីប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចដោយតួអង្គណាម្នាក់ឡើយ ដូចនេះ សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ដោយយុត្តិធម៌ មិនលម្អៀង ត្រូវបានគោរពតាមនៅតុលាការទាំងពីរនេះ។

ពាក់ព័ន្ធនឹងរយៈពេលសវនាការ ដោយសារតែមិនមានបទដ្ឋានកំណត់ណាមួយដែលណែនាំនឹងរយៈពេលសវនាការ ដូចនេះ ម.ស.ម.ក មិនចាត់ទុកថាជាកត្តាកំណត់ជាផ្លូវការនោះទេ នៅពេលកំណត់ថាថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច និងមិនលំអៀង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំណុចនេះនៅតែមានភាពពាក់ព័ន្ធចាំបាច់គួរតែលើកឡើងក្នុងរបាយការណ៍នេះផងដែរ ដោយសារ រយៈពេលសវនាការភាគច្រើននៅតុលាការគោលដៅទាំងបួន មានរយៈពេលខ្លី។

*តួលេខទី ២៤៖ រយៈពេលនៃសវនាការដែលបានសង្កេត នៅតាមតុលាការគោលដៅ*[134]

## ទិន្នន័យជារួម

| រយៈពេលសវនាការ | ១៥ នាទីចុះក្រោម | ១៦-៣០ នាទី | ៣១ នាទី–១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| **បទឧក្រិដ្ឋ** | ៧១ | ៧៦ | ៤៦ | ២១ | ២១៤ |
| **បទមជ្ឈិម** | ១៦៨ | ១០១ | ៦២ | ២៧ | ៣៥៨ |
| **បទលហុ** | ៥ | ៣ | ១ | ១ | ១០ |
| **សរុប** | **២៤៤** | **១៨០** | **១០៩** | **៤៩** | **៥៨២** |
| **សរុបជា %** | **៤២%** | **៣១%** | **១៨%** | **៨%** | **១០០%** |

[134] ទិន្នន័យនេះ ផ្អែកលើរយៈពេលនៃសវនាការដែលបានកត់ត្រាសម្រាប់សំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតក្នុងឆ្នាំ២០២៤។

## សាលាឧទ្ធរណ៍ភ្នំពេញ

| រយៈពេលសវនាការ | ១៥ នាទីចុះក្រោម | ១៦-៣០ នាទី | ៣១ នាទី–១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ៥១ | ៤៦ | ១៨ | ៥ | ១២០ |
| បទមជ្ឈិម | ៨៨ | ៣៧ | ១៣ | ១៣ | ១៥១ |
| បទលហុ | ២ | ២ | ១ | ០ | ៥ |
| សរុប | ១៤១ | ៨៥ | ៣២ | ១៨ | ២៧៦ |
| សរុបជា% | ៥១% | ៣១% | ១២% | ៧% | ១០០% |

## សាលាឧទ្ធរណ៍បាត់ដំបង

| រយៈពេលសវនាការ | ១៥ នាទីចុះក្រោម | ១៦-៣០ នាទី | ៣១ នាទី–១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ២០ | ១៩ | ១៤ | ៥ | ៥៨ |
| បទមជ្ឈិម | ៧១ | ៣១ | ១៨ | ១ | ១២១ |
| បទលហុ | ២ | ១ | ០ | ០ | ៣ |
| សរុប | ៩៣ | ៥១ | ៣២ | ៦ | ១៨២ |
| សរុបជា% | ៥១% | ២៨% | ១៨% | ៣% | ១០០% |

## សាលាឧទ្ធរណ៍ព្រះសីហនុ

| រយៈពេលសវនាការ | ១៥ នាទីចុះក្រោម | ១៦-៣០ នាទី | ៣១ នាទី–១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ០ | ៥ | ២ | ៥ | ១២ |
| បទមជ្ឈិម | ៤ | ១១ | ៤ | ៤ | ២៣ |
| បទលហុ | ១ | ០ | ០ | ០ | ១ |
| សរុប | ៥ | ១៦ | ៦ | ៩ | ៣៦ |
| សរុបជា% | ១៤% | ៤៤% | ១៧% | ២៥% | ១០០% |

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

| រយៈពេលសវនាការ | ១៥ នាទីចុះក្រោម | ១៦-៣០ នាទី | ៣១ នាទី–១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ០ | ៦ | ១២ | ៦ | ២៤ |
| បទមជ្ឈិម | ៥ | ២២ | ២៧ | ៩ | ៦៣ |
| បទលហុ | ០ | ០ | ០ | ១ | ១ |
| សរុប | ៥ | ២៨ | ៣៩ | ១៦ | ៨៨ |
| សរុបជា% | ៦% | ៣២% | ៤៤% | ១៨% | ១០០% |

យោងតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្ស សិទ្ធិទទួលបានការពិនិត្យឡើងវិញលើការកាត់ទោសរបស់បុគ្គលម្នាក់ ដោយសាលាក្ដីជាន់ខ្ពស់មួយ កំណត់ឱ្យរដ្ឋភាគីមានកាតព្វកិច្ចពិនិត្យយ៉ាងហ្មត់ចត់ផ្អែកលើភស្តុតាង និងច្បាប់ ការផ្តន្ទាទោស និងការកាត់ទោស ដែលនីតិវិធីនេះអនុញ្ញាតឱ្យមានការពិចារណាយ៉ាងត្រឹមត្រូវលើលក្ខណៈនៃសំណុំរឿង។ មុននឹងសម្រេចថាតើមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃការរកឃើញថាមានពិរុទ្ធភាព ឬយ៉ាងណា តុលាការជាន់ខ្ពស់ត្រូវពិនិត្យមើលការចោទប្រកាន់ដែលប្រឆាំងនឹងជនជាប់ចោទឱ្យបានលម្អិត ហើយពិចារណាលើភស្តុតាងដែលបានដាក់ជូននៅពេលសវនាការ និងការបញ្ជូនបន្តនៅពេលមានការប្តឹងឧទ្ធរណ៍។[135] ទោះបីជាមិនមានបទដ្ឋានណាមួយកំណត់ក៏ដោយ ប៉ុន្តែគេអាចឆ្លុះបញ្ចាំងថា សវនាការដែលមានរយៈពេលតិចជាង ៣០ នាទី ជាពិសេសនៅពេលដែលសវនាការនោះគឺពាក់ព័ន្ធនឹងបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ជាការលំបាកយ៉ាងខ្លាំងក្នុងការបង្កបរិយាកាសអំណោយផលដល់ភាគីនៃសំណុំរឿងឱ្យបានពេញលេញក្នុងសវនាការ ហើយចៅក្រមក៏អាចលំបាកក្នុងការពិនិត្យមើលករណីនេះគ្រប់ជ្រុងជ្រោយផងដែរ។

នៅសាលាឧទ្ធរណ៍ភ្នំពេញ សវនាការចំនួន ៥១% ធ្វើឡើងក្នុងរយៈពេលត្រឹមតែ ១៥ នាទី ឬតិចជាងនេះ (១៤១ ក្នុងចំណោម ២៧៦សំណុំរឿង) និង៣១% ចំណាយពេលពី ១៦ ទៅ ៣០ នាទី។ តួលេខនេះបង្ហាញថាមិនមានការប្រែប្រួលណាមួយឡើយនៅក្នុងរយៈពេលពីរឆ្នាំនេះ ព្រោះនៅឆ្នាំ២០២៣ សំណុំរឿងចំនួន ៨១% ចំណាយពេលចំនួន ៣០ នាទី ចុះក្រោម ហើយករណីបែបនេះមាន ៨១,៣%នៅឆ្នាំ២០២២។ ជាការកត់សម្គាល់ផងដែរថា មានសវនាការចំនួន១៤១ ដែលចំណាយពេលត្រឹមតែ ១៥ នាទី ឬក្រោមនេះ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានសំណុំរឿង៣៦% ជាបទឧក្រិដ្ឋ ដែលបង្ហាញការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួនត្រឹមតែ ២៨%។ នៅក្នុងការពិគ្រោះយោបល់ពីមុនជាមួយ ម.ស.ម.ក សាលាឧទ្ធរណ៍ភ្នំពេញ និងតំណាងមហាអយ្យការបានលើកឡើងថា សវនាការអាចមានរយៈពេលខ្លី នៅពេលដែលមានជនជាប់ចោទតែម្នាក់ នៅពេលដែលជនជាប់ចោទអវត្តមាន ឬជនជាប់ចោទបានសារភាពរួចហើយ ឬនៅពេលដែលមានភស្តុតាងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឈានទៅដល់ការសម្រេចដោយមិនចាំបាច់មានការជជែកវែកញែកច្រើន។[136] តុលាការបានបញ្ជាក់ថា សវនាការដែលមានរយៈពេល ១៥ នាទី ឬតិចជាងនេះ គឺផ្អែកលើស្ថានភាពសំណុំរឿង ដូចជាបណ្តឹងឧទ្ធរណ៍ដែលមិនត្រឹមត្រូវខុសលក្ខខណ្ឌច្បាប់ការដកបណ្តឹងឧទ្ធរណ៍អវត្តមានភាគីឬបទល្មើសមជ្ឈិម[137]

មិនខុសគ្នាប៉ុន្មានពីសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍បាត់ដំបងមានចំនួន ៥១% នៃសវនាការនេះប្រើរយៈពេលត្រឹម ១៥ នាទី ឬក្រោមនេះ និង ២៨% ប្រើរយៈពេលត្រឹមតែ ១៦ ទៅ៣០ នាទីប៉ុណ្ណោះ។ លើស

[135] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣២។

[136] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើការរកឃើញដែលនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[137] លិខិតលេខ ៧០៦/២៤ ចេញថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ ដោយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបទៅនឹងការរកឃើញនៃរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ ម.ស.ម.ក ស្តីពីសិទ្ធិជំនុំជម្រះដោយយុត្តិធម៌។

ពីនេះ ក្នុងចំណោមសវនាការដែលមានរយៈពេល៣០ នាទី ឬតិចជាងនេះ ៦៧%ជាសំណុំរឿងបទឧក្រិដ្ឋ។ មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ ដោយសារមានតួលេខស្រដៀងគ្នាគឺ ៧៨% នៃសវនាការដែលមានរយៈពេល ៣០ នាទី ឬតិចជាងនេះក្នុងឆ្នាំ ២០២៣ និង ៧២%នៅឆ្នាំ២០២២។

សាលាឧទ្ធរណ៍ព្រះសីហនុ មានតួលេខកើនឡើងជាប់ៗគ្នា។ ក្នុងអំឡុងពេលនៃរបាយការណ៍ សវនាការដែលត្រូវបានសង្កេតចំនួន ៥៨% សវនាការបានប្រើរយៈពេល ៣០ នាទី ឬតិចជាងនេះ ដែលបានកើនឡើងបើធៀបនឹងឆ្នាំ ២០២៣ មានចំនួនត្រឹមតែ ៥៥% និង ៤៤,១%នៅឆ្នាំ២០២២។ ទោះបីជាយ៉ាងណាក៏ដោយ សាលាឧទ្ធរណ៍ព្រះសីហនុ មានតួលេខខ្ពស់ជាងគេក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន ទាក់ទងនឹងសវនាការដែលចំណាយពេលលើសពីមួយម៉ោងមានចំនួន ២៥% (៩ ក្នុងចំណោម ៣៦ សំណុំរឿង)។

សាទរចំពោះ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានបង្ហាញពីការកត់សម្គាល់ជាងគេពាក់ព័ន្ធនឹងរយៈពេលនៃសវនាការក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួន។ ក្នុងឆ្នាំ២០២៤ គឺ៤៤%(៣៩ ក្នុងចំណោម ៨៨ សំណុំរឿង) ប្រើរយៈពេលចន្លោះពី៣១ ទៅ៦០ នាទី និង ១៨% (១៦ ក្នុងចំណោម ៨៨ សំណុំរឿង) ប្រើរយៈពេលលើសពីមួយម៉ោង។ ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានសំណុំរឿងចំនួន ៥ (៦%) ដែលប្រើរយៈពេល ១៥ នាទី ឬតិចជាងនេះ ប៉ុន្តែមិនមែនជាបទឧក្រិដ្ឋទេ។ មានសំណុំរឿងជាបទឧក្រិដ្ឋចំនួន ៦ ដែលប្រើរយៈពេលត្រឹមតែ១៦ ទៅ៣០ នាទី ។

# ៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរពពេញលេញ

## ៥.១ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

| ច្បាប់កម្ពុជា |
| --- |
| ក្រមនីតិវិធីព្រហ្មទណ្ឌ |
| មាត្រា ៣៥៧ & មាត្រា ៤០៣ |

ដូចមានចែងនៅក្នុងច្បាប់កម្ពុជា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុជានាថា សេចក្តីសម្រេចព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាម្នាក់ ត្រូវតែមានការពន្យល់អំពីមូលហេតុ និងមូលដ្ឋានក្នុងការសម្រេច និងមូលហេតុដែលបង្ហាញថាបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព ឬគ្មានទោស។ [138] ដើម្បីសម្រេចគោលបំណងនេះ សាលក្រម/សាលដីកា ត្រូវតែបង្ហាញឱ្យបានលម្អិតគ្រប់គ្រាន់អំពីអង្គហេតុនៃសំណុំរឿង (កាលបរិច្ឆេទ ទីកន្លែង ហេតុការណ៍ជាក់ស្តែង) ចៅក្រមត្រូវសំអាងលើភស្តុតាង ដើម្បីឈានដល់ការចេញសាលក្រម/សាលដីកា និងត្រូវមានការពន្យល់អំពីសំអាងហេតុ និងច្បាប់ (ឧ. បទល្មើស និងរបៀបនៃការទទួលខុសត្រូវ៖ ចារី អ្នកសមគំនិត ។ល។) សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមាននៅក្នុងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនត្រឹមតែការពារជនជាប់ចោទប្រឆាំងនឹងសេចក្តីសម្រេចមិនត្រឹមត្រូវនោះទេ ប៉ុន្តែថែមទាំងការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍ផងដែរ។ យោងតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដើម្បីអនុវត្តសិទ្ធិនេះប្រកបដោយប្រសិទ្ធភាព ពិរុទ្ធជនមានសិទ្ធិទទួលបាននូវការពិនិត្យឡើងវិញលើការផ្តន្ទាទោស និងការកាត់ទោសដោយសាលាជម្រះក្តីជាន់ខ្ពស់ ហើយពិរុទ្ធជនមានសិទ្ធិទទួលបាននូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានសំអាងហេតុត្រឹមត្រូវនៅក្នុងពេលវេលាសមរម្យមួយសម្រាប់បណ្តឹងឧទ្ធរណ៍។[139] នៅក្នុងបរិបទកម្ពុជា ទាំងភាគីជនជាប់ចោទ និងតំណាងអយ្យការ មានសិទ្ធិប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូល ដើម្បីឱ្យពិនិត្យមើលលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ឡើងវិញ។

ក្នុងចំណោមសាលដីកាទាំងអស់ដែល ម.ស.ម.ក បានស្តាប់សាលដីកានៅតាមតុលាការគោលដៅទាំងបួន មានចំនួន ៧៣% (៥៨ ក្នុងចំណោម ៧៩ សំណុំរឿង) ដែលចៅក្រមខកខានបានផ្តល់សំអាងហេតុ ពោលគឺចៅក្រមគ្រាន់តែប្រកាសអំពីការសម្រេចនោះប៉ុណ្ណោះ។ តួលេខនេះ មានភាពល្អប្រសើរឡើងបន្តិចបន្តួច បើធៀបនឹងឆ្នាំ២០២៣ ដែលពេលនោះ មាន ៧៩,៩% និង ៨០,៩% ឆ្នាំ២០២២។ ទោះបីជាមានភាពប្រសើរដ៏គួរឱ្យកត់សម្គាល់ក៏ដោយ ក៏តួលេខនេះនៅតែមិនទាន់មានការប្រែប្រួលខ្លាំងនៅឡើយទេ ដូចនេះគួរតែមានវិធាន

---

[138] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលនៅក្នុងកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/5ssncyyy

[139] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣២០/១៩៨៨, V. Francis v. Jamaica (ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣), *GAOR*, A/៤៨/៤០ (vol. II), វាក្យខណ្ឌ ១២,២, https://tinyurl.com/275fa3sr

ការចាំបាច់សមស្រប ដើម្បីលើកកម្ពស់ការគោរពសិទ្ធិសំខាន់មួយនេះក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មានតែសំណុំរឿងចំនួន ៣១% (១១ ក្នុងចំណោម ៣៥) ប៉ុណ្ណោះ ដែលមេធាវីរបស់ជនជាប់ចោទមានវត្តមាននៅពេលប្រកាសសាលដីកា។ ថ្វីដ្បិតតែនេះជាអត្រាទាបមែន ប៉ុន្តែអត្រានេះមានភាពប្រសើរជាងមុន បើធៀបនឹងឆ្នាំមុន ដែលមានតែសំណុំរឿង ១១%(១៦ ក្នុងចំណោម ១៤៤) ប៉ុណ្ណោះ ដែលមេធាវីការពារមានវត្តមាននៅពេលប្រកាសសាលដីកា។

*តួលេខទី ២៥៖ ភាគរយនៃសវនាការបានសង្កេត ដែលចៅក្រមបានផ្តល់សំអាងហេតុពេលប្រកាសសាលដីកា*[140]




## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលចៅក្រមបានអានប្រាប់នូវសំអាងហេតុក្នុងសាលដីការបស់ខ្លួន។ សំណុំរឿងចំនួន ៦២,៥% (១០ ក្នុងចំណោម ១៦) ដែលតួលេខនេះ មានការកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ២៩,៦%។ នេះគឺជាវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានបន្តរក្សា និងពង្រឹងបន្ថែមទៅលើវឌ្ឍនភាពនេះ។ ចំណុចនេះ ក៏បង្ហាញពីឆន្ទៈធ្វើឱ្យប្រសើរ បើយោងតាមការបញ្ជាក់ដោយតំណាងសាលាឧទ្ធរណ៍ភ្នំពេញកាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ដែលកំពុងបង្ហាញអំពីប្រសិទ្ធផល។[141] តំណាងតុលាការក៏បានអះអាងផងដែរថា ចៅក្រមតែងតែអានប្រាប់ដោយសង្ខេបអំពីសំអាងហេតុលើសេចក្តីសម្រេចរបស់ខ្លួនដើម្បីឱ្យជនជាប់ចោទបានយល់ច្បាស់អំពីសំណុំរឿងរបស់ពួកគេ។ ចំពោះសាលាឧទ្ធរណ៍ភ្នំពេញបានប្រកាសសាលដីកាជាសាធារណៈចំនួន ១០០% រួមទាំងកាលបរិច្ឆេទនៃការប្រកាសសាលដីកាក៏បានជម្រាបជូនជាសាធារណៈក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍។ ចៅក្រមក៏បានយោងទៅលើច្បាប់ពាក់ព័ន្ធ និងភស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលសវនាការផងដែរ។ ពុំមានករណីណាមួយ

---

140 ទិន្នន័យនេះ គឺផ្អែកលើសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅឆ្នាំ២០២៤។ (មិនដឹង) មានន័យថា អ្នកសង្កេតសវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

141 នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

ដែលបានរាយការណ៍ថា ចៅក្រមបានចេញសាលដីកាដោយផ្អែកទៅលើភស្តុតាងដែលមិនមាននៅក្នុងឯកសារសំណុំរឿងនោះទេ។

### សាលាឧទ្ធរណ៍បាត់ដំបង

នៅសាលាឧទ្ធរណ៍បាត់ដំបង ចៅក្រមខកខានអានប្រាប់សំអាងហេតុក្នុងសេចក្តីសម្រេចជាសាលដីការបស់ខ្លួនចំនួន ៨៦% (៥១ ក្នុងចំណោម ៥៩ សំណុំរឿង) ដែលតួលេខនេះមានភាពប្រហាក់ប្រហែលនឹងឆ្នាំ ២០២៣ ដែលមានចំនួន ៨៧%។ ត្រង់ចំណុចនេះ គឺសិទ្ធិទទួលបានសាលដីកាមានសំអាងហេតុ គួរបន្តយកចិត្តទុកដាក់ក្នុងការលើកកម្ពស់បន្ថែមទៀត។ តំណាងសាលាឧទ្ធរណ៍បាត់ដំបងធ្លាប់បានលើកឡើងក្នុងពេលពិគ្រោះយោបល់ជាមួយ ម.ស.ម.ក ថា ការអានសាលដីកាទាំងមូលអាចត្រូវចំណាយពេលយូរ តែសេចក្តីសម្រេចទាំងស្រុង បានចែកជូនភាគីពាក់ព័ន្ធជាទៀងទាត់រួចហើយ។[142] ខែសីហា ឆ្នាំ២០២៥ ណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានលើកឡើងថា សំណុំរឿងមួយចំនួន ពេលប្រកាសសាលដីកាមិនមានវត្តមានជនជាប់ចោទ ដូចនេះចៅក្រមអានតែសេចក្តីសម្រេចតែប៉ុណ្ណោះ ពីព្រោះថាបើអានសេចក្តីសម្រេចទាំងមូលត្រូវចំណាយពេលយូរ។[143]

ទោះបីជាសាលដីកាជាលាយលក្ខណ៍អក្សរពិតជាមានសារៈសំខាន់ក៏ដោយ ជនជាប់ចោទគួរតែបានយល់អំពីសំអាងហេតុក្នុងសាលដីកានោះភ្លាមៗដោយមិនមានការពន្យារពេលនោះឡើយ ហើយការពន្យល់ផ្ទាល់មាត់គឺជាមធ្យោបាយងាយស្រួលបំផុតក្នុងការផ្តល់ព័ត៌មាន។ គួរឱ្យកត់សម្គាល់ផងដែរ ក្នុងចំណោមជនជាប់ចោទ ២៥,៥% (១២ ក្នុងចំណោម ៤៧ នាក់) ចៅក្រមបានផ្អែកលើចម្លើយសារភាពរបស់ជនជាប់ចោទជាភស្តុតាង។ ទោះបីជា ចៅក្រមពិចារណាលើចម្លើយសារភាពនៅពេលពិនិត្យមើលសំណុំរឿង ក៏ចម្លើយសារភាពនោះមិនគួរត្រូវបានពឹងផ្អែកទាំងស្រុង ឬលើសលប់ពេកនោះទេ ដោយហេតុថាចម្លើយសារភាពខ្លះអាចមិនគួរឱ្យទុកចិត្តបាន ដូចជាតាមរយៈការបង្ខិតបង្ខំ ឬអំពើហិង្សា។ ផ្ទុយមកវិញ សាលដីកា គួរតែផ្អែកលើការពិចារណាទៅលើភស្តុតាងទាំងអស់ដែលបានបង្ហាញនៅចំពោះមុខតុលាការដែលមានក្នុងសំណុំរឿងនោះ។

នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ម.ស.ម.ក បានស្តាប់ការប្រកាសសាលដីកាចំនួនតែ ៣ ប៉ុណ្ណោះ នៅសាលាឧទ្ធរណ៍ព្រះសីហនុ និងមួយនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ នៅក្នុងចំណោមសាលដីកាដែលបានស្តាប់នៅសាលាឧទ្ធរណ៍ព្រះសីហនុ ចៅក្រមបានអានប្រាប់ពីសំអាងហេតុចំនួន ៦៦,៦% (២ ក្នុងចំណោម ៣)។

---

[142] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[143] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ចំពោះសាលដីកាទាំងបួននេះ ចៅក្រមបានយោងលើមាត្រាច្បាប់ពាក់ព័ន្ធ និងភស្តុតាងដែលបានបង្ហាញក្នុងសវនាការ។ នៅឆ្នាំ២០២៣ មានវឌ្ឍនភាពល្អ ដែលពេលនោះ ចៅក្រមបានយោងលើមាត្រាច្បាប់ពាក់ព័ន្ធ ៧១% និងយោងលើភស្តុតាងមានចំនួន ៥៦%។ ការយកចម្លើយសារភាពថាជាភស្តុតាងនៅសាលាឧទ្ធរណ៍ទាំងបួន មានការកើនឡើងបន្តិចនៅក្នុងឆ្នាំ២០២៤ មានចំនួន ២៧% បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ២៤%។ ពុំមានទិន្នន័យណាមួយក្នុងឆ្នាំ២០២៤ ដែលបង្ហាញថា ចៅក្រមបានធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមិនបានដាក់បញ្ចូលទៅក្នុងឯកសារនៃសំណុំរឿងនោះទេ។ មានសាលដីកាចំនួនមួយដែលបានស្ដាប់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានបង្ហាញពីការអនុវត្តល្អ ដោយសារតែសាលដីកានោះ ចៅក្រមបានអានប្រាប់ពីសំអាងហេតុ មាត្រាច្បាប់ពាក់ព័ន្ធ និងភស្តុតាងដែលមានក្នុងសំណុំរឿង មិនតែប៉ុណ្ណោះចម្លើយសារភាពរបស់ជនជាប់ចោទ ចៅក្រមមិនបានយកជាមូលដ្ឋាននៃភស្តុតាងឡើយ។

## ៥.២ សិទ្ធិទទួលបានមេធាវី

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | |
|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ១៤៣ មាត្រា ៣០០ មាត្រា ៣០១ និងមាត្រា ៣៨៩ | មាត្រា ៦ មាត្រា ៥០ និងមាត្រា ៥១ |

ការចោទប្រកាន់ពីបទល្មើសណាមួយ តម្រូវឱ្យមានការធ្វើតាមនីតិវិធីច្បាប់ ដែលករណីខ្លះអាចមានលក្ខណៈស្មុគស្មាញ និងពិបាក។ ដើម្បីធានាថា សិទ្ធិរបស់ជនរងការចោទប្រកាន់ ត្រូវបានការពារយ៉ាងពេញលេញក្នុងអំឡុងពេលដំណើរការនីតិវិធីព្រហ្មទណ្ឌ ពួកគេគួរតែត្រូវមានមេធាវីការពារសិទ្ធិ ដែលមានសមត្ថភាពពន្យល់អំពីសិទ្ធិ និងការចោទប្រកាន់មកលើពួកគេ ណែនាំពួកគេយល់អំពីដំណើរការនីតិវិធីទាំងមូល និងការពារផលប្រយោជន៍របស់ពួកគេនៅក្នុងតុលាការ។ ប្រសិនបើជនរងការចោទប្រកាន់មិនអាចមានលទ្ធភាពជួលមេធាវីទេនោះ អាជ្ញាធរពាក់ព័ន្ធគួរតែផ្ដល់មេធាវីដោយឥតគិតថ្លៃ និងជាផលប្រយោជន៍យុត្តិធម៌តម្រូវដូច្នោះ។[144] នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការទទួលបានមេធាវីការពារសិទ្ធិ គឺជាកាតព្វកិច្ចរបស់រដ្ឋដែលត្រូវផ្ដល់ឱ្យសម្រាប់តែបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបើជននោះជាអនីតិជនប៉ុណ្ណោះ។ ដូច្នេះហើយ មិនមែនជាកាតព្វកិច្ចរបស់រដ្ឋត្រូវផ្ដល់ឱ្យដល់បុគ្គលដែលត្រូវចោទប្រកាន់ពីបទមជ្ឈិមនោះទេ (លើកលែងតែពួកគេជាអនីតិជន) ប៉ុន្តែបុគ្គលទាំងនោះនៅតែអាចជួលមេធាវីដោយខ្លួនឯងបានប្រសិនបើពួកគេត្រូវការ តែនេះមិនមែនជាកាតព្វកិច្ចរបស់តុលាការនោះទេ។

នៅក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួនក្នុងឆ្នាំ២០២៤ មានតែជនជាប់ចោទចំនួន ៥៥,៨% នៃសំណុំរឿងដែលត្រូវបានសង្កេតដោយ ម.ស.ម.ក (៤៥៩ ក្នុងចំណោម ៨២២ នាក់) ប៉ុណ្ណោះ ដែលមាន

[144] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឃ) គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៣៨។

មេធាវីការពារសិទ្ធិ។ ចំណុចនេះបង្ហាញអំពីការធ្លាក់ចុះជាបន្តបន្ទាប់ក្នុងការលើកកម្ពស់សិទ្ធិនេះឱ្យបានប្រសើរ រយៈពេលឆ្នាំទី២ជាប់ៗគ្នា ដោយក្នុងឆ្នាំ២០២៣ ជនជាប់ចោទដែលមានមេធាវីការពារសិទ្ធិចំនួន ៥៨,៧% រីឯក្នុងឆ្នាំ២០២២ មានចំនួន ៦៦,៧%។ គួរកត់សម្គាល់ថាសាលាឧទ្ធរណ៍ព្រះសីហនុធ្លាប់គោរពសិទ្ធិនេះក្នុងឆ្នាំ២០២៣ ដែលជនជាប់ចោទមានមេធាវីការពារសិទ្ធិចំនួន ៨១,៦% ( ១១១ ក្នុងចំណោម ១៣៦ នាក់) ផ្ទុយពីនេះនៅឆ្នាំ២០២៤ ជនជាប់ចោទមានមេធាវីការពារត្រឹមតែ ៦៥,៨% ប៉ុណ្ណោះ (២៧ ក្នុងចំណោម ៤១ នាក់) ។ ដូចនេះ វឌ្ឍនភាពល្អប្រសើរនៃការលើកកម្ពស់សិទ្ធិនេះនៅក្នុងឆ្នាំ២០២៣ មិនបានបន្តទេ ដោយហេតុថាចាប់តាំងពីឆ្នាំ២០១៤ ដល់២០១៥ ពុំមានតុលាការគោលដៅណាមួយបានគោរពសិទ្ធិនេះពេញលេញនៅឡើយ។

*តួលេខទី ២៦៖ ភាគរយនៃជនជាប់ចោទមានមេធាវីការពារសិទ្ធិក្នុងឆ្នាំ២០២៣ នៅតាមតុលាការគោលដៅ*[145]




នៅក្នុងការបទចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទ ជនជាប់ចោទគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានអំពីជំនួយផ្នែកច្បាប់ ប្រសិនបើពួកគេមិនមានជំនួយផ្នែកច្បាប់នោះទេ។[146] ទោះបីច្បាប់កម្ពុជាដាក់ការទទួលខុសត្រូវនេះលើមន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក៏ដោយ[147] ក៏ ម.ស.ម.ក លើកទឹកចិត្តដល់ចៅក្រមសាលាឧទ្ធរណ៍អនុវត្តតាមនូវការប្រតិបត្តិល្អ ពោលគឺមិនត្រឹមតែផ្តល់ព័ត៌មានអំពីសិទ្ធិមានមេធាវីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារសិទ្ធិនេះផងដែរ ដើម្បីឱ្យពួកគេការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវីផងដែរ។ បន្ទាប់ពីបានពន្យល់ចំណុចនេះរួច ចៅក្រមគួរតែស្នើសុំថា តើជនជាប់ចោទយល់ព្រមបន្តដំណើរការនីតិវិធីសំណុំរឿងដោយគ្មានមេធាវីដែរឬទេ។ ការបន្តនីតិវិធីដោយគ្មានមេធាវីអាចមានផលប៉ះពាល់ជាច្រើនលើសំណុំរឿងរបស់ជនជាប់ចោទ ក៏ដូចជា លទ្ធផលចុងក្រោយផងដែរ។ យោងតាមមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងការពិនិត្យឯកសារសំណុំរឿង និងឯកសារ

[145] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៨២២ នាក់) នៅក្នុងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតក្នុងឆ្នាំ២០២៤។
[146] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឃ)។
[147] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៦, ៤៨, ៩៧, ១៤៣, ៣០៤។

សង្ខេប មានតែមេធាវី ឬលេខាធិការមេធាវីប៉ុណ្ណោះ ដែលអាចពិនិត្យមើលសំណុំរឿងមុនពេលសវនាការ និងថតចម្លងឯកសារដែលមាននៅក្នុងនោះបាន។ នេះមានន័យថា ជនជាប់ចោទដែលគ្មានមេធាវី នឹងមិនអាចចូលមើលសំណុំរឿងដែលព្រះរាជអាជ្ញានឹងប្រើដើម្បីចោទប្រកាន់ពួកគេបាននោះឡើយ។ ដូចនេះហើយបានប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេក្នុងការរៀបចំការពារក្ដីដោយខ្លួនឯង។ នៅទូទាំងតុលាការគោលដៅទាំងបួន ក្នុងឆ្នាំ ២០២៤ ចៅក្រមមិនអានបានប្រាប់ ឬពន្យល់អំពីសិទ្ធិការពារក្ដីដោយខ្លួនឯងដល់ជនជាប់ចោទដែលគ្មានមេធាវីការពារសិទ្ធិចំនួន ១៤% នៃសំណុំរឿងដែលបានសង្កេត (៣៧ ក្នុងចំណោម ២៦៥ នាក់)។ ថ្វីដ្បិតតែការមិនបានប្រាប់អំពីសិទ្ធិដ៏សំខាន់នេះដល់ជនជាប់ចោទនៅតែបន្តកើតមាន ប៉ុន្តែនេះជាការប្រសើរឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២៣ ដែលពេលនោះមានដល់ ២៤% និងកាន់តែប្រសើរឡើងបើធៀបនឹងឆ្នាំ ២០២២ មានដល់ ៤៨,៦%។ មួយវិញទៀត សិទ្ធិដែលបានបង្ហាញភាពប្រសើរផងដែរគឺទាក់ទងនឹងមេធាវីការពារសិទ្ធិជនជាប់ចោទលើសពីម្នាក់ក្នុងសំណុំរឿងតែមួយ នៅក្នុងឆ្នាំ២០២៤ មានតែ ២៤% នៃជនជាប់ចោទ (១៩៧ ក្នុងចំណោម ៨២២ នាក់) ប៉ុណ្ណោះដែលមានមេធាវីការពារសិទ្ធិ ដែលមេធាវីនោះការពារជនជាប់ចោទលើសពីម្នាក់ ដែលនេះជាការថយចុះដែរបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ២៥%។ ទោះបី ជាការមានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើសពីម្នាក់ អាចជួយសន្សំសំចៃការចំណាយក៏ពិតមែន ប៉ុន្តែការធ្វើដូច្នេះ ក៏អាចប៉ះពាល់ដល់សមត្ថភាពរបស់មេធាវីក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទឱ្យបានពេញលេញផងដែរ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ។ ទោះយ៉ាងណាក្ដី ក្នុងចំណោមសំណុំរឿងដែលមេធាវីការពារសិទ្ធិជនជាប់ចោទលើសពីម្នាក់នោះ មានតែពីរសំណុំរឿងប៉ុណ្ណោះដែលត្រូវបានរកឃើញថាមានទំនាស់ផលប្រយោជន៍គឺនៅសាលាឧទ្ធរណ៍ភ្នំពេញ។

*តួលេខទី ២៧៖ ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទនូវសិទ្ធិរបស់ពួកគេក្នុងការទទួលបានមេធាវី ឬការពារខ្លួនឯងដោយតុលាការទាំងបួន*[148]

[148] ទិន្នន័យគឺផ្អែកលើសំណុំរឿងដែលបានសង្កេតចំនួន ២៦៥ សំណុំរឿង (១១៧ សំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញ, ៨៩ សំណុំរឿងនៅសាលាឧទ្ធរណ៍បាត់ដំបង,១០ សំណុំរឿងនៅសាលាឧទ្ធរណ៍ព្រះសីហនុ និង ៤៩ សំណុំរឿងនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។




## សាលាឧទ្ធរណ៍ភ្នំពេញ

ក្នុងឆ្នាំ២០២៤ ជនជាប់ចោទ ៥៨% ក្នុងសវនាការដែលបានសង្កេតដោយ ម.ស.ម.ក មានមេធាវីការពារសិទ្ធិបានថយចុះបន្តិចបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៦០,៩% (២៨០ ក្នុងចំណោម ៤៦០ នាក់)។ ជាក់ស្តែង ជនជាប់ចោទ ១០០% ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋ (១៥៨ ក្នុងចំណោម ១៥៨ នាក់) មានមេធាវីការពារសិទ្ធិ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ផ្ទុយទៅវិញ ជនជាប់ចោទចំនួន ២៣,៩% (៤៨ ក្នុងចំណោម ២០១ នាក់) ដែលចោទប្រកាន់ពីបទមជ្ឈិមប៉ុណ្ណោះ ដែលមានមេធាវីការពារសិទ្ធិ។ ក្នុងចំណោមអ្នកដែលចោទប្រកាន់បទលហុមាន ៣៣% (២ ក្នុងចំណោម ៦ នាក់) មានមេធាវីការពារសិទ្ធិ។ ក្រៅពីនេះ ជាជនជាប់ចោទមិនមានមេធាវីការពារសិទ្ធិ អាចចាត់ទុកថា ចៅក្រមបានស្នើសុំ និងទទួលការយល់ព្រមពីជនជាប់ចោទដើម្បីបន្តដំណើរការសវនាការដោយគ្មានមេធាវីការពារសិទ្ធិ។ ទោះបីជាយ៉ាងនេះក្តី ចំណុចនេះក៏នៅតែជាវឌ្ឍនភាពល្អ ដោយសារតែនៅក្នុងឆ្នាំ២០២៣ មានជនជាប់ចោទបទមជ្ឈិមចំនួនត្រឹមតែ ៧,២% ប៉ុណ្ណោះ (១៩ ក្នុងចំណោម ២៦០ នាក់) ដែលមានមេធាវីការពារសិទ្ធិ ចំណែកឯបទលហុវិញមានត្រឹមតែ ២០% (២ ក្នុងចំណោម ១០ នាក់) ប៉ុណ្ណោះ។ ទោះបីជាមានភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំពិតមែន ក៏ប៉ុន្តែតួលេខទាំងនេះនៅតែបញ្ជាក់ថា បុគ្គលភាគច្រើនប្រឈមមុខនឹងការចោទប្រកាន់ពីបទមជ្ឈិម និងបទលហុ មិនមានមេធាវីការពារសិទ្ធិរបស់ពួកគេ។ មានការលំបាកក្នុងការកំណត់ពីផលប៉ះពាល់ដែលអាចកើតមានលើលទ្ធផលនៃសំណុំរឿងរបស់ពួកគេ ប៉ុន្តែអាចសន្និដ្ឋានបានថា ផលប៉ះពាល់នោះអាចទំនងជាមានកម្រិតខ្ពស់។ ក្នុងសំណុំរឿងចំនួន ២២% (៨២ ក្នុងចំណោម ៣៦៥ នាក់) ដែលជនជាប់ចោទមានមេធាវីការពារសិទ្ធិ ប៉ុន្តែមេធាវីទាំងនោះ បានការពារសិទ្ធិឱ្យជនជាប់ចោទលើសពីមួយ។ លើសពីនេះ ក្នុងចំណោមសំណុំរឿងទាំងនេះ បានកត់សម្គាល់ថា មាន២សំណុំរឿងមានទំនាស់ផលប្រយោជន៍។ ដូចនេះ គួរមានការយកចិត្តទុកដាក់ជាពិសេសចំពោះមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទច្រើននាក់ អាចជះឥទ្ធិពលអវិជ្ជមានដល់ផលប្រយោជន៍របស់ជនជាប់

ចោទណាមួយក្នុងចំណោមពួកគេ។ ក្នុងករណីមានទំនាស់ផលប្រយោជន៍ គួរមានវិធានការដើម្បីជួយសម្រួលដល់ជនជាប់ចោទនោះអាចទទួលបានមេធាវីផ្សេង។

មួយវិញទៀត ការបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់របស់សាលាឧទ្ធរណ៍ភ្នំពេញពាក់ព័ន្ធនឹងចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារសិទ្ធិ។ ការអនុវត្តល្អនេះ ត្រូវបានធ្វើឡើងក្នុងសំណុំរឿងចំនួន ៤៨,៧% (៥៧ ក្នុងចំណោម ១១៧) ដែលបានកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៣ ដែលនៅពេលនោះគឺមានត្រឹមតែ ១៧% (១៨ ក្នុងចំណោម ១០៥) ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿងចំនួន ១៨,៨% (២២ ក្នុងចំណោម ១១៧) ចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទទេ ដែលអាចបណ្តាលឱ្យពួកគេមិនបានដឹងអំពីសិទ្ធិរបស់ខ្លួន និងប៉ះពាល់ផលប្រយោជន៍នៃការបោះបង់សិទ្ធិមានមេធាវី។ គួរកត់សម្គាល់ថា នេះគឺជាវឌ្ឍនភាពមួយ បើធៀបនឹងឆ្នាំ២០២៣ ដែលកាលនោះ ចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទក្នុងសំណុំរឿងរហូតដល់ ២៤,៧% ដែលបានសង្កេត។

ទោះបីជាមានវឌ្ឍនភាពល្អមួយចំនួន ក៏មានរបកគំហើញបង្ហាញថា សិទ្ធិទទួលបានមេធាវី នៅតែមិនបានគោរពពេញលេញនៅឡើយ ដែលស្ថានភាពនេះបានបន្តកើតមាន បន្ទាប់ពីឆ្នាំ២០១៤ និង២០១៥។ ដូច្នេះគួរមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាថាជនជាប់ចោទទាំងអស់ទទួលបានមេធាវីការពារសិទ្ធិរបស់គេ ដែលជាមូលដ្ឋានមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

*តួលេខទី ២៨៖ ការវិវត្តគិតជាភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារសិទ្ធិនៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០២៤)*[149]

[149] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទ ១៣៥ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតក្នុងឆ្នាំ២០១៤/២០១៥។ ជនជាប់ចោទ ៤៣៩ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៥៥៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតក្នុងឆ្នាំ២០១៦/២០១៧ ជនជាប់ចោទ ២៤១ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតក្នុងឆ្នាំ២០១៧/២០១៨ ជនជាប់ចោទ ២៦២ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតក្នុងឆ្នាំ២០១៨/២០១៩ ជនជាប់ចោទ ១៨៣ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ២៥៥ នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២០៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៩/២០២០ ជនជាប់ចោទ ៨៩ នាក់ដែលមានមេធាវីម្នាក់ការពារក្នុងចំណោមជនជាប់ចោទ ១១៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតក្នុងឆ្នាំ២០២១ ជនជាប់ចោទ ២៦៦ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតក្នុងឆ្នាំ២០២២, និង ជនជាប់ចោទ ២៨០ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៤៦០ នាក់ដែលពាក់ព័ន្ធក្នុងសំណុំរឿង ៣៣៦ ដែលបាន សង្កេតក្នុងឆ្នាំ២០២៣។




## សាលាឧទ្ធរណ៍បាត់ដំបង

ការលើកកម្ពស់សិទ្ធិមានមេធាវី មិនទាន់បានពេញលេញនៅឡើយក្នុងអំឡុងពេល៣ឆ្នាំបន្តបន្ទាប់។ មានតែជនជាប់ចោទ ៥៧,៦% (១៦៧ ក្នុងចំណោម ២៩០ នាក់)ដែលមានមេធាវីការពារសិទ្ធិនៅក្នុងសវនាការដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ តួលេខនេះ មានការកើនឡើងបើធៀបនឹងឆ្នាំ ២០២៣ ដែលមានត្រឹមតែ ៥៣,៨% (១៨៦ ក្នុងចំណោម ៣៤៦ នាក់)។ ជនជាប់ចោទ ១០០% ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ (៩៩ ក្នុងចំណោម ៩៩ នាក់) មានមេធាវីការពារសិទ្ធិ ក៏ប៉ុន្តែជនជាប់ចោទពីបទមជ្ឈិមចំនួន ៣៥% (៦៦ ក្នុងចំណោម ១៨៧ នាក់) ដែលមានមេធាវីការពារសិទ្ធិ ខណៈដែលជនជាប់ចោទពីបទលហុ ពុំមានមេធាវីការពារសិទ្ធិ (៤ ក្នុងចំណោម ៤ នាក់)។ ចំណុចនេះមានន័យថា ជនជាប់ចោទភាគច្រើនជាប់ចោទពីបទមជ្ឈិម ឬលហុពុំមានមេធាវីការពារសិទ្ធិទេ។ ក្រៅពីនេះ នជាប់ចោទមិនមានមេធាវីការពារសិទ្ធិទេ ដែលអាចចាត់ថា ចៅក្រមបានសាកសួរ និងមានការយល់ព្រមពីជនចាប់ចោទ ដើម្បីបន្តសវនាការដោយគ្មានមេធាវី។ ម្យ៉ាងវិញទៀត ចំនួនករណីដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើសពីមួយម្នាក់ បានកើនឡើងដល់ ៣១,៧% (៩២ ក្នុងចំណោម ២៩០ នាក់) ក្នុងឆ្នាំ២០២៤ បើធៀបនឹង ឆ្នាំ២០២៣ មានតែ ២៩%។ ទោះបី មានការកើនឡើង ប៉ុន្តែក៏មិនមានព័ត៌មានណាមួយបញ្ជាក់ថាមានទំនាស់ផលប្រយោជន៍នោះដែរ។

មានការប្រែប្រួលខ្លះដែលថាចៅក្រមបានប្រកាន់ខ្ជាប់នូវការប្រតិបត្តិល្អក្នុងការអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិការពារខ្លួននោះ ដោយហេតុថា ក្នុងឆ្នាំ២០២៤ ចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទ ៦៧,៤% (៦០ ក្នុងចំណោម ៨៩ នាក់) បើធៀបនឹងឆ្នាំ២០២៣ មាន ៦៦%។ ម.ស.ម.ក ចង់ឃើញតុលាការបន្តប្រកាន់ខ្ជាប់នូវការប្រតិបត្តិល្អ ព្រោះការអនុវត្តនេះហាក់មានភាពប្រសើរឡើងបន្ទាប់ពីឆ្នាំ ២០២២ ដែលពេលនោះមានចំនួនត្រឹមតែ ១៦.៧% ប៉ុណ្ណោះ។ វឌ្ឍនភាពមួយទៀតនៅឆ្នាំ២០២៤ គឺមានចំនួនសំណុំរឿងដែលចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះ បានថយចុះគួរកត់សម្គាល់ពី ១៩,៦% (២២ ក្នុងចំណោម ១១២) នៅឆ្នាំ២០២៣ មកត្រឹម ៤,៥% (៤ ក្នុងចំណោម ៨៩ នាក់) ប៉ុណ្ណោះ នៅឆ្នាំ ២០២៤។

មានវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងការគោរពសិទ្ធិនេះ ទិន្នន័យជារួមនៅសាលាឧទ្ធរណ៍បាត់ដំបងមិនទាន់អាចចាត់ទុកថាសិទ្ធិទទួលបានមេធាវីត្រូវបានគោរពពេញលេញនោះទេ។ ដូច្នេះ គួរបន្តការលើកកម្ពស់ និងធានានូវវឌ្ឍនភាពទៅមុខទៀត តាមរយៈការមានវិធានការចាំបាច់នានា ដូចជា ការអានប្រាប់ និងពន្យល់អំពីសិទ្ធិការពារខ្លួនដល់ជនជាប់ចោទឱ្យបានគ្រប់គ្រាន់ ព្រមទាំងធានាថាគ្មានទំនាស់ផលប្រយោជន៍ណាមួយកើតឡើងក្នុងសំណុំរឿងដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើសពីម្នាក់។ ខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានបញ្ជាក់ថា ជនជាប់ចោទពីបទមជ្ឈិមតុលាការមិនមានកាតព្វកិច្ចផ្តល់មេធាវីឱ្យទេ តែបើជនជាប់ចោទគ្មានលទ្ធភាពរកមេធាវីខ្លួនឯង តុលាការនឹងចាត់តាំងឱ្យ ប៉ុន្តែជនជាប់ចោទខ្លួនឯងមិនព្រមទទួលយក។[150]

## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ បានលើកកម្ពស់សិទ្ធិទទួលបានមេធាវីមិនទាន់បានពេញលេញនៅឡើយក្នុងឆ្នាំ២០២៤ ខុសពីឆ្នាំ២០២៣ ដែលសិទ្ធិនេះត្រូវបានគោរព។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ជនជាប់ចោទដែលមានមេធាវីការពារសិទ្ធិនៅចំពោះមុខតុលាការមានត្រឹមតែ ៦៥,៩% (២៧ ក្នុងចំណោម ៤១ នាក់) ប៉ុណ្ណោះ ដែលនេះជាការថយចុះបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨១,៦%។ ជនជាប់ចោទ ១០០% (១៤ ក្នុងចំណោម ១៤ នាក់) ដែលចោទប្រកាន់ពីបទឧក្រិដ្ឋ មានមេធាវីការពារសិទ្ធិ។ ជនជាប់ចោទពីបទមជ្ឈិមចំនួន ៥០% មានមេធាវីការពារសិទ្ធិ។ ក្រៅពីនេះ ជាជនជាប់ចោទមិនមានមេធាវីការពារសិទ្ធិ ដែលអាចចាត់ទុកថា ចៅក្រមបានសាកសួរ និងមានការយល់ព្រមពីជនជាប់ចោទឱ្យដំណើរការសវនាការដោយគ្មានមេធាវី។ ក្នុងចំណោមជនជាប់ចោទដែលមានមេធាវីការពារសិទ្ធិ មានមេធាវីការពារជនជាប់ចោទលើសពីម្នាក់បានថយចុះមកត្រឹមតែ ២% (១ ក្នុងចំណោម ៤១ នាក់) ប៉ុណ្ណោះ បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៤២,៦% (៥៨ ក្នុងចំណោម ១៣៦ នាក់)។ មិនមានទំនាស់ផលប្រយោជន៍ណាមួយបានកើតមាននោះទេ ដែលនេះជាវឌ្ឍនភាពដ៏ល្អប្រសើរបើធៀបនឹងឆ្នាំ២០២៣ មានចំនួន២ ករណី។

ករណីដែលចៅក្រមខកខានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិការពារខ្លួនរបស់ពួកគេខណៈដែលពួកគេមិនមានមេធាវីការពារសិទ្ធិ ចំនួន ៧០% (៧ ក្នុងចំណោម ១០ នាក់) ថយចុះបន្តិច បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨២,៦% ។ ចំណុចនេះ មានន័យថាមានតែជនជាប់ចោទពីនាក់ប៉ុណ្ណោះ ដែលត្រូវបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះ ហើយមានតែមួយនាក់ប៉ុណ្ណោះ បានត្រឹមតែប្រាប់។

នៅក្នុងកិច្ចពិគ្រោះយោបល់ពីមុនជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថា ជនជាប់ចោទដែលគ្មានមេធាវីមួយចំនួន ត្រូវបានជូនដំណឹងរួចហើយ

[150] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

អំពីសិទ្ធិរបស់ពួកគេក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍លើកដំបូង។ ហេតុដូច្នេះហើយ ចៅក្រមនឹងមិនអានប្រាប់ពួកគេអំពីសិទ្ធិនេះម្តងទៀតទេនៅក្នុងសវនាការជាបន្តបន្ទាប់។[151] ម.ស.ម.ក ចង់ឃើញការប្រតិបត្តិល្អដោយមានការអានប្រាប់ និងពន្យល់ជាប្រចាំដល់ជនជាប់ចោទអំពីសិទ្ធិនេះ ដើម្បីធានាថា ជនជាប់ចោទបានយល់ដឹងច្បាស់។

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

នៅឆ្នាំ២០២៤ មានតែជនជាប់ចោទចំនួន ៤១% (៥២ ក្នុងចំណោម ១២៦ នាក់) ប៉ុណ្ណោះ ដែលមានមេធាវីការពារសិទ្ធិ បើធៀបនឹងឆ្នាំ២០២៣ មានចំនួនដល់ ៤៤,៩% (៧៩ ក្នុងចំណោម ១៧៦ នាក់) ដែលចំនួននេះទាបជាងគេក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួន។ ដូចនេះ មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ ក្នុងអំឡុងពេល៣ឆ្នាំបន្តបន្ទាប់នេះ ដោយសារតែនៅឆ្នាំ២០២២ មានជនជាប់ចោទតែ ៤៤% ប៉ុណ្ណោះដែលមេធាវីការពារសិទ្ធិ។ ក្នុងចំណោមអ្នកដែលចោទប្រកាន់ពីបទឧក្រិដ្ឋ ១០០% មានមេធាវីការពារសិទ្ធិ ខណៈដែលអ្នកដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិមមានតែ ១៩,៧% (១៨ ក្នុងចំណោម ៩១ នាក់) ប៉ុណ្ណោះដែលមានមេធាវីការពារសិទ្ធិ។ ក្រៅពីនេះ ជាជនជាប់ចោទមិនមានមេធាវីការពារសិទ្ធិដែលអាចចាត់ទុកចៅក្រមបានសាកសួរ និងមានការយល់ព្រមពីជនជាប់ចោទ ដើម្បីដំណើរការសវនាការដោយគ្មានមេធាវី។ គួរកត់សម្គាល់ផងដែរថា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទច្រើនជាងម្នាក់ បានថយចុះពី ២២% ក្នុងឆ្នាំ២០២៣ មកត្រឹម ១៧% (២២ ក្នុងចំណោម ១២៦ នាក់) ក្នុងឆ្នាំ២០២៤ និងគ្មានទំនាស់ផលប្រយោជន៍ណាមួយបានកើតមាននោះឡើយ។

មានភាពប្រសើរឡើងមួយចំនួន តែភាគរយនេះនៅមានកម្រិត ដូចនេះមិនទាន់ចាត់ទុកថាសិទ្ធិទទួលបានមេធាវីត្រូវបានធានាពេញលេញនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំនៅឡើយ។ មានចំនួន ៧៩,៦% (៣៩ ក្នុងចំណោម ៤៩ នាក់) ដែលចៅក្រមបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការប្រតិបត្តិល្អ ដូចជា ចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិការពារខ្លួនឯង ឬតាមរយៈមេធាវី។ នេះជាវឌ្ឍនភាពដ៏ល្អបើធៀបនឹងឆ្នាំ ២០២៣ មានចំនួន ៥៣,៨% (២៨ ក្នុងចំណោម ៥២ នាក់) ប៉ុណ្ណោះ។

នៅខែសីហា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានបញ្ជាក់ថា ចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ជនជាប់ចោទមិនបានពឹងពាក់មេធាវីទេ ហើយបានអនុញ្ញាតឱ្យតុលាការបន្តសវនាការដោយគ្មានវត្តមានមេធាវី។ តុលាការបានលើកឡើងថា ខ្លួនមិនមាន

[151] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីលទ្ធផលនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

កាតព្វកិច្ចក្នុងការផ្តល់មេធាវីនោះទេ ចំពោះបទមជ្ឈិម ដូចនេះ តុលាការអាចជំនុំជម្រះដោយគ្មានមេធាវីបាន ស្របតាមច្បាប់កម្ពុជា។[152]

## ៥.៣ សិទ្ធិមានសេរីភាព

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | |
|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| មាត្រា ៣ | មាត្រា ៩ (១) | មាត្រា ៣២ និង មាត្រា ៣៨ | មាត្រា ២០៣ មាត្រា មាត្រា ២០៤មាត្រា ២០៥ មាត្រា ២០៨ មាត្រា ២០៩ និងមាត្រា ២១១ |

មាត្រា ៩(១) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិមានសេរីភាព និងសុវត្ថិភាពរបស់ជនគ្រប់រូបពីការចាប់ខ្លួន ឬឃាត់ខ្លួនតាមអំពើចិត្ត។ ប៉ុន្តែសិទ្ធិមានសេរីភាពមិនមានលក្ខណៈដាច់ខាតទេ ហេតុដូចនេះ បុគ្គលម្នាក់ៗ អាចត្រូវបានដកហូតសេរីភាពដោយផ្អែកទៅលើ "មូលដ្ឋាន និងស្របទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់" ការដកហូតសេរីភាពណាមួយដែលធ្វើឡើងក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវតែស្របច្បាប់ ពោលគឺត្រូវអនុវត្តទៅតាមនីតិវិធីដែលច្បាប់កំណត់ និងដោយគោរពនីតិរដ្ឋ និងមិនត្រូវធ្វើតាមអំពើចិត្តឡើយ។[153] យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស "អំពើបំពាន" មិនមែនគ្រាន់តែមានន័យថា "ប្រឆាំងនឹងច្បាប់" នោះទេ។ ផ្ទុយទៅវិញ គំនិតនេះត្រូវតែបកស្រាយឱ្យកាន់តែទូលំទូលាយ ដោយរួមបញ្ចូលនូវធាតុផ្សំនៃភាពមិនសមរម្យ អយុត្តិធម៌ មិនអាចដឹងជាមុនបាន និងដំណើរការត្រឹមត្រូវតាមច្បាប់ ព្រមទាំងធាតុផ្សំនៃភាពសមហេតុផល ភាពចាំបាច់ និងសមាមាត្រផងដែរ។[154] ឧទាហរណ៍ ការឃុំខ្លួនជនណាមួយជាបណ្តោះអាសន្នត្រូវតែធ្វើឡើងទៅតាមភាពសមស្រប និងចាំបាច់គ្រប់កាលៈទេសៈទាំងអស់ ហើយការសម្រេចចិត្តឃុំខ្លួនជាបណ្តោះអាសន្ន គឺជាការរំលោភបំពាន លើកលែងតែមានការវាយតម្លៃឡើងវិញតាមកាលកំណត់លើមូលហេតុនៃការបន្តឃុំខ្លួននោះ។ ដោយសារតែសិទ្ធិមានសេរីភាព ជាពិសេស ការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិសន្មតទុកជាមុនថាគ្មានទោស ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធបំផុតព្រោះថាការឃុំខ្លួនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសន្មតថាគ្មានទោសបាន។ នេះជាមូលហេតុដែលការឃុំខ្លួនបណ្តោះអាសន្នត្រូវតែប្រើប្រាស់ជាវិធានការចុងក្រោយ នៅពេលដែលមានភាពចាំបាច់ និងក្នុងករណីពិសេសដែលបានចែងក្នុងច្បាប់តែប៉ុណ្ណោះ។

ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការពិសេសមួយ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ជាគោលការណ៍ ជនត្រូវចោទគួរតែមានសេរីភាព ហើយមានតែក្នុងករណី "ពិសេស" ប៉ុណ្ណោះ ដែលពួកគេអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។[155] យោងមាត្រា២០៥ នៃតាមក្រម

---

[152] នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[153] ក.អ.ស.ព.ន. មាត្រា ៩(១)

[154] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅ លេខ ៣៥ (CCPR/C/GC/៣៥) វាក្យខណ្ឌ១២ https://tinyurl.com/HRC-GC-35

[155] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣។

នីតិវិធីព្រហ្មទណ្ឌកម្ពុជា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនណាម្នាក់ ត្រូវតែធ្វើឡើងជាចាំបាច់ដើម្បី៖ (១) បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។ (២) រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។ (៣) រក្សាទុកភស្តុតាង ឬតម្រុយសម្ភារៈ (៤) ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី (៥) ការពារសន្តិសុខឱ្យជនត្រូវចោទ និង(៦) ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។ [156] គួរកត់សម្គាល់ថាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនមានការបែងចែកវិធានជាក់លាក់ក្នុងការអនុវត្តនិតីវិធីរវាងសាលាដំបូង និងសាលាឧទ្ធរណ៍ យោងតាមមាត្រា៣៩៦ បានចែងថា«វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូងត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍» ដូចនេះមានន័យថា វិធានទាំងឡាយដែលមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌគឺត្រូវអនុវត្តបានចំពោះតុលាការទាំងនេះ។

មាត្រា៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានផ្តល់អំណាចឱ្យតុលាការដោះលែងជនជាប់ចោទនៅគ្រប់ពេលវេលា ហើយមាត្រា៣០៥ ក៏ផ្តល់អំណាចដល់តុលាការស្រដៀងគ្នានេះដែរ។ មានបទប្បញ្ញត្តិមួយចំនួនបានផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមអាចដោះលែងជនជាប់ចោទឱ្យមានសេរីភាព។ ការអនុវត្តអំណាចនេះ តុលាការត្រូវពិចារណាដោយផ្អែកលើមាត្រា ២០៣ នៃក្រមនេះដែលចែងពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ដូនេះសិទ្ធិមានសេរីភាពគួរត្រូវបានលើកកម្ពស់ លើកលែងមានកំណត់ក្នុងមាត្រា២០៥ នៃក្រមនេះ។ ការចង្អៀតណែនក្នុងពន្ធនាគារជាបញ្ហាសំខាន់មួយដែលមានជាប់ពាក់ព័ន្ធក្នុងការអនុវត្តនីតិវិធីនេះ ហើយតាមរបាយការណ៍អង្គការសង្គមស៊ីវិលរកឃើញថាមាន៧៥%នៃជនជាប់ឃុំជាជនកំពុងបន្តដំណើរការនីតិវិធី [157] ដូចនេះការអនុវត្តតាមបទប្បញ្ញត្តិនេះ មិនត្រឹមតែលើកកម្ពស់សិទ្ធិមានសេរីភាពរបស់ជនរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌប៉ុណ្ណោះទេ តែថែមទាំងផ្តល់ប្រយោជន៍ដល់រាជរដ្ឋាភិបាល ព្រមទាំងដល់ប្រព័ន្ធគ្រប់គ្រងពន្ធនគារពាក់ព័ន្ធនឹងសុវត្ថិភាព សុខមាលភាពជនជាប់ឃុំ និងអ្នកធ្វើការនៅទីនោះ រួមទាំងចំណេញនូវថវិកាផងដែរ។

ការលើកលែងលើការឃុំខ្លួនបណ្តោះអាសន្ន ក៏មានបញ្ជាក់នៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលថាការឃុំខ្លួនអនីតិជន គួរតែត្រូវបានប្រើប្រាស់ជាវិធានការចុងក្រោយបំផុត និងសម្រាប់រយៈពេលដ៏ខ្លីបំផុត។ [158] លើសពីនេះ មាត្រា ៤៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងយ៉ាងច្បាស់ថា៖ "ដើម្បីឧត្តមប្រយោជន៍របស់កុមារ ចៅក្រមត្រូវពិចារណាដោះលែងអនីតិជនដែលកំពុងជាប់ឃុំ ខណៈពេលកំពុងរង់ចាំសវនាការ"។ មាត្រានេះក៏មានចែងបន្ថែមទៀតថា "ក្នុងករណីមានការពន្យារពេលយូរ ចៅក្រមគួរតែពិចារណាឡើងវិញ ដើម្បីដោះលែងអនីតិជននោះឱ្យនៅក្រៅឃុំបណ្តោះអាសន្ន"។[159] មាត្រា ៥៧ បានចែងថា ដើម្បីជា "ឧត្តមប្រយោជន៍របស់អនីតិជន" តុលាការពាក់ព័ន្ធគួរតែពិចារណាលើការដោះលែងពួកគេ ប្រសិនបើពួកគេកំពុងត្រូវបានឃុំខ្លួន។

[156] ដូចខាងលើ មាត្រា ២០៥

[157] លីកាដូ, វិបត្តិកំណើនជនជាប់ឃុំក្នុងពន្ធនាគារ ៖ ភាពចង្អៀតណែន និងតម្រូវការកំណែទម្រង់ប្រព័ន្ធពន្ធនាគារ, ១៨ កុម្ភៈ ២០២៥ https://tinyurl.com/LICADHO-prison-overcrowding

[158] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦) មាត្រា ៥ https://tinyurl.com/Law-on-Juvenile-Justice

[159] ដូចខាងលើ មាត្រា ៤៥

គោលការណ៍ដ៏សំខាន់នេះក៏គួរតែអនុវត្តចំពោះជនជាប់ចោទដែលមិនមែនជាអនីតិជនផងដែរ ដោយយល់ឃើញពីប៉ះពាល់ធ្ងន់ធ្ងរដែលការឃុំខ្លួនអាចបង្កហេតុជាច្រើនលើជីវិតរបស់បុគ្គលម្នាក់ៗ ហើយក៏ប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទផងដែរ។ ជាការកត់សម្គាល់សវនាការទាំងអស់ដែល ម.ស.ម.ក បានសង្កេតក្នុងឆ្នាំ២០២៤ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោមតុលាការទាំងបួនត្រូវបានបង្គាប់ឱ្យនៅក្រៅឃុំ ខណៈពេលដែលគាត់កំពុងរង់ចាំការប្រកាសសាលដីការបស់តុលាការ។

*តួលេខទី ២៩៖ ភាគរយនៃជនជាប់ចោទដែលត្រូវឃុំខ្លួនតាមតុលាការគោលដៅ*[160]




ផ្ទុយពីបទប្បញ្ញត្តិច្បាប់ ការសង្កេតសវនាការរបស់ ម.ស.ម.ក នៅសាលាឧទ្ធរណ៍គោលដៅទាំងបួនបានបង្ហាញឱ្យឃើញថាការឃុំខ្លួនជាវិធានអនុវត្តទូទៅ ពោលគឺមិនមែនជាករណីលើកលែងនោះទេ។ សម្រាប់រយៈពេលបីឆ្នាំជាប់ៗគ្នានេះ ម.ស.ម.ក បានកត់សម្គាល់ថាមានការកើនឡើងនូវការប្រើប្រាស់វិធានការឃុំខ្លួននៅតុលាការគោលដៅចំនួន ៣ ក្នុងចំណោម ៤ ដែលស្រដៀងទៅនឹងឆ្នាំ២០២៣ និងមានភាគរយខ្ពស់។ នៅឆ្នាំ២០២៤ ជនជាប់ចោទចំនួន ៨៥% (៦៤០ ក្នុងចំណោម ៧៥២ នាក់) ត្រូវបានឃុំខ្លួន។ តួលេខនេះកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានត្រឹម ៧៥% និង ៧២,៦% ក្នុងឆ្នាំ២០២២។ ជនជាប់ចោទភាគច្រើននៅក្នុងសំណុំរឿងដែលបានសង្កេតក្នុងអំឡុងពេលធ្វើបាយការណ៍នៅសាលាឧទ្ធរណ៍គោលដៅទាំងបួន ត្រូវបានឃុំខ្លួន ដែលនេះបង្ហាញថាជាគោលការណ៍សេរីភាព និងការអនុវត្តមិនទាន់ស្របតាមវិធានការដែលត្រូវបានកំណត់សម្រាប់តែករណីជាក់លាក់ដែលចាំបាច់ និងសមស្របប៉ុណ្ណោះ។ ដូច្នេះ នេះអាចជាការប៉ះពាល់នូវកាតព្វកិច្ចរបស់កម្ពុជាក្រោម ក.អ.ស.ព.ន. ។ ទោះបីជាមានបទប្បញ្ញត្តិច្បាស់លាស់នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលធានាសិទ្ធិមានសេរីភាពសម្រាប់ជនជាប់ចោទជាអនីតិជន លើកលែងតែក្នុងករណីពិសេសក៏ដោយ ក៏ជនជាប់ចោទជាអនីតិជនចំនួន ៥៥% (៥ ក្នុងចំណោម ៩ នាក់) នៅក្នុងសវនាការដែលបានសង្កេតក្នុងឆ្នាំ២០២៤ ត្រូវបានជាប់

[160] ទិន្នន័យនេះ គឺផ្អែកលើចំនួនជនជាប់ចោទនៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៤ ដែលបង្ហាញថា តើពួកគេត្រូវឃុំខ្លួនឬទេ (៧៥២ នៃ ៨២២)។

ឃុំក្នុងដំណើរការបណ្តឹងឧទ្ធរណ៍របស់ពួកគេ ដែលនេះគឺមិនស្របនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងថាការឃុំខ្លួនគួរតែជាករណីលើកលែង មិនមែនជាវិធានទូទៅនោះទេ។

គួរកត់សម្គាល់ថា ក្នុងចំណោមសំណុំរឿង ៧៩ ករណី នៅសាលាឧទ្ធរណ៍គោលដៅទាំងបួន ដែល ម.ស.ម.ក បានស្តាប់សាលដីកា គឺមានជនជាប់ចោទ ៩៤% ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ។ តួលេខនេះបង្ហាញថាមានការកើនឡើងបើធៀបនឹងឆ្នាំ២០២៣ ដែលពេលនោះ ការកាត់ទោសជនជាប់ចោទដាក់ពន្ធនាគារមានត្រឹមតែ ៩០,៨% ប៉ុណ្ណោះ។

## សាលាឧទ្ធរណ៍ភ្នំពេញ

នៅសាលាឧទ្ធរណ៍ភ្នំពេញ ជនជាប់ចោទចំនួន ៨៧% (៣០១ ក្នុងចំណោម ៣៤៥ នាក់) នៅក្នុងសវនាការដែល ម.ស.ម.ក បានសង្កេត បានជាប់ឃុំក្នុងដំណើរការនៃបណ្តឹងឧទ្ធរណ៍ ហើយជនជាប់ចោទទាំងអស់ចំនួន៣០១ នាក់ (១០០%) ត្រូវបន្តការឃុំខ្លួនរងចាំស្តាប់ការប្រកាសសាលដីកា។ តួលេខនេះបានកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានចំនួនត្រឹម ៨២,៧%។ ក្នុងចំណោមអ្នកជាប់ឃុំនៅមុខសវនាការសាលាឧទ្ធរណ៍ភ្នំពេញ មានចំនួន ៥១% ត្រូវបានជាប់ឃុំរយៈពេលតិចជាង១ ឆ្នាំ។ មានចំនួន ៤៧% ទៀតត្រូវជាប់ឃុំពី ១ ឆ្នាំ ដល់២ ឆ្នាំ ហើយមានជនជាប់ចោទម្នាក់ត្រូវបានជាប់ឃុំ រហូតដល់ជាង ៣ ឆ្នាំ។

## សាលាឧទ្ធរណ៍បាត់ដំបង

នៅឆ្នាំ២០២៤ ចំនួនជនជាប់ចោទដែលត្រូវបានជាប់ឃុំក្នុងដំណើរការនៃបណ្តឹងឧទ្ធរណ៍នៅសាលាឧទ្ធរណ៍បាត់ដំបង បានកើនឡើងបើធៀបនឹងឆ្នាំ២០២៣។ ចំនួនជនជាប់ចោទដែលត្រូវបានជាប់ឃុំបានកើនឡើងពី ៧៣,៩% ក្នុងឆ្នាំ២០២៣ ដល់ ៨៦% (២០៩ ក្នុងចំណោម ២៤២ នាក់) នៅឆ្នាំ២០២៤ ដែលនេះបង្ហាញពីការកើនឡើងជាបន្តបន្ទាប់ពី ៧២% នៅឆ្នាំ២០២២ ហើយមានជនជាប់ចោទទាំងអស់ ២០៩ (១០០%) ត្រូវបន្តការឃុំខ្លួនរងចាំស្តាប់ការប្រកាសសាលដីកា។ ការកើនឡើងនៃចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួនពីមួយឆ្នាំទៅមួយឆ្នាំនេះ មិនស្របនឹងបទប្បញ្ញត្តិដែលចែងថាការឃុំខ្លួនគួរត្រូវបានអនុវត្តជាវិធានការចុងក្រោយបំផុត។ ការឃុំខ្លួននេះអាចប៉ះពាល់ជាអវិជ្ជមានលើសិទ្ធិសន្មតទុកជាមុនថាគ្មានទោស។ ការឃុំខ្លួន ជាកត្តាមួយបង្កហានិភ័យលើសិទ្ធិសន្មតទុកជាមុនថាគ្មានទោសរបស់បុគ្គលម្នាក់ៗដែលចំណាយពេលវេលាក្នុងឃុំ។ ក្នុងចំណោមសំណុំរឿងដែលត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍បាត់ដំបង រយៈពេលនៃការឃុំខ្លួននោះគឺមានចំនួន ៣៧,៥% (៣ ក្នុងចំណោម ៨ នាក់) ត្រូវបានជាប់ឃុំតិចជាង ១ ឆ្នាំ ខណៈដែល ៦២,៥% (៥ ក្នុងចំណោម ៨ នាក់) ត្រូវបានជាប់ឃុំពី ១ ឆ្នាំ ដល់ ២ ឆ្នាំ។ ខែសីហា ឆ្នាំ២០២៥ តំណាងសាលាឧទ្ធរណ៍បាត់

ដំបង បានបញ្ជាក់ថា តុលាការមិនអាចដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំបានទេ ប្រសិនបើមិនមានច្បាប់ចែងអនុញ្ញាតឱ្យចៅក្រមធ្វើដូច្នោះ។[161]

## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ មានការថយចុះចំនួននៃជនជាប់ចោទដែលបានជាប់ឃុំ បើធៀបនឹងឆ្នាំ ២០២៣។ នៅឆ្នាំ២០២៤ ជនជាប់ចោទចំនួន ៧០% (២៨ ក្នុងចំណោម ៤០នាក់) នៃសវនាការដែលបានសង្កេតដែលទទួលរងវិធានការឃុំខ្លួន ខណៈដែលចំនួន ៨២% ក្នុងឆ្នាំ ២០២៣ ហើយមានជនជាប់ចោទទាំងអស់២៨ នាក់ (១០០%) ត្រូវបន្តការឃុំខ្លួនរងចាំស្តាប់ការប្រកាសសាលដីកា។ ពាក់ព័ន្ធនឹងរយៈពេលដែលជនជាប់ចោទត្រូវជាប់ឃុំនោះ បានបង្ហាញថា ២៥% តិចជាង ១ឆ្នាំ និង ៧៥% បានជាប់ឃុំ ពី ១ ឆ្នាំ ដល់៣ ឆ្នាំ។

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួនពាក់ព័ន្ធនឹងការប្រើប្រាស់វិធានការឃុំខ្លួន។ នៅក្នុងសវនាការដែល ម.ស.ម.ក បានសង្កេតមានជនជាប់ចោទ ៨១,៦% (១០២ ក្នុងចំណោម ១២៥ នាក់) ត្រូវបានជាប់ឃុំក្នុងដំណើរការនៃបណ្តឹងឧទ្ធរណ៍ដែលមានចំនួនកើន ២៤,៧% បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៥៦,៩% ហើយមានជាប់ចោទទាំងអស់១០២ នាក់ (១០០%) ត្រូវបន្តការឃុំខ្លួនរងចាំស្តាប់ការប្រកាសសាលដីកា។ តួលេខនេះមានភាពខុសគ្នាទៅនឹងការភាពប្រសើរកន្លងមក និងសិទ្ធមានសេរីភាពផងដែរ។ តួលេខទាបនៃការឃុំខ្លួនជនជាប់ចោទមុនៗនៅតុលាការនេះហាក់ដូចជាបង្ហាញថា ចៅក្រមក្នុងដែនសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ត្បូងឃ្មុំមានទំនោរខ្ពស់ក្នុងការជ្រើសរើសជម្រើសផ្សេងជំនួសឱ្យការឃុំខ្លួន។ ដូចនេះចៅក្រមគួររក្សាការអនុវត្តនូវវិធានជាជម្រើសផ្សេងដែលមិនមែនជាការឃុំខ្លួន ដើម្បីធានានូវភាពប្រសើរនាពេលខាងមុខ។

មានចំណុចប្រសើរមួយចំនួនគឺថាមានជនជាប់ចោទត្រូវបានជាប់ឃុំ ចំនួន ៥៥,៦% មានរយៈពេលតិចជាង ១ឆ្នាំ និង៤១,៧% ត្រូវបានជាប់ឃុំខ្លួនមានចំនួនពី ១ ឆ្នាំ ដល់២ ឆ្នាំ ហើយមានជនជាប់ចោទម្នាក់ត្រូវបានជាប់ឃុំលើសពី២ ឆ្នាំ ដល់៣ ឆ្នាំ។

---

[161] នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

*តួលេខទី ៣០៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដល់ថ្ងៃសវនាការរបស់សាលាឧទ្ធរណ៍នៅតាមតុលាការគោលដៅ*[162]

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | សាលាឧទ្ធរណ៍បាត់ដំបង | សាលាឧទ្ធរណ៍ព្រះសីហនុ | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | សរុបជានាក់ |
|---|---|---|---|---|---|
| តិចជាង ១ ឆ្នាំ | ២៦ | ៣ | ៤ | ២០ | **៥៣** |
| ១ ដល់ ២ ឆ្នាំ | ២៤ | ៥ | ៤ | ១៥ | **៤៨** |
| លើស ២ ឆ្នាំ ដល់ ៣ ឆ្នាំ | ០ | ០ | ៨ | ១ | **៩** |
| លើស ៣ ឆ្នាំ ដល់ ៤ ឆ្នាំ | ១ | ០ | ០ | ០ | **១** |
| លើស ៤ ឆ្នាំ ដល់ ៥ ឆ្នាំ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| លើស ៥ ឆ្នាំ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| មិនដឹងថិរវេលាឃុំខ្លួន | ៣១៤ | ២៨២ | ២៥ | ៩០ | **៧១១** |
| សរុប | ៣៦៥ | ២៩០ | ៤១ | ១២៦ | **៨២២** |

## ៥.៤ សិទ្ធិបង្ហាញភស្តុតាង

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣) (ង) | មាត្រា ១៥៣ មាត្រា ១៥៤ មាត្រា ២៩៨ មាត្រា ៣២១ មាត្រា ៣២២ មាត្រា ៣២៤ មាត្រា ៣២៦ មាត្រា ៣២៨ និង មាត្រា ៣៩៤ | មាត្រា ៦ |

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ។ ដូច្នេះភាគីនីមួយៗត្រូវមានលទ្ធភាពបង្ហាញភស្តុតាង និងហៅសាក្សីរបស់ខ្លួន ដើម្បីសាកសួរដេញដោលលើភស្តុតាង និងសាក្សីដែលបានបង្ហាញដោយភាគីម្ខាងទៀត និងតតាំងនឹងភស្តុតាងដែលពួកគេមិនទទួលយក។[163] ចំណុចនេះជាការចាំបាច់ណាស់ ដើម្បីធានាបាននូវសិទ្ធិស្មើគ្នារវាងភាគីពាក់ព័ន្ធ និងជាគោលការណ៍មូលដ្ឋានដែលតម្រូវឱ្យមានការប្រព្រឹត្តិចំពោះភាគីទាំងអស់ ក្នុងរបៀបដែលធានានូវភាពស្មើគ្នាគ្រប់

[162] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទដែលត្រូវឃុំខ្លួនបណ្តោះអាសន្ន (៦៤០ នាក់) នៅក្នុងចំណោមសំណុំរឿងដែលត្រូវបានសង្កេតនៅក្នុងឆ្នាំ២០២៤។

[163] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ១៣, ៣៩។ សម្រាប់ព័ត៌មានលម្អិតស្តីពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិបង្ហាញភស្តុតាង (សិទ្ធិក្នុងការហៅ និងសាកសួរសាក្សី)" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/zv93nahs

ដំណាក់កាលនៃការជំនុំជម្រះ ហើយគ្មានភាគីណាមួយត្រូវបាត់បង់ឱកាសក្នុងការបង្ហាញរឿងក្តីរបស់ខ្លួនឡើយ។ យោងតាម ក.អ.ស.ព.ន ការកំណត់បទចោទព្រហ្មទណ្ឌណាមួយទៅលើបុគ្គលណាម្នាក់ បុគ្គលនោះមានសិទ្ធិ "សាកសួរ ឬឱ្យគេសាកសួរ" សាក្សីដែលដាក់បន្ទុកលើខ្លួន និងសិទ្ធិស្នើសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ។[164] ការផ្តល់ភស្តុតាងតាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ (ឧ. មិននៅក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទទេ ប្រសិនបើពួកគេបានតទល់ និងសាកសួរសាក្សីនៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ។[165]

ក្នុងរបាយការណ៍ឆ្នាំទី២បានបង្ហាញថាមិនមានសំណុំរឿងណាមួយក្នុងក្នុងចំណោម ៧៧២ ដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះបង្ហាញថាជនជាប់ចោទមិនបានទទួលឱកាសឱ្យហៅសាក្សីនោះទេ។ លើសពីនេះ ក្នុងរបាយការណ៍ឆ្នាំទី៣ក៏មិនមានភាគីណាមួយថា មិនបានទទួលឱកាសបង្ហាញភស្តុតាង ឬពិនិត្យមើលសំណុំរឿងមុនពេលសវនាការនោះទេ ឬបង្ហាញថាចៅក្រមបានចេញសាលដីកាដោយផ្អែកលើភស្តុតាងដែលមិនមាននៅក្នុងសំណុំរឿង ឬមិនបានបង្ហាញនៅក្នុងសវនាការទេ។ ទោះជាបែបនេះក្តី ក៏សិទ្ធិបង្ហាញភស្តុតាងនៅតែមិនទាន់បានគោរពពេញលេញនៅឡើយ ដោយផ្អែកលើមូលហេតុចម្បងចំនួនពីរ៖

ទីមួយ តុលាការត្រូវតែធានាថា ភស្តុតាងសំអាងទាំងនោះមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងអាចទុកចិត្តបានសម្រាប់ដំណើរការជំនុំជម្រះ (តម្លៃពេញលេញនៃភស្តុតាង)។ ភស្តុតាងដែលត្រូវបានបង្ហាញ និងពិនិត្យទាំងគុណភាព និងបរិមាណ ក្នុងអំឡុងពេលជំនុំជម្រះ គឺសំខាន់ណាស់ដើម្បីធានាថា បន្ទុកភស្តុតាងហួសពីវិមតិសង្ស័យ។ ក្រៅពីភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញា គួរតែស្វែងរក និងពិនិត្យមើលលើប្រភេទភស្តុតាងផ្សេងទៀតដែលពាក់ព័ន្ធ ដូចជា សាក្សីផ្ទាល់ ភស្តុតាងវេជ្ជសាស្ត្រ និងភស្តុតាងកោសល្យវិច្ច័យជាដើម។ ទោះជាយ៉ាងនេះក្តី ម.ស.ម.ក បានកត់សម្គាល់ឃើញថា មិនមានការបង្ហាញភស្តុតាងជាវេជ្ជសាស្ត្រ ឬកោសល្យវិច្ច័យក្នុងសវនាការដែលបានសង្កេតនៅឆ្នាំ ២០២៤ នោះទេ។ នេះជាការថយចុះពីឆ្នាំ២០២៣ ដែលការបង្ហាញភស្តុតាងខាងលើនេះ មាននៅក្នុងសំណុំរឿងមួយចំនួនតូច ពោលគឺ ០,១៣% នៃសំណុំរឿងដែលបានសង្កេតនៅក្នុងឆ្នាំ២០២៣។ គួរឱ្យកត់សម្គាល់បន្ថែមទៀតនោះគឺ សាក្សីដែលត្រូវបានហៅមកធ្វើសក្ខីកម្មមានតែ ១១,៩% (៦៩ ក្នុងចំណោម ៥៨២ សំណុំរឿង)។ តួលេខនេះ បង្ហាញពីការកើនឡើងបើធៀបនឹងឆ្នាំ

---

164 ក.អ.ស.ព.ន. មាត្រា ១៤(៣)(ង)

165 អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, Mirilashvili *ទល់នឹង ប្រទេសរុស្ស៊ី* (ថ្ងៃទី ១១ ធ្នូ ២០០៨), បណ្តឹងលេង លេខ ៦២៩១/០៤ វាក្យខណ្ឌ ១៦៣ https://tinyurl.com/4kktr8yr;
តុលាការសិទ្ធិមនុស្សអឺរ៉ុប Asch ទល់នឹងប្រទេសអូទ្រីស (ថ្ងៃ២៦ ខែមេសា ឆ្នាំ១៩៩១) សេរី A លេខ ២០៣ វាក្យខណ្ឌ ២៨ https://tinyurl.com/bdfpm2ah;
តុលាការសិទ្ធិមនុស្សអឺរ៉ុប Isgrò *ទល់នឹងប្រទេសអ៊ីតាលី* (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩១) សេរី A លេខ ១៩៤-A វាក្យខណ្ឌ ៣៤ https://tinyurl.com/39mz7s7h;
តុលាការសិទ្ធិមនុស្សអឺរ៉ុប Kostovski ទល់នឹងប្រទេសហូឡង់ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) សេរី A លេខ ១៦៦ វាក្យខណ្ឌ ៤១ https://tinyurl.com/2e2pbxsh

២០២៣ ដែលមានតែ ៧% តែប៉ុណ្ណោះ។ ភាពខ្វះខាតក្នុងការបង្ហាញភស្តុតាងក្នុងទម្រង់ផ្សេងៗគ្នា មិនត្រឹមប៉ះពាល់ដល់ភាពរឹងមាំនៃដំណើរនីតិវិធីរបស់តុលាការនោះទេ តែថែមទាំងអាចប៉ះពាល់ដល់ការទទួលបានយុត្តិធម៌ និងភាពត្រឹមត្រូវនៃការសម្រេចសេចក្តីផងដែរ។

ទីពីរ ច្បាប់កម្ពុជាកំណត់ថាអ្នកជំនាញ និងសាក្សីដែលតុលាការកោះហៅ ត្រូវរង់ចាំនៅក្នុងបន្ទប់ដែលបានរៀបចំជាស្រេចសម្រាប់ពួកគេ ដែលពួកគេមិនត្រូវបានអនុញ្ញាតឱ្យមើល ឬស្តាប់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មនោះទេ[166]។ ចំណែកឯសាក្សីដែលមិនត្រូវបានកោះហៅជាផ្លូវការ អាចចូលក្នុងបន្ទប់សវនាការតាំងពីដំបូងបាន តែពួកគេនឹងត្រូវបានណែនាំឱ្យនៅក្នុងបន្ទប់រង់ចាំ ប្រសិនបើប្រធានសវនាការសម្រេចថានឹងស្តាប់ចម្លើយរបស់ពួកគេ នៅពេលដែលមានការស្នើសុំពីភាគីណាមួយប៉ុណ្ណោះ។[167] ទោះបីជាយ៉ាងណាក៏ដោយ មានចំនួន ៥៦,៥% ដែលសាក្សីត្រូវបានកោះហៅ (៣៩ ក្នុងចំណោម ៦៩ សំណុំរឿង) សាក្សីទាំងនោះមានវត្តមានក្នុងបន្ទប់សវនាការមុនពេលពួកគេផ្តល់សក្ខីកម្ម។ តួលេខនេះបង្ហាញការធ្លាក់ចុះនូវការលើកកម្ពស់សិទ្ធិនេះបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៣៦,៨% និង៤១,៩% ក្នុងឆ្នាំ ២០២២។ យ៉ាងនេះក៏ដោយការអនុញ្ញាតឱ្យសាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការ អាចនាំឱ្យសក្ខីកម្មរបស់សាក្សីទទួលឥទ្ធិពល។ ទោះបីជាការអនុវត្តបែបនេះ មានភាពខុសគ្នាពីតុលាការមួយទៅតុលាការមួយទៀតក៏ដោយ ក៏ពុំទាន់មានភាពប្រសើរនៅឡើយពាក់ព័ន្ធនឹងការមានវត្តមានរបស់សាក្សីក្នុងបន្ទប់សវនាការ ក្នុងចំណោមតុលាការទាំងបួន។

ក្នុងសំណុំរឿងដែលសាក្សីត្រូវបានហៅមកផ្តល់សក្ខីកម្មនៅសាលាឧទ្ធរណ៍ភ្នំពេញ សាក្សីដែលមានវត្តមានក្នុងបន្ទប់សវនាការមានចំនួន ៤៦% (៦ ក្នុងចំណោម ១៣ សំណុំរឿង)។ នេះជាការថយចុះគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៣ ដែលមិនមានការអនុវត្តនេះទេ។ ក្នុងឆ្នាំ២០២៤ មានការថយចុះនូវការប្រតិបត្តិល្អគួរឱ្យកត់សម្គាល់ទៅលើចំណុចនេះនៅសាលាឧទ្ធរណ៍បាត់ដំបង ដែលសាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មមានចំនួន ៧១% (២០ ក្នុងចំណោម ២៨ សំណុំរឿង) នៃសំណុំរឿងដែលបានសង្កេតជាតួលេខដែលកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានចំនួនតែ ៣៩% ប៉ុណ្ណោះ។ ក្នុងឆ្នាំ២០២៤ នៅសាលាឧទ្ធរណ៍ព្រះសីហនុ មានសាក្សីដែលវត្តមាននៅបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មចំនួន ៥០% (៣ ក្នុងចំណោម ៦ សំណុំរឿង) ដែលកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានចំនួនតែ ២៨,៦%។ នៅខែសីហា ឆ្នាំ ២០២៥ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា ចៅក្រមបានពិចារណាទៅលើភាពស្មុគស្មាញនៃសំណុំរឿង ករណីសំណុំរឿងមិនមានភាពស្មុគស្មាញ ចៅក្រមអាចឱ្យសាក្សីមានវត្តមានក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្ម ផ្ទុយទៅវិញ បើសំណុំរឿងមានស្មុគស្មាញ នុះចៅកម្រមិនអាចអនុញ្ញាតឱ្យសាក្សីស្ថិតក្នុង

[166] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២២។

[167] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៤។

បន្ទប់សវនាការទេមុនពេលផ្តល់សក្ខីកម្ម។[168] នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ក្នុងឆ្នាំ២០២៤ វត្តមានរបស់សាក្សីក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មមានចំនួន ៤៥% (១០ ក្នុងចំណោម ២២ សំណុំរឿង) មានការកើនឡើងបើធៀបនឹងឆ្នាំ២០២៣ មានចំនួនតែ ៣៨%។ ដូចនេះ តុលាការគួរមានវិធានការសមស្រប ដើម្បីធានានូវសិទ្ធិក្នុងការបង្ហាញភស្តុតាងនេះ។

ជាចុងក្រោយ ជនជាប់ចោទជាច្រើននាក់ក្នុងសំណុំរឿងដែលបានសង្កេតមិនមានមេធាវីការពារសិទ្ធិ ដូចបញ្ជាក់នៅក្នុងចំណុច ៥.២ អាចនាំឱ្យមានចម្ងល់អំពីសមត្ថភាពរបស់ជនជាប់ចោទយល់ដឹងពីប្រយោជន៍នៃសិទ្ធិនេះ ព្រមទាំងការអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាពក្នុងការហៅសាក្សី និងសាកសួរសាក្សីរបស់ភាគីម្ខាងទៀត ហេតុដូច្នេះហើយការគោរពតាមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ គួរត្រូវបានពិចារណា។ មូលហេតុមួយទៀតដែលជាការកត់សម្គាល់ គឺលទ្ធភាពរបស់ជនជាប់ចោទដែលមិនមានមេធាវីការពារ មិនអាចទទួលសំណុំរឿងរបស់ខ្លួនមកពិនិត្យផងដែរ។ ទោះបីជា គ្មានសំណុំរឿងណាមួយដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានបង្ហាញថាមិនមានការលើកឡើងពីបញ្ហាទាក់ទងនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការពារក្តីក៏ដោយ យោងតាមបទប្បញ្ញត្តិរបស់ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យមេធាវីការពារក្តីពិនិត្យមើលសំណុំរឿង និងថតចម្លងឯកសារសំណុំរឿង តែមិនបានផ្តល់សិទ្ធិដូចគ្នាដល់ជនជាប់ចោទដែលមិនមានមេធាវីការពារនោះឡើយ។[169] ប្រការនេះអាចបង្កជាឧបសគ្គដល់ជនជាប់ចោទ ក្នុងការទទួលបានការពិនិត្យមើលសំណុំរឿង និងភស្តុតាងទាំងឡាយដែលប្រឆាំងនឹងខ្លួន ព្រមទាំងមិនអាចរៀបចំការការពារដោយខ្លួនឯងបានត្រឹមត្រូវ និងគ្រប់គ្រាន់នោះទេ។

## ៥.៥ សិទ្ធិកុមារទំនាស់នឹងច្បាប់

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|---|
| ក.អ.ស.ព.ន | អ.ស.ក | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (១) | មាត្រា ៣៧ និង ៤០ | មាត្រា ៣១ និង ៤៨ | មាត្រា ១០០ និង ២១២ | មាត្រា ៣៩ និង ៤០ | មាត្រា ៥, ៦, ៣៩, ៤៧, ៤៨, ៤៩, ៥៤, ៥៧ និង ៨២ |

ច្បាប់អន្តរជាតិធានាចំពោះសិទ្ធិរបស់កុមារ - ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដែលបានរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវអនុវត្តដូចគ្នានឹងមនុស្សពេញវ័យ

[168] នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[169] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥, ២៥៤, ៣០៤, ៣១៩, ៣៩១, ៤២៨។

ដែរ។ ប៉ុន្តែកុមារត្រូវទទួលបាននូវកិច្ចការពារពិសេសផងដែរ ដោយផ្អែកលើអាយុ ភាពដឹងក្តី និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី។[170]

ក.អ.ស.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក.") ដែលបានចូលជាធរមាននៅប្រទេសកម្ពុជានៅឆ្នាំ១៩៩២ ចែងអំពីបទប្បញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តិលើកុមារក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌដែលគាំពារដោយច្បាប់ និងគោលការណ៍ណែនាំអន្តរជាតិជាច្រើន។[171] ច្បាប់ និងគោលការណ៍អន្តរជាតិទាំងនោះ បង្ហាញពីភាពចាំបាច់សម្រាប់រដ្ឋភាគីក្នុងការង្កើតច្បាប់ នីតិវិធីផ្សេងៗ អាជ្ញាធរ និងស្ថាប័ន ដែលអនុវត្តជាពិសេស ចំពោះកុមារទំនាស់នឹងច្បាប់ ឬទទួលស្គាល់ថាមានច្បាប់ព្រហ្មទណ្ឌដែលបានបំពានលើសិទ្ធិកុមារ។ ជាពិសេស រដ្ឋត្រូវកំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកុមារត្រូវសន្មតថាមិនមានសមត្ថភាពក្នុងការយល់ដឹងពីច្បាប់ព្រហ្មទណ្ឌ។[172]

កុមារដែលមានអាយុអប្បបរមា ឬលើសពីអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែក្រោមអាយុ ១៨ ឆ្នាំ អាចត្រូវបានចោទប្រកាន់ជាផ្លូវការ និងទទួលបាននីតិវិធីយុត្តិធម៌កុមារស្របតាម អ.ស.ក។[173] ទោះបីជាយ៉ាងនេះក្តី រដ្ឋភាគីត្រូវបានតម្រូវឱ្យលើកកម្ពស់វិធានការដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ដោយមិនឈានទៅរកដំណើរការនីតិវិធីតុលាការ "នៅពេលដែលសមស្រប"។[174] លើសពីនេះ ការសម្រេចមួយចំនួនគួរត្រូវបានធ្វើដូចជា ការថែទាំ ការណែនាំ និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការផ្តល់ប្រឹក្សា ការព្យួរទោសសាកល្បង ការថែទាំជំនួស វិធានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជម្រើសផ្សេងទៀតតាមរយៈការថែទាំដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាថាកុមារត្រូវបានដោះស្រាយដោយគិតគូរពីសុខុមាលភាពរបស់ពួកគេ ហើយថែមទាំងស្របទៅតាមកាលៈទេសៈ និងបទល្មើសរបស់ពួកគេផងដែរ។[175] ច្បាប់កម្ពុជាបានបញ្ញត្តិបន្ថែមពីការប្រព្រឹត្តិលើកុមារទំនាស់នឹងច្បាប់ខុសៗគ្នានៅក្នុងផ្នែកសំខាន់ៗជាច្រើន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារទំនាស់នឹងច្បាប់។

### *ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ*

ច្បាប់កម្ពុជាបានកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពី ១៤ ឆ្នាំ ដែលស្របគ្នាទៅនឹងការអនុវត្តរបស់រដ្ឋផ្សេងទៀតជាអន្តរជាតិ។[176] នេះមានន័យថាគ្មានកុមារណាម្នាក់ក្រោមអាយុដែលបានកំណត់នេះនឹងត្រូវបានតុលាការជំនុំជម្រះ នៅពេលមានបទល្មើសកើតឡើងនោះទេ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វែងរក

---

[170] អ.ស.ក មាត្រា ១។

[171] ឧទាហរណ៍ វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) ឬវិធានច្បាប់របស់ អង្គការសហប្រជាជាតិស្តីពីការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ក្នុងចំណោមវិធានច្បាប់ផ្សេងៗ។

[172] អ.ស.ក មាត្រ ៤០(៣)។

[173] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

[174] អ.ស.ក មាត្រា ៤០ (៣); គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។

[175] អ.ស.ក មាត្រា ៤០ (៤)។

[176] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១ ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា៣៨ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

កស្តុតាងដើម្បីកំណត់អាយុរបស់កុមារដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដែលរួមមានដូចជា ស្វែងរកសំបុត្រកំណើត ឬឯកសារបញ្ជាក់កំណើត ឬប្រើប្រាស់មធ្យោបាយដែលអាចទុកចិត្តបានផ្សេងទៀតដែលតុលាការអាចទទួលយកបានដើម្បីកំណត់អាយុរបស់ពួកគេ ក្នុងករណីដែលគ្មានឯកសារបញ្ជាក់កំណើត។ ករណីមានការសង្ស័យណាមួយទាក់ទងនឹងអាយុរបស់កុមារ ត្រូវតែដោះស្រាយឱ្យបានត្រឹមត្រូវដោយគិតពីប្រយោជន៍របស់កុមា។[177] តុលាការត្រូវតែផ្ទៀតផ្ទាត់អាយុរបស់កុមារទំនាស់នឹងច្បាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលខ្លួនទទួលបន្ទុកក្នុងការជំនុំជម្រះ។ ប្រសិនបើអាចកំណត់បានថា កុមារដែលរងការចោទប្រកាន់មានអាយុក្រោម ១៤ ឆ្នាំ នៅពេលបទល្មើសកើតឡើង ឬប្រសិនបើមានការសង្ស័យអំពីអាយុរបស់ពួកគេនៅពេលបទល្មើសកើតឡើង នោះចៅក្រមត្រូវឱ្យពួកគេរួចផុតពីបទចោទភ្លាមៗ។

នៅក្នុងឆ្នាំ២០២៤ ក្នុងចំណោមជនជាប់ចោទចំនួន ៨២២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតនៅតុលាការគោលដៅទាំងបួន មានជនជាប់ចោទតែ ៩ នាក់ប៉ុណ្ណោះគឺជាកុមារនៅពេលមានបទល្មើសកើតឡើង ហើយពួកគេទាំងអស់ជាក្មេងប្រុស។

សម្រាប់រយៈពេល ៣ ឆ្នាំជាប់ៗគ្នា គ្មានកុមារណាម្នាក់មានអាយុក្រោមច្បាប់កំណត់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ មានកុមារម្នាក់ អាយុពី ១៤ ដល់១៥ ឆ្នាំ ហើយចំនួន ៨ នាក់ផ្សេងទៀតមានអាយុពី ១៦ ដល់១៧ ឆ្នាំ។ មានកុមារដែលទំនាស់នឹងច្បាប់ម្នាក់ បានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ចំនួន ៧ នាក់បានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍បាត់ដំបង និងម្នាក់បានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ មិនមានករណីកុមារទំនាស់នឹងច្បាប់ដែល ម.ស.ម.ក បានសង្កេតនៅសាលាឧទ្ធរណ៍ព្រះសីហនុនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះទេ។ កុមារទំនាស់នឹងច្បាប់ចំនួន ១ នាក់ អាយុ ១៤ ដល់១៥ ឆ្នាំ ត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍បាត់ដំបង និងកុមារចំនួន ៩ នាក់ផ្សេងទៀតដែលបានបង្ហាញខ្លួននៅចំពោះមុខតុលាការនេះមានអាយុ ១៦ ដល់១៧ ឆ្នាំ។ ចំនួនម្នាក់បានបង្ហាញខ្លួនចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ និងម្នាក់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំពាក់ព័ន្ធនឹងជនជាប់ចោទជាកុមារអាយុ ១៦ ដល់១៧ ឆ្នាំ។

*តួលេខទី ៣១៖ អាយុរបស់កុមារដែលរងការចោទប្រកាន់នៅពេលមានបទល្មើសកើតឡើង*[178]




177 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

178 ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុបចំនួន ០៩ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅក្នុងឆ្នាំ២០២៤។

*សិទ្ធិមានសេរីភាព និងការសន្មតជាមុនថាគ្មានទោស*

វិធានការឃុំខ្លួន មិនគួរត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នោះទេ លើកលែងតែសំណុំរឿងធ្ងន់ធ្ងរបំផុត និងក្រោយពេលដាក់ឱ្យកុមារចូលទៅក្នុងសហគមន៍ បន្ទាប់ពីការពិចារណាដោយយកចិត្តទុកដាក់។[179] ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងយ៉ាងច្បាស់ថា ការឃុំខ្លួនលើកុមារទំនាស់នឹងច្បាប់គឺជាវិធានការចុងក្រោយបំផុត និងចែងថាសាលាឧទ្ធរណ៍ត្រូវពិចារណាដោះលែងកុមារដែលជាប់ឃុំឱ្យមានសេរីភាពដើម្បីការពារឧត្តមប្រយោជន៍របស់ពួកគេ។[180] លើសពីនេះ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបានចែងថា អនីតិជនដែលបានប្រព្រឹត្តបទល្មើសត្រូវជាកម្មវត្ថុនៃ "វិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ"។ [181] មាត្រា ៤០ នៃក្រមនេះ បន្តចែងថា វិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ រួមមាន ដូចជា (១) ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សា អនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត (២)ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន (៣)ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន (៤)ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស (៥)ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។ ទោះបើជាមានបទប្បញ្ញត្តិទាំងនេះក៏ដោយ ការសង្កេតសវនាការរបស់ ម.ស.ម.ក បានបង្ហាញពីការប្រើប្រាស់វិធានការឃុំខ្លួនស្ទើរតែជាទម្លាប់នៅក្នុងករណីពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់។ នៅក្នុងឆ្នាំ២០២៤ នៃជនជាប់ចោទជាកុមារនៅក្នុងសំណុំរឿងដែលបានសង្កេត មានចំនួន ៥៥% (៥ នាក់ ក្នុងចំណោម ៩ នាក់) គឺត្រូវបានឃុំខ្លួន បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួន ៨០,៨%។ យ៉ាងណាមិញ គួរកត់សម្គាល់លើចំណុចនេះផងដែរថា ចំនួនជនជាប់ចោទជាកុមារនៅក្នុងរយៈពេលពីរឆ្នាំនេះមានការប្រែប្រួលហើយបើធៀបពីមួយឆ្នាំទៅមួយឆ្នាំតែមិនទាន់បានទទួលនូវកិច្ចការពារពេញលេញនៅឡើយ។

ការលើកកម្ពស់សិទ្ធិសេរីភាពនៃជនជាប់ចោទជាកុមារ បានថយចុះចាប់តាំងពីឆ្នាំ២០១៤ និង២០១៥ មក ខណៈនោះមានចំនួន ៦២% នៃជនជាប់ចោទជាកុមារ ត្រូវបានឃុំខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ ដែលនៅពេលនោះតុលាការមានយុត្តាធិការលើទូទាំងប្រទេស។ តួលេខនេះបញ្ជាក់ថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ មិនទាន់បានអនុវត្តឱ្យប្រសើឡើងនៅឡើយដែលទាក់ទងនឹងការការពារសិទ្ធិដ៏សំខាន់នេះទេ ទោះបីជាច្បាប់នេះបានបង្កើតនូវវិធានបង្វែរជនល្មើសដែលជាកុមារ ជាជម្រើសជំនួសឱ្យការឃុំខ្លួនក្តី។[182]
ទោះជាយ៉ាងនេះក្តី នៅក្នុងឆ្នាំ២០២៤ មិនមានសំណុំរឿងណាមួយនៅក្នុងចំណោមសំណុំរឿងចំនួន ៧ ពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន ដែល ម.ស.ម.ក បានស្តាប់សាលដីកានោះទេ ថាតើចៅក្រមបានពិចារណាកាត់

[179] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៨៦។
[180] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៣៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧។
[181] ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៩។
[182] ក្រមព្រហ្មទណ្ឌ មាត្រា ៤០ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនជំពូក ១០។

ទោសមិនដាក់ពន្ធនាគារ ឬដាក់ពន្ធនាគារនោះទេ។ មានសំណុំរឿងចំនួន ៥ បានជំនុំជម្រះនៅចំពោះមុខសាលាឧទ្ធរណ៍បាត់ដំបង ១ សំណុំរឿងនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ និង ១ ទៀតនៅសាលាឧទ្ធរណ៍ភ្នំពេញ។

ចៅក្រមបានពិចារណាការកាត់ទោសដែលជាជម្រើសមិនដាក់ពន្ធនាគារមានចំនួន ២៧% នេះជាសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០២៣។ គួរកត់សម្គាល់ថាមិនមានសំណុំរឿងណាមួយដែល ម.ស.ម.ក បានសង្កេតពាក់ព័ន្ធនឹងជនជាប់ចោទជាកុមារដែលចៅក្រមបានយោងទៅមាត្រា ៣៨ ឬ៣៩ នៃក្រមព្រហ្មទណ្ឌដែលផ្ដោតទៅលើជនជាប់ចោទជាអនីតិជននោះទេ។

*តួលេខទី ៣២៖: ចំនួនភាគរយនៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានឃុំខ្លួនក្នុងឆ្នាំ២០២៤*[183]




ក្នុងរបាយការណ៍ឆ្នាំទី៣ មានចំនួន ៥៥% (៥ ក្នុងចំណោម ៩ នាក់) នៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានឃុំខ្លួន និងប្រើឯកសណ្ឋានពន្ធនាគារ។ ភាពប្រសើរបានថយចុះបើធៀបនឹងឆ្នាំ២០២៣ ដែលគ្មានកុមារទំនាស់នឹងច្បាប់ណាម្នាក់បង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារពណ៌ខៀវនោះទេ រីឯនៅឆ្នាំ ២០២៤ មានចំនួនដល់ ១០០% (៣ ក្នុងចំណោម ៣ នាក់) នៃកុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំ និងមានវត្តមានក្នុងសវនាការ បានស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវនៅចំពោះមុខសាលាឧទ្ធណ៍បាត់ដំបង។ នេះជាការគួរកត់សម្គាល់ដែលដែលជនជាប់ចោទជាកុមារបង្ហាញខ្លួនក្នុងឯកសណ្ឋានពន្ធនាគារពណ៌ខៀវ ចូលរួមក្នុងសវនាការរបស់ពួកគេ ដូចបានរៀបរាប់នៅក្នុងផ្នែក ៤.៥ ខាងលើ។ មានកុមារទំនាស់នឹងច្បាប់ចំនួន ១ នាក់ នៅសាលាឧទ្ធរណ៍ភ្នំពេញ និង ១ នាក់ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលពួកគេបានស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ គួរមានការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធ្វើឱ្យមានភាពប្រសើរលើចំណុចនេះ។ ចំពោះដំណើរការជំនុំជម្រះលើសំណុំរឿងកុមារទំនាស់នឹងច្បាប់ដែលតម្រូវឱ្យស្លៀកឯកសណ្ឋានណាមួយអាចជាបទពិសោធន៍ដែលមានការប៉ះទង្គិចដល់កុមារ ហើយចាំ បាច់ត្រូវការពារឧត្តមប្រយោជន៍របស់កុមារ ឱ្យបានពេញលេញនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីទាំងមូល។

[183] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប (៩ នាក់)ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅក្នុងឆ្នាំ ២០២៤។

ម.ស.ម.ក ក៏សូមស្នើឱ្យតុលាការគោលដៅ និងអគ្គនាយកដ្ឋានពន្ធនាគារ ពង្រឹងការអនុវត្តល្អបន្ថែមទៀត ដើម្បីធានាថាកុមារទំនាស់នឹងច្បាប់អាចចូលរួមសវនាការដោយស្លៀកពាក់ឯកសណ្ឋានស៊ីវិល។

*ការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់*

យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ កុមារមានសិទ្ធិទទួលបានការគោរពឯកជនភាពរបស់ពួកគេនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី រាប់បញ្ចូលចាប់ពីដំណាក់កាលដំបូងនៃការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចជាស្ថាពរ។[184] សិទ្ធិនេះ ក៏ត្រូវអនុវត្តផងដែរប្រសិនបើកុមារត្រូវបានចោទប្រកាន់ ដូចជាការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការឃាត់ខ្លួន/ឃុំឃាំង ឬការដកហូតសេរីភាព។ ហេតុផលជាមូលដ្ឋាននៃសិទ្ធិនេះ គឺដើម្បីជៀសវាងការប៉ះពាល់ដែលបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬការបង្ខូចកេរ្តិ៍ឈ្មោះណាមួយ។ ដូច្នេះ សវនាការលើកុមារទំនាស់នឹងច្បាប់ត្រូវធ្វើឡើងជាអសាធារណៈ។ ក្នុងបរិបទនៃច្បាប់កម្ពុជាជាពិសេស ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងយ៉ាងច្បាស់ថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមនៃរឿងក្តីអនីតិជនត្រូវធ្វើក្នុងសវនាការជាអសាធារណៈ។[185]

ឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ឬកុមាររងគ្រោះអាចត្រូវបានការពារបន្ថែមទៀតដោយមិនបង្ហាញអត្តសញ្ញាណរបស់ពួកគេ តាមរយៈការដាក់បាំងរនាំង ឬប្រើមធ្យោបាយផ្សេងទៀតក្នុងពេលផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា ដូចជាសវនាការតាមប្រព័ន្ធវីដេអូ ឬសវនាការអសាធារណៈ គួរតែត្រូវបានពិចារណា។ ប្រសិនបើសាលក្រម ឬការផ្តន្ទាទោសត្រូវប្រកាសជាសាធារណៈ នោះអត្តសញ្ញាណរបស់កុមារ មិនគួរត្រូវបានបង្ហាញឡើយ។[186] ជាចុងក្រោយ រាល់ឯកសារទាក់ទងនឹងកុមារ គួរតែត្រូវបានរក្សាការសម្ងាត់យ៉ាងតឹងរ៉ឹង និងមិនបើកចំហដល់ភាគីទីបី លើកលែងចំពោះតែអ្នកដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការស៊ើបអង្កេត និងការវិនិច្ឆ័យលើសំណុំរឿង។[187] ប្រការនេះត្រូវធានាឱ្យបាន ទោះបីជានៅពេលកុមារឈានដល់អាយុ ១៨ ឆ្នាំ ក៏ដោយ។[188]

នៅឆ្នាំ២០២៤ ចៅក្រមបានចាត់វិធានការ (សវនាការអសាធារណៈ) ដើម្បីការពារឯកជនភាពកុមារទំនាស់នឹងច្បាប់ចំនួន ៧៧,៨% (៧ នាក់ ក្នុងចំណោម ៩ នាក់) នៅក្នុងសំណុំរឿងដែលបានសង្កេត។ ទិន្នន័យនេះបានកើនបន្តិច បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៥២,៩% (៩ នាក់ក្នុងចំណោម ១៧ នាក់)។ គួរបញ្ជាក់ថា សំណុំរឿងទាំងអស់ទាក់ទងនឹងកុមារទំនាស់នឹងច្បាប់មាននៅសាលាឧទ្ធរណ៍បាត់ដំបង គឺចៅក្រមបានធ្វើសវនាការជាអសាធារណៈ។ វិធានក្នុងការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ មិនទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយទេនៅសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

---

[184] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(២)(vii) មាត្រា ១៦ មាត្រា ៤០(១) គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៦ ៧៩។

[185] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤៧។

[186] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[187] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[188] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

*ការបែងចែកជនជាប់ឃុំជាកុមារក្នុងពន្ធនាគារ*

បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌កុមារចែងថា កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពត្រូវដាក់ឱ្យដាច់ដោយឡែកពីជនជាប់ឃុំជាមនុស្សពេញវ័យ និងត្រូវនៅក្នុងកន្លែងដាច់ដោយឡែកពីមន្ត្រីដែលទទួលបន្ទុក ហើយមន្ត្រីទាំងនោះបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងប្រតិបត្តិតាមគោលនយោបាយ និងអនុវត្តប្រកបដោយកុមារមេត្រី។ ករណីលើកលែងអាចអនុវត្តបានតែដើម្បីឧត្តមប្រយោជន៍របស់កុមារដែលត្រូវឃុំខ្លួនប៉ុណ្ណោះ[189]។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា កុមារដែលត្រូវបានដកហូតសេរីភាពត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកជាប់ឃុំពេញវ័យ ហើយត្រូវឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាដែលគ្រប់គ្រងដោយមន្ត្រីដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវស្តីពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ បទដ្ឋានសិទ្ធិកុមារជាតិ និងអន្តរជាតិ និងការប្រព្រឹត្តិចំពោះកុមារជាប់ឃុំ។ ច្បាប់នេះបានចែងបន្ថែមទៀតថា អនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិតជាកុមារ។[190] ជាចំណុចគួរឱ្យកត់សម្គាល់ សម្រាប់រយៈពេលបីឆ្នាំជាប់ៗគ្នានេះ គ្មានការបង្ហាញថាកុមារទំនាស់នឹងច្បាប់ណាម្នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៤ ត្រូវបានឃុំខ្លួនជាមួយជនជាប់ឃុំពេញវ័យនោះទេ។

*តួលេខទី៣៣៖ ភាគរយនៃជនជាប់ចោទជាកុមារដែលត្រូវបានឃុំខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅទាំងបួន (ពីឆ្នាំ២០២២)*[191]




## សេចក្តីសន្និដ្ឋាន

ទោះបីជាចំនួនសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ មានចំនួនតិចនៅក្នុងសំណុំរឿងដែលបានសង្កេតនៅក្នុងឆ្នាំ២០២៤ក្តី យើងក៏នៅតែអាចធ្វើការសន្និដ្ឋានបាន ខណៈដែលវិធាននានាត្រូវបានអនុវត្តដើម្បី

---

[189] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៩២ និង ៩៣។

[190] ច្បាប់យុត្តិធម៌អនីតិជន។

[191] ទិន្នន័យនេះផ្អែកលើចំនួនកុមារជំទាស់នឹងច្បាប់ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតក្នុងអំឡុងពេលធ្វើការរាយការណ៍នីមួយៗ។ ដោយហេតុហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្តប់ទូទាំងប្រទេស មុនពេលដែលសាលាឧទ្ធរណ៍ទាំងបីចាប់ផ្តើមដំណើរការក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការថ្នាក់ជាតិ។ តួលេខចាប់ពីឆ្នាំ២០២២ ទៅមុខគឺ ម.ស.ម.ក បានចាប់ផ្តើមការសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីបន្ថែមទៀត។ តួលេខក្នុងឆ្នាំ២០២១ ត្រូវបានបង្ហាញផងដែរដើម្បីបញ្ចៀសគម្លាតនៃទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពនៅក្នុងដែលស្ថិតក្រោមយុត្តាធិការរបស់សាលា ឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។

លើកកម្ពស់សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលនាំឱ្យសិទ្ធិទាំងនេះមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយដែរ។ មានការកត់សម្គាល់ថាវិធានការឃុំខ្លួនក្នុងសំណុំរឿងកុមារទំនាស់នឹងច្បាប់ត្រូវបានអនុវត្តជាញឹកញាប់ និងមានការកើនឡើងនូវការប្រើប្រាស់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវ (ជាឯកសណ្ឋានសម្រាប់ទណ្ឌិត) ព្រមទាំងអាចប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ និងវិធានការការពារឯកជនភាពអំឡុងពេលសវនាការគួរត្រូវបានកែលម្អ។ ដូច្នេះ គួរមានវិធានការសមស្របត្រូវបានអនុវត្តដើម្បីលើកកម្ពស់សិទ្ធិនេះ និងធានាថាកុមារទំនាស់នឹងច្បាប់ទទួលបានយុត្តិធម៌ និងសមធម៌ពេញលេញក្នុងដំណើរការនីតិវិធីទាំងមូល។

# ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

បេកគំហើញការសង្កេតសវនាការក្នុងឆ្នាំ២០២៤ បានបង្ហាញអំពីវឌ្ឍភាពមួយចំនួនលើធាតុសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ម.ស.ម.ក បានកត់សម្គាល់ឃើញថា សាលាឧទ្ធរណ៍ទាំងបួនមិនទាន់បានគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួន ដូចបានបង្ហាញក្នុងរបាយការណ៍នេះ។ សិទ្ធិមួយចំនួនមិនទាន់បានលើកកម្ពស់ពេញលេញនៅបន្តកើតមាន ដូចជា វិធាននៃការឃុំខ្លួនពាក់ព័ន្ធនឹងសំណុំរឿងកុមារទំនាស់នឹងច្បាប់ ការបន្តធ្វើទារុណកម្មនៅដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនទាន់បានអនុវត្តពេញលេញនៅឡើយនៅក្នុងឆ្នាំ២០២៤។

ជារួម ចំណុចមួយចំនួនដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ អាចត្រូវបានដោះស្រាយតាមរយៈវិធីងាយៗ អាចចំណាយធនធានតិច និងអាចអនុវត្តទៅបាន។ ករណីផ្សេងទៀត អាចតម្រូវឱ្យមានការបណ្តុះបណ្តាលដល់ចៅក្រម និងមេធាវីអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយបន្ទាប់ពីនោះគឺជាឆន្ទៈរបស់គាត់ក្នុងការគោរពសិទ្ធិទាំងនេះ។ តាមរយៈការអនុវត្តវិធានការភ្លាមៗ និងចាំបាច់ទាំងនេះសាលាឧទ្ធរណ៍ក៏អាចជាគំរូដល់សាលាដំបូងផងដែរ និងមានឥទ្ធិពលជាវិជ្ជមានដល់គុណភាពនៃការគ្រប់គ្រងយុត្តិធម៌នៅកម្ពុជា ព្រមទាំងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ ដើម្បីជាប្រយោជន៍ដល់គ្រប់ភាគីក្នុងដំណើរការសវនាការ និងសង្គមជាតិទាំងមូល។

## ៦.១ អនុសាសន៍រួម

៦.១.១ ក្រសួងយុត្តិធម៌គួររៀបចំកិច្ចប្រជុំជាទៀងទាត់ ស្តីពីការអនុវត្តជាក់ស្តែងនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមួយចៅក្រមសាលាឧទ្ធរណ៍ ដើម្បីលើកកម្ពស់ការគោរពគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្អែកលើមូលដ្ឋាននៃបទដ្ឋានជាតិ និងអន្តរជាតិ។

៦.១.២ ក្រសួងយុត្តិធម៌គួរបង្កើតទម្រង់បទដ្ឋានសម្រាប់សេចក្តីសម្រេច និងបញ្ជូនទៅគ្រប់តុលាការទាំងអស់ដើម្បីអនុវត្ត។ ទម្រង់នេះគួរមានព័ត៌មានដូចខាងក្រោម ដើម្បីជានាថារបាយការណ៍សង្ខេបដែលចៅក្រមប្រធានក្រុមប្រឹក្សាអាន គឺមានភាពពេញលេញ៖

១. បទល្មើសដែលបានចោទប្រកាន់លើជនជាប់ចោទ និងច្បាប់ពាក់ព័ន្ធ

២. កាលបរិច្ឆេទ ពេលវេលា ទីកន្លែងដែលបទល្មើសកើតឡើង និងភាគីពាក់ព័ន្ធ

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិទទួលបាន។

ជាពិសេស ទម្រង់បទដ្ឋាននៃសេចក្តីសម្រេច គួររំឭកចៅក្រមអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការសន្និតទុកជាមុនថាគ្មានទោសរហូតដល់មានសេចក្តីសម្រេចជាស្ថាពរ និងអាជ្ញាអស់ជំនុំ ព្រមទាំងប្រាប់ថាបន្ទុកនៃភស្តុតាងគឺព្រះរាជអាជ្ញា។

៦.១.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីបទចោទប្រកាន់ និងសិទ្ធិរបស់ពួកគេដែរឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះ គួរតែជាហេតុផលនៃការប្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោស។

## ៦.២ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព

៦.២.១ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៣០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថាមាត្រានេះស្របនឹងមាត្រា ៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន(ការឱ្យរួចផុតពីបទចោទ) ដើម្បីលើកកម្ពស់សិទ្ធិមានសេរីភាពរបស់ជនជាប់ចោទ ដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទ និងត្រូវបង្គាប់ឱ្យដោះលែងជនជាប់ចោទនោះភ្លាម ទោះបីជាតំណាងអយ្យការប្តឹងនឹងសេចក្តីសម្រេចនេះក៏ដោយ។

៦.២.២ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួស ជាជាងការឃុំខ្លួន រួមទាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងអនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ចំណុច ១៦.៣.២ ដើម្បីធានាបាននូវការលើកលែងការឃុំខ្លួន និងរក្សានូវសិទ្ធិមានសេរីភាព ដោយផ្អែកលើការវាយតម្លៃនៃសំណុំរឿងនីមួយៗ។

៦.២.៣ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួស ជាជាងការកាត់ទោសឱ្យជាប់ពន្ធនាគារ ជាពិសេសសំណុំរឿងដែលជនជាប់ចោទជាកុមារ។

៦.២.៤ តុលាការត្រូវធានាថា ជនជាប់ចោទ ជាពិសេសជនជាប់ឃុំត្រូវបាននាំយកមកជំនុំជម្រះភ្លាមៗតាមដែលអាចធ្វើទៅបាន និងការពន្យារពេលដោយគ្មានសំអាងហេតុត្រឹមត្រូវប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងការផ្តល់យុត្តិធម៌យ៉ាងឆាប់រហ័ស។

## ៦.៣ អនុសាសន៍ស្តីពីសិទ្ធិទទួលបានមេធាវី

៦.៣.១ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឱ្យជនជាប់ចោទទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទទួលបានមេធាវី ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

៦.៣.២ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទដែលគ្មានមេធាវី អាចពិនិត្យមើលសំណុំរឿងរបស់ខ្លួនមុនពេលចូលសវនាការ និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការការពារខ្លួនដោយខ្លួនឯង។

៦.៣.៣ ចៅក្រមគួរប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេ ប្រសិនបើពួកគេមិនមានមេធាវីការពារ។

៦.៣.៤ តុលាការគួរធានាថា មិនមានទំនាស់ផលប្រយោជន៍ ក្នុងករណីដែលមេធាវីម្នាក់ការពារឱ្យជនជាប់ចោទច្រើននាក់នៅពេលសវនាការ។

៦.៣.៥ ក្រសួងយុត្តិធម៌ គួរជូនដំណឹងដល់សាធារណជន អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដែលរដ្ឋជាអ្នករ៉ាប់រងតាមរយៈការផ្សព្វផ្សាយនៅតាមប៉ុស្ដិ៍នគរបាល ពន្ធនាគារ និងអគារតុលាការផងដែរ។

## ៦.៤ អនុសាសន៍ស្ដីពីសិទ្ធបង្ហាញភស្តុតាង

៦.៤.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិបង្ហាញភស្តុតាងរបស់ពួកគេ ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងការបង្ហាញភស្តុតាងប្រឆាំងនឹងពួកគេដែរ។

៦.៤.២ ចៅក្រមគួរបង្គាប់ឱ្យសាក្សីចាកចេញពីបន្ទប់សវនាការ រហូតទាល់តែពួកគេត្រូវបានកោះហៅឱ្យផ្ដល់សក្ខីកម្មទើបអាចត្រឡប់មកវិញបាន ដែលនេះជាមធ្យោបាយមួយដើម្បីធានាថា សាក្សីមិនរងឥទ្ធិពលពីភស្តុតាង និងសក្ខីកម្មផ្សេងទៀតដែលបានបង្ហាញនៅពេលសវនាការ។

៦.៤.៣ ចៅក្រមត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ន ថាតើភស្តុតាងដែលបានបង្ហាញមានលក្ខណៈហួសពីវិមតិសង្ស័យដែលថាជនជាប់ចោទមានពិរុទ្ធភាពដែរឬទេ។ ប្រសិនបើមានការបកស្រាយថាភស្តុតាងដែលស៊ីសង្វាក់គ្នានឹងភាពគ្មានទោសរបស់ជនជាប់ចោទ ដូច្នោះជនជាប់ចោទត្រូវតែរួចពីបទចោទ។

៦.៤.៤ ក្រសួងយុត្តិធម៌ គួររៀបចំបង្កើតគោលការណ៍ណែនាំច្បាស់លាស់ទាក់ទងនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង ដោយផ្អែកលើការអនុវត្តរបស់ អ.វ.ត.ក[192] និងធានាថា ចៅក្រមទាំងអស់ទទួលបានការបណ្ដុះបណ្ដាលសមស្រប។

## ៦.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៦.៥.១ ចៅក្រមគួរអានប្រាប់ជនជាប់ចោទអំពីការចោទប្រកាន់លើពួកគេ និងផ្ដល់ព័ត៌មានពាក់ព័ន្ធនានាដូចជាកាលបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងច្បាប់ជាធរមាន។ ប្រការនេះមានសារៈសំខាន់ជាពិសេស ក្នុងករណីដែលបទចោទប្រកាន់អាចត្រូវបានប្ដូរ ឬកែចាប់តាំងពីពេលចាប់ខ្លួន/ចោទប្រកាន់ដំបូង។

៦.៥.២ ចៅក្រមគួរផ្ដល់ការពន្យល់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីសិទ្ធិទទួលបានជំនុំជម្រះរបស់ជនជាប់ចោទទោះបីជាពួកគេត្រូវបានពន្យល់រួចហើយនៅសាលាដំបូងក៏ដោយ។

៦.៥.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ តើពួកគេយល់ដឹងអំពីបទចោទប្រកាន់មកលើពួកគេ និងសិទ្ធិរបស់ពួកគេដែរឬទេ។

---

[192] ការអនុវត្តរបស់ អ.វ.ត.ក អាចជាការណែនាំដ៏មានប្រយោជន៍ ជាពិសេសវិធានផ្ទៃក្នុងរបស់ខ្លួន ដូចជាវាក្យខណ្ឌ២០៤ ដល់ ២០៩ នៃសំណុំរឿងលេខ ០០២/០១ សាលក្រមរបស់អង្គបុរេជំនុំជម្រះ សូមមើល "សាលក្រមអង្គបុរេជំនុំជម្រះ"; អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦) សំណុំរឿង/សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCC/SC, https://tinyurl.com/3xyzz4wz

## ៦.៦ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ

៦.៦.១ តុលាការ និងអគ្គនាយកដ្ឋានពន្ធនាគារ គួរពិគ្រោះយោបល់ និងសម្របសម្រួលគ្នា ដើម្បីដោះស្រាយបញ្ហាភស្តុភារ និងទំនាក់ទំនងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានទាក់ទងនឹងទីតាំងរបស់ជនជាប់ចោទ ដើម្បីធានាឱ្យជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

៦.៦.២ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ព័ត៌មានអំពីការផ្ទេរជនជាប់ឃុំ គឺត្រូវបានបញ្ជូនជាទៀងទាត់ទៅកាន់មហាអយ្យការ ដើម្បីធានាថាតុលាការនឹងផ្តល់ព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលានៃសវនាការនៃបណ្តឹងឧទ្ធរណ៍ទៅដល់មណ្ឌលអប់រំកែប្រែដែលឃុំខ្លួនជនជាប់ចោទឱ្យបានត្រឹមត្រូវ។

៦.៦.៣ ចៅក្រមគួរពន្យារពេលសវនាការណាមួយ ប្រសិនបើជនជាប់ចោទមិនមានវត្តមាន ទោះបីជាពួកគេមានមេធាវីការពារក៏ដោយ លុះត្រាតែពួកគេបានលះបង់សិទ្ធិមានវត្តមានជាផ្លូវការរបស់ខ្លួន។

## ៦.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៦.៧.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទឱ្យបានច្បាស់ អំពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ រហូតទាល់តែមានសេចក្តីសម្រេចជាស្ថាពរ និងអំពីបន្ទុកនៃភស្តុតាងជាភារកិច្ចរបស់ព្រះរាជអាជ្ញា ហើយជនជាប់ចោទមានសិទ្ធិនៅស្ងៀម ដែលចៅក្រមមិនអាចប្រើប្រាស់ភាពនៅស្ងៀមនេះប្រឆាំងនឹងជនជាប់ចោទឡើយ។

៦.៧.២ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ គួរផ្សព្វផ្សាយអំពីគោលការណ៍ណែនាំច្បាស់លាស់ទៅតុលាការដែលបញ្ជាក់ថាជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ស៊ីវិលធម្មតា។

៦.៧.៣ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ជនជាប់ចោទដែលត្រូវបាននាំមកតុលាការមិនត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវទេ។

៦.៧.៤ ចៅក្រមគួរអនុញ្ញាតឱ្យជនជាប់ចោទ ដែលត្រូវបាននាំមកតុលាការក្នុងឯកសណ្ឋានទណ្ឌិតត្រូវស្លៀកពាក់ឯកសណ្ឋានស៊ីវិលជំនួសវិញមុនពេលសវនាការ។

## ៦.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព

៦.៨.១ តុលាការត្រូវតែស៊ើបអង្កេតភ្លាមៗ ដោយហ្មត់ចត់ និងមានប្រសិទ្ធភាពចំពោះការលើកឡើងរបស់ជនជាប់ចោទថាមានការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពមុននឹងចេញសេចក្តីសម្រេច។

៦.៨.២ តុលាការត្រូវធានាថា ប្រសិនបើមានការលើកឡើងថាមានការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្មណាមួយ ដូចនេះ រាល់ភស្តុតាង ឬចម្លើយសារភាពដែលទទួលបានតាមវិធីបែបនេះ គឺមិនអាចទទួលយកបានឡើយ ហើយត្រូវធ្វើការជំនុំជម្រះឡើងវិញ និងធានាថាមានការជួសជុលសំណងសមរម្យដល់ជនរងគ្រោះ។

៦.៨.៣ ក្រសួងយុត្តិធម៌គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៩៨ នៃក្រមនេះពាក់ព័ន្ធនឹងការឃាត់ខ្លួនដោយនគរបាល ដោយលុបចេញរយៈពេល ២៤ ម៉ោងបន្ទាប់ពីសម្រេចថាឃាត់ខ្លួន ដើម្បីឱ្យជនសង្ស័យធ្វើការសន្ទនាជាមួយមេធាវី ឬបុគ្គលដែលខ្លួនជ្រើសរើសបានឆាប់ដែលអាចធ្វើទៅបាន ។

## ៦.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ

៦.៩.១ តុលាការត្រូវធានាថាសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយសរសេរអក្សរកាត់ក្នុងករណីចាំបាច់ ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬសម្រាប់ហេតុផលណាមួយផ្សេងទៀត។

៦.៩.២ ដោយអនុវត្តតាមរបស់ អ.វ.ត.ក[193] គួរបង្កើតក្របខ័ណ្ឌមួយដែលចៅក្រមមានកាតព្វកិច្ចក្នុងការប្រាប់ និងពន្យល់អំពីសំអាងហេតុច្បាប់ និងភស្តុតាងលើមូលដ្ឋាននៃសេចក្ដីសម្រេចរបស់ខ្លួន ហើយធានាថាសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរមានសំអាងហេតុត្រូវបានផ្ដល់ដល់ជនជាប់ចោទ។

## ៦.១០ អនុសាសន៍ទាក់ទងនឹងវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី

៦.១០.១១ ចៅក្រមត្រូវធានាថាបានបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការស្ដាប់សវនាការរបស់ខ្លួន ដើម្បីធានាថាសំណុំរឿងរបស់ខ្លួនត្រូវបានជំនុំជម្រះបានត្រឹមត្រូវ និងដោយហ្មត់ចត់។

៦.១០.១១ ក្រសួងយុត្តិធម៌ និងឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម គួរធ្វើការរួមគ្នាដើម្បីពិនិត្យឡើងវិញលើក្រមសីលធម៌របស់ចៅក្រម និងធ្វើការកែសម្រួលតាមការចាំបាច់។ ការកែសម្រួលគួររាប់បញ្ចូលទាំងការហាមឃាត់លើការប្រើប្រាស់ទូរស័ព្ទ និងគួរអនុញ្ញាតឱ្យមានការសម្រាករយៈពេលខ្លី ដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងមេធាវីចាកចេញពីបន្ទប់សវនាការ ឬទទួលទូរស័ព្ទរបស់ខ្លួន។

## ៦.១១ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

៦.១១.១ ចៅក្រមគួរពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ជាពិសេសមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការជំនុំជម្រះ និងការប្រកាសសេចក្ដីសម្រេចត្រូវធ្វើឡើងជាអសាធារណៈ។

៦.១១.២ ចៅក្រមគួរអនុវត្តតាមការប្រតិបត្តិល្អរបស់ អ.វ.ត.ក និងអនុញ្ញាតឱ្យកុមារទំនាស់នឹងច្បាប់បង្ហាញខ្លួននៅចំពោះមុខតុលាការដោយប្រើប្រាស់សម្លៀកបំពាក់របស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល។

៦.១១.៣ ចៅក្រមគួរកម្រិតការឃុំខ្លួនកុមារទំនាស់នឹងច្បាប់តែក្នុងករណីពិសេស នៅពេលដែលមិនមានជម្រើសផ្សេងទៀតប៉ុណ្ណោះ ហើយធានាថា ក្នុងករណីបែបនេះ រាល់វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីគោរពសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។

៦.១១.៤ ក្រសួងយុត្តិធម៌គួរធានាថា ចៅក្រម និងព្រះរាជអាជ្ញា គួរទទួលបានការបណ្ដុះបណ្ដាលជាក់លាក់ទាក់ទងនឹងយុត្តិធម៌កុមារ។

---

[193] សូមមើលជាពិសេស "សាលក្រមនៃអង្គបុរេជំនុំជម្រះ, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦, សំណុំរឿង/សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCC/SC, https://tinyurl.com/2amb8t57

៦.១១.៥ ចៅក្រមគួរពិនិត្យ និងប្រើប្រាស់វិធានការមិនឃុំខ្លួនកុមារទំនាស់នឹងច្បាប់ និងអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោសលើកុមារដែលត្រូវបានទទួលស្គាល់ថាជាការបំពានច្បាប់ព្រហ្មទណ្ឌ ដូចនេះ ត្រូវផ្តោតសំខាន់លើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោសតែម្យ៉ាង ព្រមទាំងផ្តោតលើឧត្តមប្រយោជន៍របស់កុមារផងដែរ។

៦.១១.៦ ក្រសួងយុត្តិធម៌ គួរអនុវត្តវិធានការបង្វែរដែលតាមរយៈវិធាននេះ កុមារទំនាស់នឹងច្បាប់ទទួលបានជំនួយគាំទ្រ និងស្តារនីតិសម្បទាចូលក្នុងសហគមន៍វិញ ដែលជាវិធានមួយជំនួសឱ្យការចោទប្រកាន់ជាផ្លូវការ។ វិធាននេះ ត្រូវអនុវត្តចំពោះគ្រប់កុមារទំនាស់នឹងច្បាប់ទាំងអស់ដែលប្រព្រឹត្តបទល្មើសដំបូង លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

៦.១១.៧ ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើច្បាប់ដែលមានស្រាប់ រួមទាំងច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅរបស់តុលាការ ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីប្រព័ន្ធយុត្តិធម៌កុមារ រួមមាន វិធានក្រុងប៉េកាំង គោលការណ៍ណែនាំរបស់អង្គការយូនីសេហ្វសម្រាប់កំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន[194] សៀវភៅណែនាំការអនុវត្តរបស់អង្គការយូនីសេហ្វសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ[195] និងកំណែទម្រង់ច្បាប់ របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ៕[196]

---

[194] អង្គការយូនីសេហ្វ "គោលការណ៍ណែនាំស្តីពីកំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន" (ឆ្នាំ២០១១) https://tinyurl.com/3y34324u

[195] អង្គការយូនីសេហ្វ សៀវភៅណែនាំការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (ឆ្នាំ២០០៧) ទំព័រ ១០៧ https://tinyurl.com/yc3c7v8x

[196] អង្គការយូនីសេហ្វ "កំណែទម្រង់ច្បាប់ និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ" ទំព័រ ៨៧, http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf។